ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

Extraordinary Chambers in the Courts of Cambodia

Chambres Extraordinaires au sein des Tribunaux Cambodgiens

---

អង្គជំនុំជម្រះសាលាដំបូង

Trial Chamber

Chambre de Premiere instance

# កំណត់ហេតុជាលាយលក្ខណ៍អក្សរ
# នៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្តី "ឌុច"
# សាធារណៈ

សំណុំរឿងលេខ ០០១/១៨-០៧-២០០៧-អវតក/អជសដ

**ថ្ងៃទី២៦ ខែសីហា ឆ្នាំ២០០៩**

**សវនាការលើកទី៦៥**

**ចៅក្រមសាលាដំបូង៖**

លោក និល ណុន ជាប្រធាន

លោកស្រី ស៊ីលយ៉ា ខាតរ៉ាយថ៍

*(Judge Silvia Carwright)*

លោក យ៉ា សុខន

លោក ហ្សង់ម៉ាក ឡាវែន៍

*(Judge Jean-Marc Lavegne)*

លោក ធូ មណី

លោក យូរ ឧត្តរា

លោកស្រី ក្លូឌា ហ្វេនស៍ *(Judge Claudia Fenz)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោកស្រី សែ កុលវុឌ្ឍី

លោក ឌុច ផារី

កញ្ញា ណាតាចា វីស៊ែល រីសឺ

*(Ms. Natacha Wexels-Riser)*

លោក ម៉ាត្ទ គ្រីស្ពារ *(Mr. Matteo Crippa)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក សេង ប៊ុនឃាង

លោក វាំងសង់ ដឺវ៉ាយដ៍ ដេស្មាឯល

*(Mr. Vincent DE WILDE D'ESTMAEL)*

លោក ប៉ាក ច័ន្ទលីណូ (ក្រឡាបញ្ជី)

**ជនជាប់ចោទ៖**

លោក កាំង ហ្គេកអ៊ាវ

**មេធាវីការពារជនជាប់ចោទ៖**

លោក ការ សាវុត្ថ

លោក ហ្វ្រង់ស្វ័រ រូ *(Mr. François ROUX)*

លោកស្រីម៉ារីប៉ូល កានីហ្សារេស

*(Ms. Marie-Paul CANIZARES)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

កញ្ញា ម៉ុច សុវណ្ណារី

កញ្ញា ទី ស្រីនណា

លោក អាឡាំង វែនណឺ*(Mr. Alain Werner)*

លោកស្រី ហ្វាប៊ីយ៉ែន ទ្រូស្ស ណាព្រូស

*(Ms. Fabienne Trusse-Naprous)*

កញ្ញា ចេស្ស៊ីកា ហ្វីណែល

*(Ms. Jessica FINELLE)*

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុំ អរុណ

**បញ្ជីឈ្មោះ អ្នកនិយាយ៖**

ភាសា ដែលប្រើប្រាស់ លើកលែងតែបានកំណត់ជាក់លាក់នៅក្នុងប្រតិចារឹក

| **អ្នកនិយាយ** | **ភាសា** |
|---|---|
| លោកស្រី ម៉ារីប៉ូល កានីហ្សារេស | បារាំង |
| ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍ | អង់គ្លេស |
| លោក វ៉ាំងសង់ ឌឺវ៉ាយថ៍ ដេស្វាឯល | បារាំង |
| លោក ការ សាវុត្ថ | ខ្មែរ |
| លោក គង់ ពិសី | ខ្មែរ |
| ចៅក្រម ហ្សង់ម៉ាក ឡាវ៉ែន៍ | បារាំង |
| កញ្ញា ម៉ុច សុវណ្ណារី | ខ្មែរ |
| លោក ហ្វ្រង់ស្វ័រ រ៉ូ | បារាំង |
| លោក សេង ប៊ុនឃាង | ខ្មែរ |
| ជនជាប់ចោទ | ខ្មែរ |
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំជម្រះ) | ខ្មែរ |
| លោកស្រី សែ កុលវុឌ្ឍី | ខ្មែរ |
| លោកស្រី ហ្វាប៊ីយ៉ែន ទ្រូស្ស ណាព្រូស | បារាំង |
| លោក អាឡាំង វ៉ែនណឺ | អង់គ្លេស |
| កញ្ញា ទី ស្រ៊ីនណា | ខ្មែរ |

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលមកក្នុងបន្ទប់សវនាការ)*

[០៩:០២:៣៨]

**ប្រធានអង្គជំនុំ៖**

អញ្ជើញអង្គុយចុះ ។ អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ ។ នៅព្រឹកនេះ គឺយើងបន្តនូវកិច្ចពិភាក្សាដេញដោលនូវចំពោះបណ្តឹងមួយចំនួន ដែលមេធាវីការពារក្តីបានជំទាស់តវ៉ាទៅនឹងការពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដែលបានលើកឡើងកាលពីម្សិលមិញ ។ ហើយមុននឹងដំណើរការពិភាក្សាដេញដោលអំពីបញ្ហានេះ អង្គជំនុំជម្រះសូមជម្រាបជូនដំណឹងដល់ភាគី និងសាធារណជនឲ្យបានជ្រាបថា នៅថ្ងៃនេះអង្គជំនុំជម្រះនឹងដំណើរការធ្វើសវនាការតែមួយព្រឹកទេ គឺរហូតដល់ម៉ោងដប់ពីរថ្ងៃត្រង់ ដោយនៅរសៀលអង្គជំនុំជម្រះត្រូវរៀបចំនូវកិច្ចប្រជុំផ្ទៃជាចាំបាច់បន្ទាន់ ដើម្បីដោះស្រាយបញ្ហាដែលនៅសេសសល់មួយចំនួន ។

ជាការពិតណាស់ គឺម្សិលមិញយើងបានសម្រាកដំណើរការសវនាការមុនម៉ោងកំណត់ ដើម្បីទៅប្រជុំពិភាក្សាដោះស្រាយបញ្ហា ប៉ុន្តែដោយសារបញ្ហាបន្ទាន់នោះ មានចំនួនច្រើនដែលមិនអាចពិភាក្សាដោះស្រាយចប់កាលពីម្សិលមិញ ។

ដូច្នេះ នៅរសៀលនេះចាំបាច់ត្រូវតែប្រជុំពិភាក្សា ដើម្បីសម្រេចឲ្យបានជាក់លាក់ និងបានដាច់ស្រេចនៅរសៀលនេះ ។ ហេតុនេះសូមភាគី និងសាធារណជនជ្រាប ។

ហើយមុននឹងដាក់បញ្ហាទៅភាគី ដើម្បីជជែកពិភាក្សា អង្គជំនុំជម្រះសូមធ្វើការណែនាំដល់ភាគីបញ្ហាមួយចំនួនដូចខាងក្រោមនេះ៖

នៅព្រឹកនេះ យើងនឹងដាក់បញ្ហាពិភាក្សាដេញដោលដោយភាគីមេធាវីការពារក្តីដោយលើកបញ្ហានីមួយៗជាក់លាក់ ។ ហើយមេធាវីតំណាងឲ្យដើមបណ្តឹងរដ្ឋប្បវេណី គឺមានសិទ្ធិនៅក្នុងការបង្ហាញហេតុផលតបវិញទៅលើអ្វី ដែលជាការកត់សម្គាល់ ឬក៏បង្ហាញហេតុផលនៃការជំទាស់តវ៉ារបស់មេធាវីការពារក្តី ។ ហើយទន្ទឹមនឹងនេះ ប្រសិនបើមានហេតុផលថ្មីដែលលើកឡើងដោយមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី មេធាវីការពារក្តីអាចលើកឡើងដើម្បីជំទាស់តវ៉ា ឬក៏ជជែកពិភាក្សាលើបញ្ហានោះបានតែម្តងប៉ុណ្ណោះ ។ គឺមិនផ្តល់លទ្ធភាពឲ្យភាគីធ្វើការជជែកដេញដោលនូវបញ្ហានីមួយ គឺចុះឡើងៗច្រើនលើកច្រើនសាដូចកាលពីអ្វី ដែលបានធ្វើកាលម្សិលមិញនោះទេ ។ ដូច្នេះ សូមភាគីជ្រាប ។

ហើយទន្ទឹមនេះអង្គជំនុំជម្រះក៏បានដឹង និងបានស្ដាប់រួចហើយអំពីសម្ដីរបស់តំណាងសហព្រះរាជអាជ្ញាកាលពីម្សិលមិញថា ខ្លួនមានបំណងធ្វើអត្ថាធិប្បាយអ្វីពាក់ព័ន្ធទៅនឹងពាក្យសុំតាំងខ្លួនដើមបណ្ដឹងរដ្ឋប្បវេណីនីមួយៗ ដែលបានលើកឡើងដោយមេធាវីការពារក្ដីនោះទេ ។ តែប្រសិនបើមាន សូមឲ្យតំណាងសហព្រះរាជអាជ្ញាបង្ហាញនូវជំហររបស់ខ្លួនអំពីកាលដែលខ្លួនមានបំណងក្នុងការធ្វើអត្ថាធិប្បាយពាក់ព័ន្ធទៅនឹងការប្រយោជន៍វិវាទ ប្រយោជន៍ផ្នែកខាងរដ្ឋប្បវេណីនៅក្នុងរឿងក្ដីនេះ ។

[០៩:០៧:១០]

ជាកិច្ចបន្តអង្គជំនុំជម្រះសូមអញ្ជើញមេធាវីការពារក្ដី ដើម្បីឡើងបង្ហាញអំពីហេតុផលទាំងឡាយនៃការជំទាស់តវ៉ារបស់ខ្លួនទៅតាមករណីនីមួយៗនៃពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ដែលបានបង្ហាញកាលពីម្សិលមិញ ។ សូមអញ្ជើញ ។

បង្អង់បន្តិចសិនមេធាវីការពារក្ដី ។ អញ្ជើញមេធាវីដើមបណ្ដឹងរដ្ឋប្បវេណីក្រុមបី ។

**លោកស្រី ហ្សាប៊ីយ៉ែន ទ្រូស្សូណាព្រូស៖**

សូមអរគុណលោកប្រធាន ។ តាមពិតខ្ញុំបានជម្រាបជូនអង្គសវនាការម្សិលមិញ មុនយើងពិនិត្យពាក្យសុំរបស់ដើមបណ្ដឹងរដ្ឋប្បវេណី ដែលអាចនឹងលើកឡើង បង្កើតឡើងនូវភាពលំបាកនោះ ។ ខ្ញុំចង់លើកឡើងអំពីចំណុចទូទៅ ឥឡូវនេះខ្ញុំមិនប្រាកដថាខ្ញុំទទួលបានការបកប្រែ-- តែឥឡូវខ្ញុំស្ដាប់ឮហើយ។

ដូច្នេះ ខ្ញុំសូមអនុញ្ញាតធ្វើសេចក្ដីសង្កេតមួយចំនួន ។ សេចក្ដីសង្កេតជាបឋមនោះ គឺថាអាចអនុញ្ញាតឲ្យខ្ញុំនិយាយពីបញ្ហាមួយចំនួនពាក់ព័ន្ធនឹងការលំបាក ដែលយើងនឹងជួបប្រទះ ដើម្បីផ្ដល់នូវចំណុចនានា ដែលជាភស្តុតាងនៅក្នុងពាក្យសុំតាំងខ្លួនជាដើមណ្ដឹងរដ្ឋប្បវេណី ។

ខ្ញុំសូមអនុញ្ញាតអង្គជំនុំជម្រះដើម្បីធ្វើសេចក្ដីសង្កេតជាទូទៅមួយ ។

*(ចៅក្រមពិភាក្សាគ្នា)*

**ប្រធានអង្គជំនុំ៖**

អញ្ជើញ ប៉ុន្ដែសូមឲ្យខ្លីបានហើយ ពីព្រោះម្សិលមិញបានមានបញ្ហានេះច្រើនរួចហើយ ហើយជាការងារមួយដូចជាចំណាយពេលវេលាច្រើនកាលពីម្សិលមិញ ។

**លោកស្រី ហ្សាប៊ីយ៉ែន ទ្រូស្សូណាព្រូស៖**

សូមគោរពលោកប្រធាន ។ តាមពិតខ្ញុំចង់ធ្វើសេចក្ដីសង្កេតបឋមមួយចំនួនពាក់ព័ន្ធទៅនឹងពាក្យបណ្ដឹងរបស់ដើមបណ្ដឹងរដ្ឋប្បវេណីរបស់យើង ។ ពីព្រោះថា តាមពិតថា យើងយល់វាមានភាពចាំបាច់

ដើម្បីជម្រាបជូនពីបញ្ហាធំៗចម្បងពីរ ដែលថាទំនាក់ទំនងទៅនឹងស-២១ ហើយមួយទៀតគឺបញ្ហាទីពីរ គឺទំនាក់ទំនងសាច់ញាតិ ឬថាភាពជាសាច់ញាតិជិតស្និតទៅនឹងជនរងគ្រោះនោះដូចម្ដេច?

អ៊ីចឹង ខ្ញុំសូមអនុញ្ញាត ដើម្បីកំណត់នៅក្នុងសេចក្ដីសង្កេតរបស់ខ្ញុំជាបឋមថា ចំណុចនេះមិនគប្បីត្រូវជំទាស់នោះទេ ពីព្រោះថាឯកសារនៅក្នុងស-២១ នោះមានទាំងស្រុងចំពោះជនរងគ្រោះខ្លះ ប៉ុន្តែមិនមានចំពោះជនរងគ្រោះមួយចំនួន ។ ពាក្យសុំខ្លះ គឺថាមានឈ្មោះជនរងគ្រោះ ពាក្យសុំខ្លះមានតែរូបថត ពាក្យសុំខ្លះមានប្រវត្តិរូបរបស់ជនរងគ្រោះ ។ ប៉ុន្តែ ចួនកាលយើងមិនអាចបញ្ចូលនូវធាតុផ្សំនៃភស្ដុតាងទាំងអស់នោះឱ្យគ្រប់នោះទេ ។ ដូច្នេះ ទាំងអស់នេះជាភស្ដុតាងសំខាន់ៗដែលយើងមាន ដោយសារបណ្ណាសារនៅស-២១ នោះវាមិនទាំងស្រុងគ្រប់អ្នកទោសទាំងអស់នោះទេ ។

អ៊ីចឹងហើយការសម្រេចដោយសាក្សីមួយចំនួនជាអ្នកជំនាញដូច លោក ដេវីដ ឆេនឌ័ល័រ នោះគាត់បានធ្វើការសិក្សាជាលម្អិតនូវបណ្ណសាររបស់ស-២១ ហើយគាត់បានប្រាប់យើងថា បណ្ណសារទាំងអស់ មួយចំនួននោះ គឺថាមិនពេញលេញទាំងស្រុងនោះទេ ។ គាត់បាននិយាយបញ្ជាក់ច្បាស់នៅពេលដែលគាត់បង្ហាញខ្លួននោះ គឺថានៅ ERN 006227 នោះ ដែលថាដើមបណ្ដឹងរដ្ឋប្បវេណីខ្លះ បានចង្អុលបង្ហាញពីរបៀប ដែលខ្លួនអាចនឹងមានលទ្ធភាពចូលមើលឯកសារដូចជា អង់តូនីញ៉ា ជូឡុង ដែលគាត់និយាយអំពីបងប្អូនជីដូនមួយ ។ គាត់ថា លទ្ធភាពនៃការបើកមើលឯកសារនៅឆ្នាំ១៩៧៩ នោះ គឺថាជាឯកសារនៅក្រោមធ្នឹរស-២១ គឺថារកឃើញនៅតាមផ្លូវ ។ នេះហើយជាទិដ្ឋភាពមួយដែលថាបណ្ណសារនោះមិនទាំងស្រុង ទាំងមូលនៅនឹងស-២១ ទាំងអស់ទេ ។

អ៊ីចឹងហើយខ្ញុំជឿជាក់ថា វាអាចមានលទ្ធភាពឱ្យយើងបញ្ជាក់នៅពេលនេះថា មិនចាំបាច់ទៅមានទាំងអស់ទេ មិនមែនមានន័យថា ដោយសារថា យើងមិនមានទំនាក់ទំនងជិតស្និទ្ធទៅនឹងដើមបណ្ដឹងរដ្ឋប្បវេណីរបស់ ដែលនៅក្នុងបណ្ណសារស-២១ នោះ ។ នោះមានន័យថា ជនរងគ្រោះនោះ គឺមិនត្រូវបានឃុំ ឬក៏មិនបានកម្ទេចនៅស-២១ នោះទេ ។ ពីព្រោះឯកសារវាបានបាត់ចេញពីកន្លែងហ្នឹង ។

លោកប្រធាន លោក លោកស្រីចៅក្រម ជាទីគោរព! ខ្ញុំយល់ថាអង្គជំនុំជម្រះនឹងប្រើសិទ្ធិឆន្ទានុសិទ្ធិ ដើម្បីពិចារណារបស់ពាក្យសុំរបស់ដើមបណ្ដឹងរដ្ឋប្បវេណី ដើម្បីវាយតម្លៃនឹងភាពសមស្រប ដោយផ្អែកទៅលើបរិបទប្រវត្តិសាស្ត្រ ជាបរិបទមួយដែលថាជាក់លាក់ ទាក់ទងទៅនឹងពាក្យសុំនីមួយៗរបស់យើងខ្ញុំ ។ ជាពិសេសភស្ដុតាងពាក់ព័ន្ធមួយចំនួន ដែលយើងមានលទ្ធភាពទទួលបាននៅក្នុងដំណាក់កាលស៊ើបអង្កេត ហើយនិងក្នុងពេលសវនាការនេះផងដែរ ។

ជាពិសេសទៅទៀត ពាក់ព័ន្ធទៅនឹងស-២១ យើងបានឮជាញឹកញាប់ហើយពីជនជាប់ចោទថា គាត់មិនទទួលស្គាល់ថា មានការនៅតម្កើទាំងស្រុងរូបថតនៅស-២១ ទេ ។ ប៉ុន្តែ ខ្ញុំសូមបញ្ជាក់ គឺមិនមែនទៅតាមសម្តីរបស់ជនជាប់ចោទដើម្បីនិយាយថាភស្តុតាងហ្នឹងអាចទទួលយក ឬមិនទទួលយកនោះទេ គឺជាអង្គជំនុំជម្រះ គឺជាអ្នកមានសិទ្ធិអំណាចក្នុងការសម្រេចថា អាចទទួលយក ឬក៏មិនទទួលយក។

ប៉ុន្តែ ដើម្បីចៀសវាងនូវការលំបាកមួយចំនួនដើមបណ្តឹងរដ្ឋប្បវេណីនៅក្រុមរបស់ខ្ញុំ គឺដូចគ្នានឹងក្រុមផ្សេងទៀតដែរ យើងបានស្នើសុំសារមន្ទីរស-២១ ដើម្បីឲ្យធ្វើការបញ្ជាក់អំពីភាពទាក់ទង ឬក៏ប្រភពដើមនៃរូបថតទាំងអស់ហ្នឹង ដើម្បីសុំអង្គជំនុំជម្រះពិនិត្យមើលតាមករណីនីមួយៗ ។ ហើយតាមពិត គឺថាប្រភពនៃរូបថតទាំងអស់នោះ គឺត្រូវបានបញ្ជាក់ដោយសារមន្ទីរទួលស្លែង ។ ម្យ៉ាងវិញទៀត យើងយល់ឃើញថា ពាក្យសុំមួយចំនួន យើងមានរូបថត ហើយយើងមានឈ្មោះនៅលើបញ្ជីអ្នកទោសនោះផងដែរ ។ ពេលខ្លះយើងមានប្រវត្តិរូបរបស់ជនរងគ្រោះ ហើយតាមពិតមិនមែនចាំបាច់ដើម្បីតម្រូវឲ្យប្រមូលនូវឯកសារទាំងអស់ចេញពីបណ្ណសារស-២១ ដើម្បីបញ្ជាក់អំពីភស្តុតាង ដែលទាក់ទងថាជនរងគ្រោះត្រូវបានឃុំខ្លួន ឬកម្ទេចនៅស-២១ នោះទេ ។ នេះហើយជាករណី ដែលយើងចង់ជម្រាប ។ សូមអភ័យទោសលោកប្រធាន ។

*(គ្មានការបកប្រែ)*

**ប្រធានអង្គជំនុំ៖**

បាទ, និយាយឲ្យយឺតបន្តិច បើញាប់ពេកអាចការបកប្រែ បកប្រែមិនទាន់ ។ សូមលោកស្រីមេធាវីនិយាយឲ្យបានយឺតបន្តិច ដើម្បីឲ្យការបកប្រែហ្នឹង បកប្រែភាសាហ្នឹងបកទាន់ ហើយពេញលេញល្អ ។

អត់ឮ! មើល មើលមន្ត្រីតុលាការរៀបមើលប្រព័ន្ធសំឡេង មានបញ្ហា អត់ឮទេ ។

**លោកស្រី ហ្សាប៊ីយ៉ែន ទ្រូស្សូណាព្រូស៖**

ឈ្មោះត្រឹមត្រូវរបស់គាត់ ដោយបានពិនិត្យឃើញថា ជនរងគ្រោះទាំងនេះអនុវត្តទៅតាមទំនៀមទម្លាប់ខ្មែរ ចួនកាលអាចប្រើនាមត្រកូលជាឈ្មោះឪពុក ឬក៏ពេលខ្លះប្រើជីតា ឬក៏ជាឈ្មោះបដិវត្តន៍របស់គាត់នោះផងទៀត ដែលដើមបណ្តឹងរដ្ឋប្បវេណីមិនបានដឹង ឬក៏អ្នកខ្លះក៏បានភ្លេចឈ្មោះបដិវត្តន៍របស់ខ្លួនទៅទៀត ។ នេះជាចំណុចមួយដែលពាក់ព័ន្ធទៅនឹងចំណុចទីមួយ ដែលនិយាយការពាក់ព័ន្ធទៅនឹងស-២១ ។

[០៩:១៨:៥៤]

ឥឡូវនេះ ខ្ញុំចូលទៅដល់ចំណុចទីពីរ ខ្ញុំចង់ជម្រាបថា គឺទំនាក់ទំនងសាច់ញាតិ ញាតិលោហិត ឬក៏ញាតិពន្ធរវាងដើមបណ្តឹងរដ្ឋប្បវេណីទៅជនរងគ្រោះ ។ ចំណុចនេះ វាមានសារសំខាន់ណាស់ ដើម្បីចង្អុលបង្ហាញនៅក្នុងសេចក្តីផ្តើម ដើម្បីបញ្ជាក់ថាយើងត្រូវពិចារណាលើបរិបទប្រវត្តិសាស្ត្រ ទាំងអស់ ហើយនិងបរិបទសង្គមសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជាផងដែរ ។ តាមពិតដើមបណ្តឹងរដ្ឋប្បវេណីមួយចំនួន មិនអាចផ្តល់នូវឯកសារចុះបញ្ជីជាអាត្រានុកូលដ្ឋានឲ្យបានច្បាស់ទេ ពីព្រោះថាឯកសារទាំងនោះមិនមាន ឬក៏ត្រូវបានបាត់បង់ ។ ហើយជាពិសេស គឺថាស្ថានភាពនេះ គឺថាមានលំបាកណាស់នៅថ្នាក់ឃុំ ឬក៏ថ្នាក់ស្រុក ឬក៏ថ្នាក់ខេត្ត ឬក៏ជួបបញ្ហាស្រដៀងគ្នានេះឯង ។

ដូច្នេះ សំខាន់យើងត្រូវពិចារណាទៅលើការលំបាករបស់ក្រុមគ្រួសារនីមួយៗនៃប្រជាជន ដែលនៅក្នុងតំបន់មួយចំនួនដែរ ។ ដូច្នេះ ខ្ញុំជឿជាក់ថា ជាសំខាន់យើងត្រូវពិចារណាទៅលើកត្តាទាំងអស់នេះ ដែលជាចំណុចសំខាន់នៃដំណាក់កាលនីតិវិធីនេះ ដែលយើងយោងទៅវិធានកវិធាន៨៧នៃវិធានផ្ទៃក្នុង ដែលវិធាននោះចែងថា “ភស្តុតាងនៅក្នុងរឿងក្តីព្រហ្មទណ្ឌត្រូវតែបង្ហាញ” ។ ក្នុងករណីមួយចំនួន យើងមានលទ្ធភាព ហើយយើងអាចផ្តល់នូវធាតុផ្សំអំពីប្រភព ជាពិសេសពីទំនាក់ទំនងសាច់ញាតិ ឬក៏ភាពជិតស្និទ្ធរវាងដើមបណ្តឹងរដ្ឋប្បវេណីទៅនឹងជនរងគ្រោះ ។ នេះ គឺថាយើងផ្អែកទៅលើឯកសារ ឬក៏ព័ត៌មានរបស់អាជ្ញាធរមូល ដូចជាមេឃុំជាដើម ។

ក្នុងករណីមួយចំនួនទៀត យើងមានលទ្ធភាពដើម្បីដាក់ជូននូវជាសេចក្តីថ្លែងការណ៍អះអាងរបស់មនុស្សមួយចំនួន ដូចជា ឪពុកម្តាយ មិត្តភក្តិ អ្នកជិតខាង អ្នកដែលអាចធ្វើសាក្សីបញ្ជាក់ថា ទំនាក់ទំនងសាច់ញាតិ ឬក៏ញាតិពន្ធរបស់ដើមបណ្តឹងរដ្ឋប្បវេណីមានជាមួយនឹងជនរងគ្រោះ ។

នៅក្នុងករណីផ្សេងទៀត យើងពិនិត្យឃើញថា អានេះវាអាស្រ័យទៅលើករណីនីមួយៗហើយ សេចក្តីអះអាងប្រកាសនេះ គឺថាអាចទំនាក់ទំនងនោះ គឺថាមានគ្រប់គ្រាន់ហើយ ដោយមិនចាំបាច់បង្ហាញភស្តុតាងតាមរយៈការស៊ើបអង្កេតអ្វីឲ្យលើសពីអ្វីដែលយើងមាននោះទេ ។ ហើយនៅពេលនេះខ្ញុំយល់ថា ទាំងអស់នេះ គឺជាធាតុផ្សំដ៏សំខាន់ដើម្បីបញ្ជាក់អំពីការពិតរបស់បុគ្គលនីមួយៗ ។

*(មានបញ្ហាបច្ចេកទេស)*

[០៩:២៤:០៣]

--ដោះស្រាយអំពីសញ្ញាណ អំពីនិយមន័យថា តើសាច់ញាតិ ហើយនិងសាច់ញាតិជិតស្និទ្ធ និង

សាច់ញាតិឆ្ងាយនោះ វាមានន័យដូចម្ដេច?

តាមពិត សេចក្តីណែនាំអនុវត្តនៅក្នុងមាត្រា៣.២(ក) និយាយថា “ស្ថានភាពដែលថា មានការព្យសនកម្មអំពីផ្លូវចិត្ត អំពីការបាត់បង់សមាជិកក្រុមគ្រួសារដែលរាប់បញ្ចូលថា ជនរងគ្រោះដែលត្រូវបានបាត់បង់ពីការប្រព្រឹត្តិលើបទល្មើសដែលបានចោទ” ។ ហើយសាច់ញាតិនោះ អាចជាសមាជិកក្រុមគ្រួសារផ្ទាល់ ឬក៏ជាបុគ្គលមួយទៀតខាងក្រៅ ដូចជា មិត្តភក្តិ ដែលថាមានទំនាក់ទំនងមនោសញ្ចេតនា ឬក៏គុណស្រ័យអ្វីមួយដែរ ។ ហើយខ្ញុំនឹងនិយាយដល់សេចក្តីដកស្រង់មួយ ដោយទ្រឹស្តីមួយនៅក្នុងឆ្នាំ ១៩៧០ នៅពេលដែលគាត់សិក្សាអំពីសេចក្តីសម្រេចរបស់តុលាការកំពូលបារាំងនោះ ដែលតាមពិតដែលបញ្ជាក់អំពីបញ្ជីរបស់មនុស្សមួយចំនួនដែលអាចនឹងមានសិទ្ធិទៅតាមផ្លូវច្បាប់បាន ។ ដូច្នេះ អ្នកច្បាប់ *ហ្វីលីព ឡឺទួរណូ* នោះបាននិយាយថា “គោលការណ៍នៃការទទួលសំណងជម្ងឺចិត្តនេះត្រូវតែបង្ហាញភស្តុតាងច្បាស់” ។

ដូច្នេះ ខ្ញុំជឿជាក់ថា ទាក់ទងនៅក្នុងក្រុមរបស់យើង ខ្ញុំជឿជាក់ថា ធាតុផ្សំទាំងអស់នេះ គឺមានទាំងអស់រួចហើយ ហើយក្រុមផ្សេងទៀត ក៏មានប្រហែលគ្នាហ្នឹងដែរ ។ ហើយនេះហើយ វាស្របទៅតាមលំដាប់លំដោយផ្អែកទៅលើការអះអាងសេចក្តីថ្លែងបញ្ជាក់ ដែលថានៅក្នុងកាលៈទេសៈនេះអនុញ្ញាតឱ្យអង្គជំនុំជម្រះធ្វើនូវសេចក្តីសម្រេច ដើម្បីគាំទ្រការសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់យើងខ្ញុំ។

[០៩:២៧:០៩]

ចំណុចនេះត្រូវតែបញ្ជាក់ថា អ្នកដែលរងការឈឺចាប់នោះ គឺត្រូវតែនឹងទទួលបានសិទ្ធិក្នុងការធ្វើជាដើមបណ្តឹងរដ្ឋប្បវេណី ។ ហើយក្នុងករណីនេះ យើងនឹងអនុញ្ញាតអង្គជំនុំជម្រះធ្វើការពិចារណាសម្រេចដើម្បីជាអត្ថប្រយោជន៍របស់ជនរងគ្រោះដើមបណ្តឹងរដ្ឋប្បវេណីស្វែងរកការពិតក្នុងរឿងក្តីនេះ ។

លោកប្រធានជាទីគោរព លោក លោកស្រីចៅក្រម ជាសេចក្តីផ្តើមដំបូងតែប៉ុណ្ណេះពីយើងខ្ញុំ ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញតំណាងសហព្រះរាជអាជ្ញាអន្តរជាតិ ។

**លោក វាំងសង់ ដឺវ៉ាយដ៍ ដេស្សាឯលៈ**

សូមអរគុណលោកប្រធាន ។ ដោយពិចារណាថា សហព្រះរាជអាជ្ញានឹងមិនចូលរួមនៅក្នុងការដេញដោលទៅលើដើមបណ្តឹងរដ្ឋប្បវេណីនីមួយៗនោះទេ ។ យើងសូមផ្តល់សេចក្តីសង្កេតជាទូទៅ ដូចនឹងអ្វីដែលបានលើកឡើងដោយលោកស្រី ទ្រូស្សូណាព្រួស ដែលគាត់តំណាងដើមបណ្តឹងរដ្ឋប្បវេណី

របស់គាត់នៅក្នុងក្រុម ។ ហើយក៏ខ្ញុំយល់ឃើញថា មេធាវីដើមបណ្តឹងរដ្ឋប្បវេណីក៏យល់ស្របទៅលើចំណុចនោះដែរ ។ ហើយចំពោះយើងខ្ញុំនោះ ភស្តុតាងទាំងអស់គឺអាចអនុវត្តទៅតាមវិធាន២៣ ហើយអង្គជំនុំជម្រះត្រូវពិចារណាឲ្យបានសមស្រប ដោយផ្អែកទៅលើភស្តុតាង និងធាតុផ្សំទាំងឡាយបង្ហាញជូនអង្គសវនាការ ហើយនិងដោយផ្អែកទៅលើភាពពាក់ព័ន្ធគ្នារវាងធាតុផ្សំទាំងអស់នោះ ហើយនិងពិនិត្យទៅលើមូលហេតុដែលទាក់ទងទៅនឹងពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី និងរួមទាំងចម្លើយសេចក្តីថ្លែងផ្សេងៗរបស់ដើមបណ្តឹងរដ្ឋប្បវេណី ដែលមាននៅក្នុងសំណុំរឿង ។ ខ្ញុំយល់ឃើញថាយើងត្រូវពិចារណាផងដែរទៅលើការវាយតម្លៃទៅលើភស្តុតាងទាំងអស់នោះ ដោយយើងពិចារណាទៅលើធាតុផ្សំមួយចំនួន ធាតុផ្សំទាំងអស់នោះត្រូវបានលើកឡើងហើយ ដោយមេធាវីតំណាងរដ្ឋប្បវេណី ។

ធាតុផ្សំទីមួយ គឺទាក់ទងទៅនឹងអង្គហេតុដែលថា វាកើតឡើងសាមសិបឆ្នាំរួចមកហើយហើយចំពោះដើមបណ្តឹងរដ្ឋប្បវេណីគាត់បានពន្យល់ហើយ វាមិនអាចឲ្យគាត់រក្សាឯកសារបាននោះទេ ដែលវាជាគុណប្រយោជន៍សម្រាប់ពេលបច្ចុប្បន្ន ។ ហើយចំពោះដើមបណ្តឹងរដ្ឋប្បវេណីដែលគាត់មកចូលខ្លួននៅទីនេះ គឺគាត់តែងតែពន្យល់អំពីរបបខ្មែរក្រហម ហើយបង្ហាញអំពីហេតុផលដែលថា រូបថតជនរងគ្រោះបងប្អូនគាត់ត្រូវបំផ្លាញនៅក្នុងអំឡុងពេលនោះ ដូច្នេះហើយទើបគាត់មិនអាចបង្ហាញភស្តុតាង និងរូបថតទាំងអស់នោះនៅពេលនេះ ។

ខ្ញុំសូមផ្តល់ជាយោបល់ថា បណ្ណសារគឺ មិនអាចមាលក្ខណៈពេញលេញនោះទេ ដោយសារតែឯកសារជាច្រើនត្រូវបានបំផ្លាញ ហើយឯកសារនីមួយៗនោះគឺវាខូចខាតទៅតាមពេលវេលា ដោយសារស្ថានភាពនិងលក្ខខណ្ឌនៃការថែរក្សាឯកសារ ។ ហើយឯកសារទាំងអស់នោះហើយ ដែលវាបានផ្តល់ជាផលប្រយោជន៍ឲ្យខាងសហព្រះរាជអាជ្ញារៀបចំជាបញ្ជីរួមទៅលើអ្នកទោសនៅស-២១ ដែលបញ្ជីនោះគឺផ្អែកទៅលើប្រវត្តិរូប បញ្ជីអ្នកទោសផ្សេងៗ ហើយនិងបញ្ជីសម្លាប់អ្នកទោស ហើយរួមទាំងរូបថតផ្សេងៗដែលយើងខ្ញុំប្រមូលបាន ។ បញ្ជីទាំងអស់នោះវាមិនពេញលេញនោះទេ ហើយជនជាប់ចោទនោះក៏បានទទួលយកបញ្ហា ហើយទទួលស្គាល់ទៅលើបញ្ហានេះផងដែរ ជាពិសេសនៅក្នុងដំណាក់កាលស៊ើបអង្កេត ។ ហើយឈ្មោះមួយចំនួនដែលមាននៅក្នុងបញ្ជីនោះ គឺវាមិនបានឆ្លុះបញ្ចាំងអំពីចំនួនមនុស្សស្លាប់នៅស-២១ នោះទេ។ ចំនួនដែលយើងបានប្រមូលផ្តុំនោះគឺវាមានចំនួនតិចជាងអ្វីដែលយើងគិតទុកហើយខ្ញុំមានការភ្ញាក់ផ្អើលនៅពេលដែលមេធាវីការពារក្តី នៅពេលមួយចំនួនបានបង្ហាញនិងលើកឡើងថាដោយសារតែបុគ្គល ឈ្មោះរបស់បុគ្គលមិនមាននៅក្នុងបញ្ជីរួមនោះ គឺវាមិនមានភស្តុតាងដែលបញ្ជាក់

ថា បុគ្គលនោះត្រូវបាននាំខ្លួនចូលមកស-២១ ហើយសម្លាប់ចោលនៅទីនោះ ។ ហើយចំពោះខ្ញុំ ខ្ញុំយល់ឃើញថា នេះគឺជាឥរិយាបថមួយដែលថាយើងឃើញថា គាត់សន្និដ្ឋានយ៉ាងលឿនបំផុតនៅពេលគាត់មិនឃើញមានឈ្មោះនៅក្នុងបញ្ជី ហើយដោយសារតែបញ្ជីនោះមានលក្ខណៈពេញលេញ ។

[០៩:៣៣:៣៦]

**ប្រធានអង្គជំនុំ៖**

អញ្ជើញតំណាងសហព្រះរាជអាជ្ញាបន្ត ។

**លោក វ៉ាំងសង់ ដឺវ៉ាយដ៍ ដេស្មាឯល៖**

ទាក់ទងទៅនឹងការចុះឈ្មោះផ្សេងៗដែលយើងបានលើកឡើងនេះ យើងត្រូវពិចារណាអំពីស្ថានភាពដែលថា បញ្ហាការចុះឈ្មោះផ្សេងៗនោះ មិនថានៅពេលអតីត ឬក៏ពេលបច្ចុប្បន្ន ។ ការចុះឈ្មោះទាំងអស់នោះ គឺវាអាចទាក់ទងទៅនឹងការបង្ហាញទៅលើភាពត្រឹមត្រូវនៃអត្តសញ្ញាណប័ណ្ណ ឬក៏អាចបង្ហាញអំពីទំនាក់ទំនងញាតិលោហិតជាមួយនឹងជនរងគ្រោះនៅស-២១ ហើយខ្ញុំជឿថា យើងអាចពិចារណាទៅលើកិច្ចទាំងឡាយដែលបានធ្វើឡើងក្នុងការបញ្ជាក់លើលិខិតកំណើត ឬក៏លិខិតផ្សេងៗដែលបានរៀបចំឡើងដោយមេភូមិ មេឃុំ មេស្រុកផ្សេងៗ ។ ហើយនិងសក្ខីកម្មសេចក្តីថ្លែងផ្សេងៗរបស់សាក្សីដែលអាចបញ្ជាក់ទៅលើអត្តសញ្ញាណទាំងអស់នេះ ។

[០៩:៣៤:៥៧]

ដូច្នេះ ចំណុចចុងក្រោយ លោកប្រធានអង្គជំនុំជម្រះមិនទាន់បានកំណត់រយៈពេលកំណត់នៅឡើយ ឲ្យមេធាវីដើមបណ្តឹងរដ្ឋប្បវេណីប្រមូល នឹងប្រមូលផ្តុំទៅលើឯកសារទាំងនោះ ។ ហើយប្រសិនបើវាពាក់ព័ន្ធទៅនឹងករណីរបស់យើងនៅទីនេះ ក្នុងរឿងក្តីនីមួយៗមេធាវីដើមបណ្តឹងរដ្ឋប្បវេណីគាត់បានបញ្ជាក់ ហើយថាឯកសារមួយចំនោះគាត់កំពុងតែរៀបចំ ហើយគាត់មិនអាចផ្តល់ជូននៅក្នុងសវនាការថ្ងៃនេះ ។ ដូច្នេះ ខ្ញុំស្នើសុំអង្គសវនាការថា ពេលវេលាកំណត់ចុងក្រោយគួរតែប្រកាស ដើម្បីឲ្យធ្វើការរៀបចំ និងប្រមូលផ្តុំនៅឯកសារទាំងអស់នោះ ដើម្បីឲ្យបង្កើតឯកសារចុងក្រោយនោះ ហើយបានដាក់ចូលទៅក្នុងសំណុំយើងមុនពេលដែលយើងបញ្ចប់សវនាការដេញដោលរបស់យើង ។ ទាំងអស់នេះគឺជាសេចក្តីសង្កេតរបស់ខ្ញុំ ដែលខ្ញុំចង់លើកឡើងនៅក្នុងសេចក្តីសង្កេតបឋម ហើយយើងខ្ញុំពុំមានសេចក្តីសង្កេតបន្ថែមទៀតទេ ទាក់ទងទៅនឹងការពិភាក្សាដេញដោលទៅលើរឿងក្តីដើមបណ្តឹងរដ្ឋប្បវេណីនីមួយៗ ។ សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកមេធាវី ។

**លោក ការ សាវុត្ថ៖**

សូមអរគុណលោកប្រធាន សូមគោរព!

**លោក គង់ ពិសី៖**

សូមអរគុណលោកប្រធាន សូមគោរពលោក លោកស្រីចៅក្រមជាតិ និងអន្តរជាតិទាំងអស់ ។ ខ្ញុំបាទតំណាងឲ្យខាងក្រុមពីរផង ហើយនិងក្រុមបួនផង ។ ហើយជាបឋមខ្ញុំបាទសូមធ្វើការឯកភាពជាមួយនឹងមេធាវីនៅក្នុងក្រុមបីដែលបានលើកឡើងកន្លងរួចមក ហើយជាបន្តទៅទៀតខ្ញុំបានសូមជម្រាបជូនអង្គជំនុំជម្រះបន្ថែមទៀតទាក់ទងទៅនឹងបញ្ហាដែលថា ទំនាក់ទំនងសាច់ញាតិរវាងអ្នកដែលដើមបណ្តឹងរដ្ឋប្បវេណី ហើយនិងជនរងគ្រោះនៅឯមន្ទីរស-២១ វាមានការលំបាកយ៉ាងម៉េចទំនាក់ទំនងនោះ ។

ឧទាហរណ៍ថា យុវជនម្នាក់ដែលមិនមែនជាឧទាហរណ៍ទេ គឺជារឿងជាក់ស្តែងរបស់កូនក្តីរបស់ខ្ញុំបាទដែលឈ្មោះ ដែលមានក្នុងឯកសារ E2/35 គឺថាគាត់មានក្មួយគាត់ ។ ក្មួយគាត់ហ្នឹងបានស្លាប់នៅមន្ទីរស-២១ នោះពិតប្រាកដមែនហើយមានរូបថតទៅទៀតបាទ ដែលមេធាវីខាងការពារបានលើកឡើងជំទាស់ ។ ហើយបញ្ហានេះគឺថា ឪពុករបស់ជនរងគ្រោះនោះបានស្លាប់អស់ ដល់បានស្លាប់អស់អ៊ីចឹងទៅធម្មតាជា--

**ប្រធានអង្គជំនុំ៖**

លោកមេធាវីគប្បីធ្វើការកត់សម្គាល់ជាទូទៅបានហើយ ចំណែកឯការបញ្ហាជាក់ស្តែងនៃករណីដែលនឹងអត្ថាធិប្បាយដោយមេធាវីការពារក្តីនោះ លោកនឹងត្រង់ត្រាប់ចាំស្តាប់នូវបញ្ហា ហើយលោកតបវិញនូវបញ្ហាតាមករណីនីមួយៗ មិនគប្បីលោកយកមួយករណីជាក់ស្តែងជាក់ស្តែងយកមកនេះទេ អានេះជាការសង្កេតជាលក្ខណៈទូទៅប៉ុណ្ណោះ ។

**លោក គង់ ពិសី៖**

បាទ សូមអរគុណលោកប្រធាន ។ បើដូច្នេះខ្ញុំសូមរង់ចាំធ្វើការឆ្លើយតប បាទសូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញអង្គជំនុំជម្រះប្រគល់វេទិកាទៅមេធាវីការពារក្តី ដើម្បីធ្វើការអត្ថធិប្បាយតាមករណីនីមួយៗនៃបញ្ហាដែលមានចំពោះពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ។ សូមអញ្ជើញ ។

**លោក ការ សាវុត្ថ៖**

សូមអរគុណលោកប្រធាន សូមគោរពលោកចៅក្រមជាតិ និងអន្តរជាតិ និងសូមគោរពអង្គសវនាការទាំងមូល ។ ខ្ញុំបាទជាមេធាវីការពារក្តីឲ្យជនជាប់ចោទ ។ ខ្ញុំបាទសូមធ្វើការកត់សម្គាល់សិនមុននឹងលើកចំណុចនីមួយៗមកពិភាក្សា ។ ខ្ញុំបាទសូមធ្វើការកត់សម្គាល់ថា ជនជាប់ចោទបានទទួលស្គាល់ឧក្រិដ្ឋកម្មទាំងអស់នៅស-២១ ដែលមានមនុស្សស្លាប់នៅទីនោះ ១២,៣៨០នាក់ ។

[០៩:៤០:០៦]

អ៊ីចឹង យើងខ្ញុំជាមេធាវីការពារជនជាប់ចោទ រង់ចាំតែទទួលដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់ដែលបានចូលមកប្តឹងតវ៉ា អត់មានប្រកែកទេ ។ ប៉ុន្តែការដែលចូលមកតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនេះ សូមឲ្យត្រឹមត្រូវ ធ្វើឡើងឲ្យត្រឹមត្រូវតាមលក្ខណៈច្បាប់ ។ ទីមួយថា តើគាត់មានគុណសម្បត្តិក្នុងការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីបានឬទេ? ឧទាហរណ៍ បើគាត់ជាប្តី ឬជាប្រពន្ធ ជាកូនបង្កើតជាបងបង្កើតជាប្អូនបង្កើត ជាឪពុកម្តាយ អាហ្នឹងបើឃើញអ៊ីចឹងហើយមេធាវីការពារក្តីចាំតែទទួលទេ ។ ហើយចុះបើគាត់លើកឡើងថា ទេគ្រាន់តែត្រឹមថាក្មួយ ឬមួយក៏ត្រឹមតែថាខ្ញុំមានញាតិមិត្ត មានមិត្តភក្តិប្រាំមួយនាក់ស្លាប់ ។ ហើយអាការស្លាប់នឹងទៀតវាមិនមែនស្លាប់នៅស-២១ មិនដឹងស្លាប់នៅឯណាផងហើយមកលើកដាក់ឲ្យកូនក្តីខ្ញុំទទួល គឺទទួលយកមិនបានទេ ខ្ញុំសូមជម្រាប ។

ទីពីរ ការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ត្រូវមានភស្តុតាងច្បាស់លាស់ថា បុគ្គលដែលស្លាប់នោះ ដែលរងគ្រោះនោះពិតជារងគ្រោះនៅស-២១ ពិតប្រាកដមែន ហើយយើងខ្ញុំមិនទាមទារឲ្យមានឯកសារគ្រប់គ្រាន់ទាំងអស់នោះទេ ។ ក៏ប៉ុន្តែ ក្នុងឯកសារចំណោមឯកសារទាំងអស់ គឺឲ្យវាយ៉ាងហោចណាស់ក៏វាមានមួយ ។ ឧទាហរណ៍ថា ចូលទៅគេថតរូប អ៊ីចឹងវាមានរូបថតបិតលេខនៅហ្នឹង ឲ្យមានរូបថតនៅនឹងទូលស្លែងមកទទួលយកភ្លាម អត់មានប្រកែកទេ ។ ឥឡូវថា រូបថតគេមិនបានថតចុះ ឬក៏វាបាត់ចុះ ន៎ែ! ឲ្យមានចម្លើយសារភាពថា ន៎ែកូនខ្ញុំនេះ ឃើញទេ! ចម្លើយសារភាពនេះ លើកឡើងនេះ! គេទទួលយកហើយ ។ អ្ហ! ឥឡូវបើថាចម្លើយសារភាពក៏វាអត់ទៀត អ៊ីចឹងបញ្ជីឈ្មោះវាមាននៅហ្នឹងតើ! បើសិនណាជា បើរូបថតក៏វាអត់ ចម្លើយសារភាពក៏វាអត់ មានបញ្ជីឈ្មោះមួយនៅហ្នឹង នៅក្នុងហ្នឹងមានឈ្មោះ ។ អ៊ីចឹងវាមានភស្តុតាងមួយនៅក្នុងហ្នឹង ទទួលយកភ្លាម ទទួលយកបាន។ ហើយចុះបើវាគ្មានអីទាំងអស់ ហើយគាត់ចេះតែថា ឲ្យយើងទទួលយកកើតដែរ? នេះត្រង់ហ្នឹងដែលខ្ញុំកត់សម្គាល់នៅក្នុងដើមបណ្តឹងរដ្ឋប្បវេណីមួយចំនួនដែលខ្ញុំបានច្រានចោល ។

ដូច្នេះការកត់សម្គាល់របស់ខ្ញុំមានតែប៉ុណ្ណោះ សូមអរគុណ ហើយសូមឲ្យមេធាវីអន្តរជាតិការពារអន្តរជាតិលើកឡើងពីករណីនីមួយៗ ។

[០៩:៤២:៥០]

**ប្រធានអង្គជំនុំ៖**

អញ្ជើញមេធាវីការពារក្តីអន្តរជាតិ ។

**លោក ហ្វ្រង់ស្វ័រ រូ៖**

សូមអរគុណលោកប្រធាន ។ មុនពេលមេធាវីការពារក្តី កានីហ្សារេស ឡើងឆ្លើយបតលើកឡើងទៅលើករណីនីមួយខ្ញុំសូមធ្វើការលើកសេចក្តីសង្កេតបឋមជាមុន ។ ខ្ញុំសូមអរគុណមេធាវីដើមបណ្តឹងរដ្ឋប្បវេណីដែលគាត់បើកការជជែកទៅលើសេចក្តីសង្កេតបឋមនេះ ដែលវាមានភាពសំខាន់ណាស់សម្រាប់នីតិវិធីរបស់យើង ហើយខ្ញុំក៏សូមអរគុណចំពោះសេចក្តីលើកឡើងរបស់សហព្រះរាជអាជ្ញា ។ ខ្ញុំរីករាយណាស់ដែលសហព្រះរាជអាជ្ញាបានសម្រេចលើកឡើងអន្តរាគមន៍នៅក្នុងដំណាក់កាលនេះ ។ ដោយសារតែយើងបានចូលមកដល់ចំណុចដែលសំខាន់ហើយនៅក្នុងនីតិវិធី និងសេចក្តីថ្លែងរបស់យើង។ យើងបានលើកឡើងហើយថា ជនជាប់ចោទគាត់បានទទួលទៅលើការខុសត្រូវរបស់គាត់ហើយយើងក៏បានលើកឡើងផងដែរថា យើងបើកឲ្យដើមបណ្តឹងរដ្ឋប្បវេណីគាត់ដាក់ពាក្យបណ្តឹងចំពោះជនរងគ្រោះដែលជាប់ទាក់ទងទៅនឹងគាត់ស្លាប់នៅស-២១ ហើយនៅពេលនេះក្នុងនាមមេធាវី ហ្វ្រង់ស្វ័រ រូ ខ្ញុំសូមលើកឡើងថា យើងមានវិធានច្បាប់របស់យើងនៅក្នុងភាសាឡាតាំង គឺយើងថា *ឌ្យូរ៉ា លិក សេដលិក* (dura lex sed lex) គឺច្បាប់របស់យើង វិធានរបស់យើង គឺមានលក្ខណៈតឹងរ៉ឹង ។ ដូច្នេះ យើងមិននៅទីនេះ-- ថាតើយើងត្រូវធ្វើយ៉ាងណាចំពោះច្បាប់ និងបញ្ហាយុត្តិធម៌នោះទេ តែងយើងត្រូវគោរពច្បាប់ ។ *អិនជីអូ* (NGO)គាត់បានធ្វើការទៅលើឯកសារនេះយូរហើយ ហើយវាអាស្រ័យទៅលើអង្គការ *អិនជីអូ* ទាំងអស់នោះដែលគាត់អនុញ្ញាតនិងជំនួយទៅដល់មេធាវីដើមបណ្តឹងរដ្ឋប្បវេណីដើម្បីផលិត និងបង្កើតធាតុផ្សំមួយចំនួនតូច ហើយធាតុផ្សំទាំងអស់នោះវាអាចមានសារសំខាន់ចំពោះអង្គសវនាការដែលឲ្យអង្គសវនាការសម្រេចនៅចុងក្រោយ ថាតើបុគ្គលដើមបណ្តឹងរដ្ឋប្បវេណីជាក់លាក់ទាំងនោះគាត់ពិតជាត្រូវទៅនឹងគុណសម្បត្តិដែលទាមទារក្នុងនាមដាក់ពាក្យជាបណ្តឹងរដ្ឋប្បវេណីដែរឬទេ?

នៅពេលនេះ ខ្ញុំសូមគោរពទាញចំណាប់អារម្មណ៍ពីភាគីទាំងអស់ថានៅក្នុងទីនេះ គឺយើងគឺជាតុលាការអន្តរជាតិដំបូងបំផុតដែលយើងបានទទួលស្គាល់អំពីសិទ្ធិដើមបណ្តឹងរដ្ឋប្បវេណី ។ យើងបាន

ធ្វើការតតាំងក្នុងរយៈពេលដប់ប្រាំឆ្នាំ ដែលដើម្បីឲ្យមក ដល់ស្ថានភាពដែលយើងជួបនៅទីនេះ ។ យើងដឹងហើយជនរងគ្រោះមិនមានសិទ្ធិទេនៅក្នុងតុលាការអន្តរជាតិទាំងឡាយ ហើយយើងបានទទួលជោគជ័យក្នុងការទាមទារឲ្យមានសិទ្ធិនេះ ។ ប៉ុន្តែ យ៉ាងណាក៏ដោយ សូមកុំឲ្យយើងធ្វើឲ្យមានការបំផ្លិចបំផ្លាញទៅលើចំណុចល្អនេះ ។ យើងកុំឲ្យទាត់ចោលទៅលើកិច្ចប្រឹងប្រែងដែលយើងទាមទារឲ្យមានសិទ្ធិដើមបណ្តឹងរដ្ឋប្បវេណីមួយនេះ ។

ដើមបណ្តឹងរដ្ឋប្បវេណីមួយចំនួនកាលពីសប្តាហ៍មុន គឺគាត់ដើរតួនាទីហួស តួនាទីរបស់គាត់ក្នុងនាមជាដើមបណ្តឹងរដ្ឋប្បវេណី ហើយលោកក៏បានធ្វើការលើកឡើងនិង ធ្វើការផ្តល់យោបល់និងជម្រាបទៅដល់ដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់នោះ ។ ហើយនៅពេលនេះយើងកំពុងតែមានការវិវត្តន៍យ៉ាងច្រើននៅក្នុងវិស័យយុត្តិធម៌ព្រហ្មទណ្ឌអន្តរជាតិ ។ ដូច្នេះហើយ យើងត្រូវគោរពទៅតាមការងារទាំងឡាយដែលយើងត្រូវបំពេញឲ្យបានល្អឥតខ្ចោះ ។ ដូច្នេះហើយគឺខ្ញុំសូមជម្រាបមេធាវីដើមបណ្តឹងរដ្ឋប្បវេណីថា វាអាស្រ័យទៅលើ មេធាវីទាំងអស់នោះ ដើម្បីផ្តល់ទៅលើធាតុផ្សំក្នុងលក្ខណៈយុត្តាធិការ ធ្វើយ៉ាងណាឲ្យយើងអាចពិចារណាថា ភាគីមួយចំនួនអាចនិងមិនអាចជាដើមបណ្តឹងរដ្ឋប្បវេណី ។

យើងដឹងហើយថា នៅក្នុងប្រទេសរបស់យើង ប្រទេសកម្ពុជានេះ គឺមានការស្លាប់រាប់ម៉ឺន រាប់ពាន់នាក់ ។ ហើយចំពោះគុកមាន១៩៦ ហើយគ្រួសារមួយចំនួនគាត់អាចយល់ឃើញថា ឪពុក កូនប្រុស ឬក៏បងប្អូនរបស់គាត់ស្លាប់នៅស-២១ ហើយបុគ្គលណាមួយទៀតក៏អាចគាត់យល់ឃើញថាមិនអាចស្លាប់នៅស-២១ អាចស្លាប់នៅមន្ទីរសន្តិសុខផ្សេង ។ អ៊ីចឹង តើយើងត្រូវធ្វើយ៉ាងម៉េចទៅលើករណីទាំងអស់នេះ ។ យើងត្រូវតែព្យាយាមធ្វើការងាររបស់យើងទាំងអស់ ហើយយើងអនុវត្តទៅតាមច្បាប់របស់យើង វិធានរបស់យើងដើម្បីរកយុត្តិធម៌ដូចមេធាវី ការ សាវុត្ត គាត់បានលើកឡើងហើយនៅក្នុងសេចក្តីសង្ខេបបឋមរបស់គាត់ ។ យើងត្រូវធ្វើការគោរពវិធានច្បាប់របស់យើងដែលវាជាផលប្រយោជន៍ច្បាប់និងជាផលប្រយោជន៍របស់ដើមបណ្តឹងរដ្ឋប្បវេណី ។ ដូច្នេះ ដោយសារតែនៅក្នុងពេលអនាគត គឺយើងមានបំណងជំរុញឲ្យមានការវិវឌ្ឍន៍មួយ ដែលដូចទៅនឹងការវិវឌ្ឍន៍របស់យើងនៅក្នុងតុលាការរបស់យើងនេះ ។

លោក លោកស្រី ចៅក្រមជាទីគោរព! មេធាវីការពារក្តី គឺគាត់ផ្តល់បញ្ជីទាក់ទងទៅនឹងដើមបណ្តឹងរដ្ឋប្បវេណីនីមួយៗហើយ ។ នៅពេលនេះ គឺយើងបានទទួលធាតុផ្សំផ្សេងៗទៀតទាក់ទងទៅនឹងភស្តុតាង ហើយយើងអាចត្រូវគិតគ្នា និងគោរពទៅតាមការសង្កេតរបស់ចៅក្រម ខាងរាយថ៍ នៅពេល

ដែលយើងពិភាក្សាដេញដោលនេះ គឺមានធាតុផ្សំលេចឡើងរហូត ។ ដូច្នេះហើយគឺយើងត្រូវតែឆ្លើយតប នៅគ្រប់ពេល និងនៅចុងបញ្ចប់ ។ ហើយជាជាងរាល់ការលើកឡើងអ្វីដែលយើងបានលើកឡើងម្សិល មិញហើយនោះ ប្រហែលជាយើងអាចស្នើសុំឲ្យមេធាវី កានីហ្សារេស សុំឲ្យផ្តល់បច្ចុប្បន្នភាពទាក់ទង ទៅនឹងបញ្ជីនោះ ។ ថាតើឲ្យលោកស្រីនោះគាត់ជម្រាបទៅថាតើរឿងក្តីណាខ្លះ ករណីណាខ្លះដែលយើង បានទទួលព័ត៌មានកាលពីម្សិលមិញ ហើយអង្គជំនុំជម្រះនឹងសម្រេចនៅដំណាក់កាលចុងក្រោយ ។ ហើយព័ត៌មានដែលយើងទទួលបានកាលពីម្សិលមិញយើងអាចជម្រាបថា ករណីមួយចំនួននោះមានភាព សង្ស័យដោយផ្អែកទៅលើភស្តុតាងនិងករណីមួយចំនួន ។ ដូច្នេះ ខ្ញុំសូមថ្លែងអំណរគុណ ហើយសូម អនុញ្ញាតឲ្យផ្តល់វេទិកាទៅដល់មេធាវី កានីហ្សារេស ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកស្រីមេធាវី ។

[០៩:៥០:៤២]

**លោកស្រី ម៉ារីប៉ូល កានីហ្សារេស៖**

សូមអរគុណលោកប្រធាន ។ ជាការពិតដូចដែលមេធាវី ហ្វ្រង់ស្វ័រ រូ បានលើកឡើងជូនអង្គ សវនាការ ។ ឯកសារថ្មីបានបង្កើតឡើងដោយដើមបណ្តឹងរដ្ឋប្បវេណីពីក្រុមទីមួយ ដែលកាលពីម្សិល មិញបានផ្តល់ឯកសារថ្មីជូនយើងខ្ញុំទាក់ទងទៅនឹងអ្នកតាំងខ្លួនចំនួនប្រាំរូប ។ ព្រឹកមិញនេះ ក្រុមទីបីបាន ផ្តល់ឯកសារមួយចំនួនជាក់លាក់ទាក់ទងទៅនឹងដើមបណ្តឹងរដ្ឋប្បវេណីមួយចំនួន ។

លោក លោកស្រី ចៅក្រម លោកប្រធានជាទីគោរព! ប្រសិនបើអនុញ្ញាតគឺខ្ញុំសូមអាចធ្វើការ ធ្វើសេចក្តីសង្កេតបឋមទាក់ទងទៅនឹងបញ្ហានេះផងដែរ ។

[០៩:៥១:៤៧]

អង្គជំនុំជម្រះជ្រាបហើយ ជ្រាបយ៉ាងច្បាស់ថា នៅពេលដែលព្រឹកមិញមុនពេលដែលយើងចាប់ ផ្តើមសវនាការរបស់យើង គឺមានឯកសារថ្មីដែលយើងទទួលបាន ។ ដូច្នេះហើយយើងត្រូវការពេលវេលា ដើម្បីធ្វើការវាយតម្លៃទៅលើភស្តុតាង ហើយយើងដឹងហើយសវនាការយើងបានដំណើរការហើយ ឯកសារទាំងអស់នោះយើងមាន ។ ហើយខ្ញុំសូមលើកឡើងបញ្ជាក់ថា ខ្ញុំមិនមានពេលគ្រប់គ្រាន់ដើម្បី ពិនិត្យទៅលើឯកសារទាំងនោះទេ ។ ហើយជាពិសេសនោះ គឺខ្ញុំមិនអាចធ្វើការពិភាក្សាជាមួយនឹងកូនក្តី របស់ខ្ញុំអំពីបញ្ហាដែលពាក់ព័ន្ធទៅនឹងឯកសារថ្មីទាំងអស់នោះ ។

ជាការពិតខ្ញុំយល់ឃើញថា ខ្ញុំនឹកឃើញអំពីសេចក្តីសង្កេតដែលខ្ញុំលើកឡើងកាលពីរសៀលម្សិលមិញ ដែលសេចក្តីសង្កេតនោះលើកឡើងដោយមេធាវីដើមបណ្តឹងរដ្ឋប្បវេណីក្រុមមួយដែលគាត់បញ្ជាក់ថា វាអាស្រ័យទៅលើមេធាវីការពារក្តីនៅក្នុងដំណាក់កាលសវនាការបឋម ឲ្យលើកឡើងសេចក្តីសង្កេតទាក់ទងទៅនឹងពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ។ ការសង្កេតរបស់ខ្ញុំឆ្លើយតបទៅនឹងបញ្ហានេះ គឺអាចជាបញ្ហាដែលថាលោកប្រើពាក្យមួយចំនួនដែលលោក អាឡាំង វែនណឺ បានប្រើប្រាស់នោះ។ ហើយអង្គជំនុំជម្រះគាត់បានយល់ហើយទៅលើបញ្ហានោះ មានការលំបាកណាស់នៅក្នុងដំណាក់កាលសវនាការបឋម ។ ហើយនៅពេលនោះឯកសារមួយចំនួនមិនមានបង្កើតនៅឡើយទេ ហើយវាមានលក្ខណៈពិបាកនៅក្នុងការបង្ហាញអំពីជំហរជាក់លាក់របស់មេធាវីការពារក្តីទាក់ទងទៅនឹងពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ។

នៅក្នុងករណីណាក៏ដោយ ដោយពិចារណាទៅលើធាតុផ្សំដែលយើងទទួលបានកាលពីម្សិលមិញនៅចុងសវនាការរបស់យើង គឺឯកសារមួយចំនួនគឺបានបង្កើតដោយឡែកជាភាសាខ្មែរ ។ ហើយមិនមានការបកប្រែជាភាសាអង់គ្លេស ឬក៏ជាភាសាបារាំងនោះទេ ។ ដូច្នេះហើយយើងមិនអាចយកឯកសារទាំងនោះមកពិចារណា ។ ទាក់ទងនឹងដើមបណ្តឹងរដ្ឋប្បវេណីពីររូបនៅក្នុងក្រុមទីមួយ ។ ហើយឯកសារទាំងអស់នោះឲ្យយើងអាចបញ្ជាក់ជំហរ និងបង្ហាញរបស់យើងថា យើងពុំមានការតវ៉ាទៅលើដើមបណ្តឹងរដ្ឋប្បវេណី ពីររូបនោះទេ គឺ D25/20 ហើយនិង E2/57 ។ ប៉ុន្តែ យើងនៅតែរក្សាជំហរតវ៉ារបស់យើងចំពោះដើមបណ្តឹងរដ្ឋប្បវេណីដទៃទៀត ។ ដោយការរក្សានូវសិទ្ធិរបស់យើងកាលពីលើកមុនទាក់ទងទៅនឹងឯកសារផ្សេងៗដែលបង្ហាញជូនយើងកាលពីព្រឹកមិញ ។

[០៩:៥៦:៥៧]

**ប្រធានអង្គជំនុំ៖**

មេធាវីការពារតើមានតែដើមបណ្តឹងរដ្ឋប្បវេណីតែពីរ គឺD25/20 និងE2/57 តែពីរហ្នឹងទេដែលថា មេធាវីដកនូវការជំទាស់តវ៉ារបស់ខ្លួន?

*(មានបញ្ហាសំឡេង)*

ពីតុលាការអត់មានបក អត់ឮផង ឮម្តងឮខ្សោយ ម្តងឮខ្លាំង ម្តងឮ ម្តងអត់ឮអ៊ីចឹងដំណើរការសវនាការម៉េចទៅឥឡូវនេះ?

តែពីហ្នឹងទេ គឺ D25/20 ហើយនិង E2/57 ដែលធ្វើការដកការជំទាស់តវ៉ានោះ?

**លោកស្រី ម៉ារីប៉ូល កានីហ្សារេស៖**

ដោយពិចារណាទៅលើឯកសារ ដែលបានបង្កើតកាលពីល្ងាចម្សិលមិញមេធាវីការពារក្តីមិនមានអ្វីតវ៉ាទៅលើដើមបណ្តឹងរដ្ឋប្បវេណីពីររូបនោះទេ ។ គឺខ្ញុំសូមលើកឡើងវិញ គឺD25/20 និង E2/57 ដែលខ្ញុំពុំមានការជំទាស់តវ៉ាទៀតទេ ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញ ។

**លោក អាឡាំង វែនណឺ៖**

សូមជម្រាបសួរ សូមគោរពលោក លោកស្រីចៅក្រម! ខ្ញុំមានពាក្យមួយចំនួនគឺ D25/20 ហើយនិង E2/57 សូមអរគុណមេធាវីការពារដែលមេធាវីបានពិនិត្យដោយប្រុងប្រយ័ត្ន ហើយនិងផ្តល់ពីជំហរក្នុងការសម្រេចអំពីកាយវិការនេះ ហើយខ្ញុំសូមជម្រាបអង្គជំនុំជម្រះថាតាមពិត យើងខ្ញុំស្នើដាក់ពាក្យសុំការបកប្រែឯកសារនេះ ដើម្បីដាក់ក្នុងឯកសារសំណុំរឿងហើយនៅពេលដែលយើងបានទទួលហើយយើងអាចនឹងចែកជូនទៅមេធាវីការពារទៀត ។ ហើយសូមអរគុណមេធាវីការពារហើយយើងនឹងធ្វើការងារមួយចំនួនដើម្បីបំពេញបែបបទនីតិវិធីហើយឲ្យមានការបកប្រែនូវឯកសារទាំងអស់នោះ សូមអរគុណ ។

[១០:00:00]

**ប្រធានអង្គជំនុំ៖**

មេធាវីការពារឡើងអត្ថាធិប្បាយបន្ត ។ មានបញ្ហាអីទៀតហើយ? ហើយសូម-- ជារឿងចុងក្រោយណ៎ា ពីព្រោះត្រូវវេទិកានៃការពិភាក្សា ហើយបើនិយាយអ្វីនិយាយឲ្យអស់ ។ មិនដដែលទេ បើថាជាដដែលចុះឡើងហ្នឹង គឺកិច្ចការដែលត្រូវធ្វើជជែកវែកញែកអំពីសារធាតុ នោះគឺអត់អាចដំណើរការបានទេ ។ នេះជាចុងក្រោយហើយ ។

**លោកស្រី ហ្សាប៊ីយ៉ែន ទ្រូស្សណាព្រូស៖**

សូមអរគុណលោកប្រធាន ។ ខ្ញុំសូមជម្រាបជូនអង្គជំនុំជម្រះថា តាមពិតយើងបានដាក់ជូននូវឯកសារថ្មី ទៅខាងមេធាវីការពារ ហើយតាមពិតឯកសារទាំងអស់នេះត្រូវបានរៀបចំឡើង រួចហើយយើងបានត្រៀមខ្លួននូវពាក្យសុំដែលត្រូវនឹងដាក់ជូនស្របជាមួយនឹងវិធាន ដែលមានចែងរបស់តុលាការ។ ប៉ុន្តែជាថ្មីម្តងទៀតយើងចង់បានចំណុចមួយដែលថា ពាក្យសំណើនេះត្រូវបានលើកតទល់នៅថ្ងៃនេះ គឺ

ថាមេធាវីការពារបានលើកទទួលឯកសារហើយ ដើម្បីយ៉ាងម៉េចយើងអាចនឹងធ្វើបាន គោរពទៅតាមគោលការណ៍តទល់គ្នាបាន ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញមេធាវីការពារក្តី ។ សូមចាប់ផ្តើមនូវការបង្ហាញនូវហេតុផលទាំងឡាយនៃការតវ៉ារបស់ខ្លួនតាមករណីនីមួយៗ ។ ហើយមេធាវីតំណាងឲ្យដើមបណ្តឹងរដ្ឋប្បវេណី គឺត្រូវគ្រាប់ស្តាប់នូវបញ្ហាហើយឆ្លើយតប មិនអនុញ្ញាតឲ្យតបច្រើនដងទេ ក្នុងករណីមួយឲ្យតបតែម្តងទេ អ៊ីចឹងតៀមឲ្យហើយនូវលក្ខណៈសម្បត្តិ នូវឯកសារ នូវភស្តុតាងនានា ដើម្បីតបក្នុងករណីបង្ហាញនូវឯកសារបន្ថែមផ្សេងទៀតដែលបំពេញថ្មី គឺអនុញ្ញាតឲ្យមេធាវីការពារក្តី តបតែម្តងវិញតែប៉ុណ្ណោះ ។

អំមិញដូចជាបានប្រាប់ហើយ ថាជាលើកចុងក្រោយ ហើយមានបញ្ហាអីទៀត?

លោកស្រីមេធាវីគួរពិចារណាឡើងវិញមើល៍ រៀបគំនិតឲ្យហើយ ថាខ្លួនត្រូវការចំណាយពេលប៉ុន្មាននិយាយបញ្ហាអ្វីខ្លះ? និយាយឲ្យអស់ពីព្រោះវេទិកានេះ យើងបានប្រកាសតាំងពីព្រឹកមិញជាវេទិកាត្រូវបង្ហាញនូវហេតុផលនៃការតវ៉ាជំទាស់របស់ភាគីមេធាវីការពារក្តី ចំពោះបញ្ហាដែលមាន ។ ហើយអស់លោក លោកស្រីជាមេធាវីតំណាងឲ្យដើមបណ្តឹងរដ្ឋប្បវេណីធ្វើការបង្ហាញនូវហេតុផលដើម្បីគាំទ្រនូវពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់កូនក្តីរបស់ខ្លួន ។ ហើយព្រឹកមិញគឺសុំធ្វើការកត់សម្គាល់ឥឡូវហ្នឹងការកត់សម្គាល់គឺមួយម៉ោងជាងហើយ ។ ហើយហាក់ដូចជាបញ្ហាដដែល វាអត់មានបញ្ហាអីថ្មីសោះ ដែលនាំឲ្យកើតឡើងនូវបញ្ហាលើកឡើងម្តងហើយម្តងទៀត ។ នេះជាលើកចុងក្រោយ ។

[១០:០៣:៤៩]

**លោកស្រី ហ្សាប៊ីយ៉ែន ទ្រូស្សណាព្រូស៖**

សូមគោរពលោកប្រធាន! ហ្នឹងគឺជាបញ្ហាបច្ចេកទេសទេដែលខ្ញុំលើកឡើង ដោយហេតុថាអ្វីដែលយើងគិតគួរនៅក្នុងមេធាវីដើមបណ្តឹងរដ្ឋប្បវេណីនោះ យើងបានពិចារណាថាតើតុលាការនឹងទទួលយកសំណើនេះឬអត់? ហើយមេធាវីការពារគប្បីបញ្ជាក់ពីការជំទាស់របស់ខ្លួន អំពីក្រុមមួយ ក្រុមពីរក្រុមបី ហើយខ្ញុំមិនទាន់ដឹងថាតើអង្គជំនុំជម្រះសម្រេចយកវិធីណាមួយ ។ យើងខ្ញុំស្នើថា សុំឲ្យអង្គជំនុំជម្រះមេត្តាពិចារណា ហើយខ្ញុំសុំឲ្យអង្គជំនុំជម្រះមេត្តាសម្រេច អំពីលំដាប់លំដោយនៃការជំទាស់តវ៉ារបស់មេធាវីការពារ ។

**ប្រធានអង្គជំនុំ៖**

ឥឡូវនេះយើងមិនបានរៀបចំបញ្ហាហ្នឹងទេ ហើយម្សិលមិញនេះគឺមានការបង្ហាញនូវលំដាប់នៃការជំទាស់តវ៉ារបស់ខ្លួនរួចហើយ។ ដូច្នេះ អង្គជំនុំជម្រះសម្រេចតាមនេះធ្វើជាមូលដ្ឋាន ហើយករណីនីមួយៗដែលដើមបណ្តឹងរដ្ឋប្បវេណីណាដែលមានបញ្ហាគឺសុំមេធាវីដើមបណ្តឹងរដ្ឋប្បវេណីក្រុមនោះ គឺត្រូវគ្រាប់នូវបញ្ហា ហើយលើកមកជជែកពិភាក្សាតវ៉ាចំពោះការបង្ហាញហេតុផលទាំងឡាយនៃការជំទាស់របស់មេធាវីការពារក្តី ។ សូមអញ្ជើញ ។

**លោកស្រី មារីប៉ូល ការនីហ្សាវេស៖**

សូមគោរពលោកប្រធាន ។ ខ្ញុំស្នើថា យើងគប្បីត្រឡប់ទៅតាមលំដាប់ ដែលខ្ញុំបានជូនពីម្សិលមិញ ដើម្បីពិនិត្យមើលបញ្ជីនេះ ពីព្រោះអង្គជំនុំជម្រះបានឯកភាពទៅតាមលំដាប់លំដោយ ដែលខ្ញុំបានស្នើលើកឡើងនោះ ។

ដើមបណ្តឹងរដ្ឋប្បវេណីទីមួយនោះ ដែលយើងបាននិយាយពីម្សិលមិញនោះគឺ E2/22 មេធាវីការពារបានចង្អុលបង្ហាញថា ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ គឺអ្នកដាក់ពាក្យបណ្តឹង គឺ ស៊ី តាឈឹម នោះបានដាក់ពាក្យ ឈឹម ស៊ីថា បានដាក់ពាក្យអំពីការចាប់ខ្លួននៃ ដែលថាជនម្នាក់ជាអតីតយោធាខ្មែរក្រហម ហើយដើមបណ្តឹងរដ្ឋប្បវេណីបញ្ជាក់ថា ទំនាក់ទំនងជាមិត្តភក្តិ ហើយមិនមានអ្វីក្រៅពីហ្នឹងនៅក្នុងសំណុំរឿង នៅក្នុងករណីដើម្បីបង្ហាញទំនាក់ទំនងរវាងដើមបណ្តឹងរដ្ឋប្បវេណីហើយនិងជនរងគ្រោះ ។ ហើយក៏មិនមានទំនាក់ទំនងអ្វីអំពីជនរងគ្រោះទៅនឹងស-២១ ។ អ៊ីចឹងហើយខ្ញុំបានផ្តល់សេចក្តីសង្កេតជាបឋមដែលធ្វើឡើងដោយលោកមេធាវី ការ សាវុត្ថ និង ហ្វ្រង់ស្វ័រ រូ នោះ ។

[១០:០៨:១០]

ដូច្នេះ អាស្រ័យទៅលើដើមបណ្តឹងរដ្ឋប្បវេណីជាអ្នកត្រូវបង្ហាញភស្តុតាងអប្បបរមា ដើម្បីឲ្យអង្គជំនុំជម្រះអាចនឹងធ្វើសេចក្តីសម្រេចថា ជននោះខ្លួនមានគុណសម្បត្តិអាចជាដើមបណ្តឹងរដ្ឋប្បវេណីបានឬមិនបាននោះ ។ ហើយយើងជឿជាក់ថា នៅក្នុងករណីមួយនេះ ចំពោះរឿងសាច់ញាតិ ឬក៏អង្គហេតុថាជនរងគ្រោះអាចត្រូវបាន ឬមិនត្រូវបានឃុំខ្លួននៅស-២១ យើងករណីក្នុងករណីនេះ គឺមិនមានធាតុផ្សំភស្តុតាងណាមួយដែលអនុញ្ញាតឲ្យយើងអាចនឹងពិចារណាថា ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះមានគុណសម្បត្តិ ឬក៏មានលទ្ធភាពនឹងតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនោះទេ ។

**ប្រធានអង្គជំនុំ៖**

មេធាវីតំណាងឲ្យដើមបណ្តឹងរដ្ឋប្បវេណីក្រុមពីរ ឈឹម ស៊ីថា គឺជាដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងក្រុមពីរ ។ សូមអញ្ជើញមេធាវី ។

**លោក គង់ ពិសី៖**

សូមអរគុណលោកប្រធាន ។ ចំពោះបញ្ហានេះ ខ្ញុំបាទសូមអនុញ្ញាតលោកប្រធាន ដើម្បីរក្សាសិទ្ធិនៅក្នុងការបង្ហាញភស្តុតាងជាក្រោយទៀត ប្រសិនណាជាលោកប្រធានត្រូវការនៅថ្ងៃណាមួយ ។ បាទសូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

ដំណើរការសវនាការ ដូចជាការដេញដោលគិតដល់ទីបញ្ចប់ហើយ ហើយមកសួរថាតើអង្គជំនុំជម្រះត្រូវការភស្តុតាងនៅពេលណា ដូចជាចម្លែកដែរ ។ មេធាវីការពារក្តីបានទទួលសិទ្ធិតំណាងឲ្យដើមបណ្តឹងរដ្ឋប្បវេណី ដូចចេះតែច្រើនខែ ច្រើនឆ្នាំមកហើយ បើគិតជាឆ្នាំ ពីរឆ្នាំទៅហើយ តាំងពី២០០៨មករហូតដល់ ២០០៩ ជិតដល់ដាច់ ២០០៩ សវនាការគេជិតចប់ហើយ ហើយបើថាដាក់ភស្តុតាងដល់ថ្ងៃណា នេះយើងឆ្ងល់ដែរ ។

ជាកាតព្វកិច្ច ជាភារកិច្ចរបស់មេធាវីការពារក្តី ត្រូវប្រឹងប្រែងនៅក្នុងគ្រប់ដំណាក់កាលទាំងអស់ដើម្បីប្រមែប្រមូលភស្តុតាង ហើយដាក់មកអង្គជំនុំជម្រះហើយបញ្ជូនទៅភាគីដើម្បីឲ្យភាគីគេធ្វើការសិក្សាស្វែងយល់ អំពីហេតុផលទាំងឡាយ និងឯកសារភស្តុតាងនានា ដើម្បីមានការឆ្លើយតប ។

[១០:១០:៣០]

ហើយទើបមកដល់ថ្ងៃនេះ ទើបមកដល់តែថាត្រូវការថ្ងៃណា? ថ្ងៃឱសានវាទនៃការចុងក្រោយគឺអង្គជំនុំជម្រះបានជម្រាបរួចហើយ ។ អង្គជំនុំជម្រះមិនជម្រាបទៀតទេ អំពីភស្តុតាងឯកសារនានាដែលមាន ហើយការដាក់នេះគឺដាក់ឯកសារចាស់ដែលមានស្រាប់នៅក្នុងសំណុំរឿង ។ ដូចជាបានប្រកាសកាលពីម្សិលមិញថ្មីៗទេ អ៊ីចឹងឱកាសចុងក្រោយនៃបញ្ហាដែលមាន គឺត្រូវចប់នៅពេលដែលអង្គជំនុំជម្រះបិទការពិភាក្សាដេញដោល ។

នេះគឺជានីតិវិធីដែលមានចែងនៅក្នុងវិធាន ក៏ដូចជានៅក្នុងច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ក៏ដូចជានីតិវិធីរដ្ឋប្បវេណីកម្ពុជាដែលបានចែងច្បាស់លាស់អំពីនីតិវិធីនៃការដាក់ឯកសារនៃការបង្ហាញនូវហេតុផល ដែលភស្តុតាងនានានេះ ។

អញ្ជើញតទៀត មេធាវីការពារក្ដី ។

**លោកស្រី មារីប៉ូល កានីហ្សារេសះ**

ទាក់ទងទៅនឹងករណីមួយខាងក្រោមនេះ E2/37 នៅក្នុងករណីនេះដែរ យើងក៏ប្រឈមមុខជំទាស់ដូចនឹងករណីខាងកដើមដែរ ព្រោះដើមបណ្ដឹងរដ្ឋប្បវេណី គឺសំដៅថាមានមិត្តភក្ដិប្រាំមួយនាក់ ដែលជាជនរងគ្រោះនៅស-២១ ត្រូវគេសម្លាប់នៅទីនោះ ។ ហើយយើងមិនមានភស្តុតាង អំពីទំនាក់ទំនងសាច់សាលោហិត រវាងជនរងគ្រោះទៅនឹងអ្នកដាក់ពាក្យសុំទេ ។ ហើយយើងក៏មិនមានឯកសារអ្វីនៅក្នុងសំណុំរឿងដែលបង្ហាញថា ជនរងគ្រោះទាំងនេះ មានពាក់ព័ន្ធអ្វីទៅនឹងស-២១នោះទេ ។

**ប្រធានអង្គជំនុំ៖**

មេធាវីតំណាងឲ្យដើមបណ្ដឹងរដ្ឋប្បវេណីក្រុមបី ។

**លោកស្រី ហ្សាប៊ីយ៉ែន ទ្រូស្សូណាព្រូសះ**

លោកប្រធានជាទីគោរព! ក្នុងករណីនេះ ដែលគាត់ដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ពីព្រោះថាគាត់បានឃើញមិត្តភក្ដិរបស់គាត់ត្រូវបានគេចាប់ខ្លួន ហើយនាំខ្លួនយកទៅទួលស្លែង ។ ហើយនៅក្នុងករណីមួយនេះ តាមពិតពួកគាត់ជាមិត្តភក្ដិនឹងគ្នា ហើយគាត់បានអះអាងថា គាត់មាន១ការភ័យខ្លាច ហើយគាត់មានការឈឺចាប់យ៉ាងខ្លាំង នៅពេលដែលគាត់បានដឹងពីជោគវាសនារបស់មិត្តភក្ដិរបស់គាត់នោះ ។ អ៊ីចឹង ខ្ញុំយោងទៅរកសេចក្ដីអង្កេតបឋមរបស់ខ្ញុំអំពីសញ្ញាណនៃទំនាក់ទំនងជិតស្និទ្ធរវាងបុគ្គលនិងបុគ្គលដែលថា បើសិនថាជននោះមានការឈឺចាប់ មានទុក្ខសោក ដោយសារការបាត់បង់មិត្តភក្ដិនោះ ទំនាក់ទំនងនោះគឺអាចជាលក្ខខណ្ឌមួយដែលធ្វើឲ្យគាត់មានសិទ្ធិ ។ យើងនិយាយអំពីបុគ្គលដែលថា គាត់មានវ័យចំណាស់ យើងមិនអាចមានទំនាក់ទំនងជាមួយគាត់ឲ្យបានស្រួលទេ គាត់នៅក្នុងតំបន់ដាច់ស្រយាល គឺថាឆ្ងាយជាងរតនគីរីទៀត យើងពិបាកនឹងទាក់ទងគាត់ អាយុរបស់គាត់ក៏មិនអនុញ្ញាតឲ្យគាត់ចូលរួមនៅក្នុងការពិភាក្សាលំអិតវែងឆ្ងាយនោះដែរ ។

ដូច្នេះ ខ្ញុំសូមអនុញ្ញាតអង្គជំនុំជម្រះមេត្តាពិចារណាក្នុងករណីជាក់លាក់មួយនេះ ដើម្បីធ្វើសេចក្ដីសម្រេចទៅតាមករណី និងភស្តុតាងដែលយើងមាន ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញមេធាវីការពារក្ដីបន្ត ។

**លោកស្រី មារីប៉ូល កានីហ្សារេស៖**

ពាក់ព័ន្ធនឹង E2/66 អ្នកដាក់ពាក្យសុំបានបញ្ជាក់ថា បងស្រីរបស់គាត់ ពេញ សុខេន ត្រូវបានគេឃុំខ្លួននៅស-២១ ។ យើងពិនិត្យឃើញថា ពេញ សុខេន ដែលថាអនុលោមទៅតាមលោក កាំង ហ្គេកអ៊ាវ គឺ សុភាព, ពេញ សុភាព នោះ គឺជាកូនស្រីរបស់ វន វ៉េត ទេ ប៉ុន្តែអ្នកដាក់ពាក្យសុំបញ្ជាក់ថា នាមត្រកូលរបស់គាត់ឈ្មោះ ពេញ នោះ គឺថាហៅ ជិន ថន គឺជាអ្នកម្តាយ ។ ដូច្នេះ យើងពិនិត្យមើលថា វាអាចនឹងមានឈ្មោះស្រដៀងគ្នា ដែលធ្វើឱ្យអ្នកដាក់ពាក្យសុំយល់ថា ជាឈ្មោះបងស្រីរបស់ខ្លួន ជាឈ្មោះរបស់ជនដែលអាចនឹងត្រូវឃុំខ្លួននៅស-២១ ។ ប៉ុន្តែ នៅក្នុងពាក្យសុំរបស់ដើមបណ្តឹងរដ្ឋប្បវេណីនេះ គឺមិនបានបង្ហាញអំពីបញ្ជីឈ្មោះជនរងគ្រោះដែលមាននៅក្នុងមន្ទីរស-២១ ដែលខ្លួនលើកឡើងនោះទេ ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញ មេធាវីតំណាងឱ្យដើមបណ្តឹងរដ្ឋប្បវេណីក្រុមពីរ ។

**លោក គង់ ពិសី៖**

សូមអរគុណ លោកប្រធាន ។ ហើយចំពោះបញ្ហា ពេញ សុខេន នេះ ។ គាត់មានបងស្រីរបស់គាត់ហ្នឹង ពិតប្រាកដមែន ។ ពីព្រោះថា នៅពេលដែលគាត់បានទៅពិនិត្យនៅកន្លែងមន្ទីរទួលស្លែងទៅគាត់បានឃើញរូបថតរបស់បងស្រីរបស់គាត់នៅទីនោះ ។ ហេតុនេះហើយ បានជាគាត់សំអាង មិនមានសំអាងទៅលើឈ្មោះ ដែរថាស្រដៀងគ្នានេះ គឺសំអាងទៅលើរូបថតផងបាទ ។ នេះសូមបញ្ជាក់ជូនអង្គជំនុំជម្រះមេត្តាជ្រាប ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញមេធាវីការពារក្តីបន្តទៀត ។

**លោកស្រី ម៉ារីប៉ូល កានីហ្សារេស៖**

ទាក់ទងទៅនឹងដើមបណ្តឹងរដ្ឋប្បវេណី D25/15 មេធាវីការពារបញ្ជាក់ថា ដើមបណ្តឹងរដ្ឋប្បវេណីមិនបានបញ្ជាក់ពីទំនាក់ទំនងសាច់ញាតិជាមួយនឹងជនរងគ្រោះទេ ។ ហើយមិនបានដាក់បញ្ចូលនៅក្នុងសំណុំរឿងនូវភស្តុតាងមួយចំនួនដែលអាចឱ្យយើងជឿថា មានទំនាក់ទំនងរវាងជនរងគ្រោះទៅនឹងស-២១ ។ អ៊ីចឹងហើយមេធាវីដើមបណ្តឹងរដ្ឋប្បវេណីបានផ្តល់ឯកសារបន្ថែមទៀត ប៉ុន្តែឯកសារបន្ថែមនោះ ពិនិត្យមើលទៅមិនឃើញមានទំនាក់ទំនងអ្វីដែលមាន ដែលដាក់បញ្ចូលរួចទៅហើយនោះទេ ។

អ៊ីចឹងភស្តុតាងដែលយើងឃើញនៅក្នុងករណីនេះ គឺទាក់ទងទៅនឹងព័ត៌មានទាក់ទងទៅនឹងប្រវត្តិរូប ដែលបានចងក្រងឡើង ដោយទាក់ទងជនរងគ្រោះដោយនិយាយអំពីឈ្មោះ ពិន អ៊ឹម នោះ-- ប៉ែន អ៊ឹម គឺថាមិនមែនដកស្រង់ចេញមកពីស-២១ នោះទេ ។

[១០:១៨:២៥]

**ប្រធានអង្គជំនុំ៖**

អញ្ជើញមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្រុមមួយ ។

**កញ្ញា ទី ស្រ៊ីនណា៖**

សូមគោរពលោកប្រធាន និងនាងខ្ញុំសូមធ្វើការឆ្លើយតបជាមួយនឹងមេធាវីការពារ ។ ទាក់ទងទៅនឹងកូនក្តីនាងខ្ញុំ ដែលមានអត្តសញ្ញាណ D25/15 នេះ ដែលមានឈ្មោះ សួន សៀង ហ្នឹង តាមការសម្ភាសន៍ជាមួយគាត់ជាក់ស្តែង គាត់បានជម្រាប ហើយបញ្ជាក់បន្ថែមទៀតថា ទាក់ទងឈ្មោះ ប៉ែន អ៊ុំ ហ្នឹង គឺត្រូវជាបងប្អូនជីដូន ពុំមែនជាបងប្អូនបង្កើតទេ ។ ដូច្នេះ ទាក់ទងទៅនឹងចំណុចហ្នឹង យើងឃើញថា នៅក្នុងឯកសារដែលពាក់ព័ន្ធនឹងនៅក្នុងមន្ទីរស-២១ យើងមានប្រវត្តិរូបស្តីអំពីប្រវត្តិរូបរបស់គាត់ ។

ទីមួយ គឺជាប្រវត្តិរូបរបស់គាត់ ដែលមាននៅក្នុងមន្ទីរស-២១ ។ គឺនៅក្នុងឯកសារហ្នឹង គឺបានសរសេរនៅក្បាលបញ្ជីនេះ ដាក់ថាមន្ទីរស-២១ ភ្នំពេញ ។ នេះគឺជាអត្តសញ្ញាណមួយដែលបង្ហាញថា គាត់មានឯកសារមួយនៅក្នុងមន្ទីរស-២១ ។

ហើយចំណុចមួយទៀត ឈ្មោះ ប៉ែន អ៊ុំ ហ្នឹងដែរ ក៏មាននៅក្នុងបញ្ជីកម្ទេច ចុះថ្ងៃទី១៥ ខែ១០ ឆ្នាំ១៩៧៧ ។ ឯកសារដែលទាក់ទងទៅនឹងបញ្ជីកម្ទេចនេះ គឺខាងក្រុមមេធាវីយើងខ្ញុំបានស្រាវជ្រាវតាមប្រព័ន្ធអ៊ីនធឺណេត ទាក់ទងទៅនឹង*ដេតាបេស* (database) របស់មជ្ឈមណ្ឌលឯកសារកម្ពុជា។ ហើយយើងខ្ញុំក៏បានរកបន្ថែម ហើយយើងក៏បានកឺបបញ្ចូលដែរ ប៉ុន្តែយើងខ្ញុំនឹងធ្វើការប្រគល់ជូនមេធាវីការពារនៅពេលក្រោយ បន្ទាប់ពីមានការឈប់សម្រាក យើងខ្ញុំនឹងប្រគល់ជូនដើម្បីបញ្ជាក់បន្ថែមថា ឯកសារហ្នឹង គឺយើងរកឃើញនៅក្នុងប្រព័ន្ធអ៊ីនធឺណេត ដែលមាននៅក្នុងវេបសាយ របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ។ នេះគឺជាចំណុចមួយដែលបញ្ជាក់ពីអត្តសញ្ញាណរបស់កូនក្តីនាងខ្ញុំ ដែលនៅក្នុងមន្ទីរស-២១ ។

ដោយឡែក ទាក់ទងទៅនឹងអត្តសញ្ញាណរបស់ដើមបណ្តឹងរដ្ឋប្បវេណីផ្ទាល់ ដែលមានឈ្មោះ ស៊្វន សៀង ។ ស៊្វន សៀង គឺគាត់បានបញ្ជាក់បន្ថែមហើយថា គឺត្រូវជាបងប្អូនជីដូនមួយរបស់ឈ្មោះ ប៉ែន អ៊ុំ ហើយនៅក្នុងហ្នឹង ស៊្វន សៀង ក៏បានប្រគល់អត្តសញ្ញាណប័ណ្ណគាត់ដែលមាននៅក្នុងអំឡុង

ពេលបច្ចុប្បន្ន ។ ពីព្រោះថាទាក់ទងទៅនឹងឯកសាររបស់គាត់ ដែលមានកាលពីសម័យ-- គាត់ជាបុគ្គលម្នាក់ ដែលមានអាយុ៧0ឆ្នាំមកហើយ ។ អ៊ីចឹងទាក់ទងជាមួយនឹងវ័យចំណាស់របស់គាត់ កាលពីសម័យកម្ពុជាប្រជាធិបតេយ្យ មានន័យថា គាត់ជាបុគ្គលម្នាក់ដែលបានឆ្លងកាត់របបកម្ពុជាប្រជាធិបតេយ្យ ។ ហើយឯកសាររបស់គាត់ដែលពាក់ព័ន្ធជាមួយនឹងរូបគាត់ផ្ទាល់ នៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យហ្នឹង គឺត្រូវបានបំផ្លាញចោលអស់ហើយ ពីព្រោះថាមូលហេតុដែលគាត់ឈានឲ្យមានការបំផ្លាញចោលហ្នឹង គាត់មានការដុតកម្ទេចឯកសារទាំងនោះ ទាក់ទងនឹងអត្តសញ្ញាណរវាងគាត់ និងបងប្អូនជីដូនរបស់គាត់ ក៏ដូចជាឪពុកម្តាយរបស់គាត់អីហ្នឹង គឺគាត់ត្រូវធ្វើការដុតបំផ្លាញ ដើម្បីគេចផុតពីការសង្កេតរបស់បក្សកម្ពុជា-- បក្ស អង្គការ ដែលហៅថា បក្សកម្ពុជាប្រជាធិបតេយ្យនុំង ។

ហើយនិងចំណុចមួយទៀត គាត់ធ្វើការដុតហ្នឹង ដើម្បីគេចផុតពីការសង្កេត ការតាមដានពីប្រវត្តិគាត់ ដើម្បីឲ្យមានការរួចផុតពីសេចក្តីស្លាប់ បើគាត់មិនមានការលាក់បាំងនូវអត្តសញ្ញាណរបស់គាត់ទេ គាត់នឹងទទួលការសង្កេត ហើយនាំឲ្យគាត់នឹងត្រូវបានគេចាប់យកទៅកម្ទេចចោល ដូចប្អូនជីដូនរបស់គាត់ដែរ ។

[១០:២២:១៥]

ដូច្នេះហើយ ដោយសារតែទំនាក់ទំនងរបស់គាត់នឹងហេតុផលទាំងនេះហើយ ដែលនាំឲ្យមានការពិបាកនៅក្នុងការបង្ហាញពីទំនាក់ទំនងគាត់រវាងនឹងប្អូនប្រុសជីដូនរបស់គាត់ ។ ពាកព័ន្ធនឹងចំណុចនេះដែរ នាងខ្ញុំនឹងព្យាយាមខំប្រឹងរកស្វែងរកឯកសារបន្ថែម ប្រសិនបើមានឯកសារទាំងឡាយដែលមានការពាក់ព័ន្ធបន្ថែម នាងខ្ញុំនឹងស្នើសុំរក្សាសិទ្ធិក្នុងការប្រគល់ជូននៅពេលក្រោយ ប្រសិនបើជានាងខ្ញុំអាចរកឃើញឯកសារទាំងនោះបន្ថែមទៀត ។ សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញមេធាវីការពារក្តីបន្ត ។

**លោកស្រី ម៉ារីប៉ូល កានីហ្សារេស៖**

ពាក់ព័ន្ធទៅនឹងដើមបណ្តឹងរដ្ឋប្បវេណី E2/35 ។ អ្នកដាក់ពាក្យសុំបានបញ្ជាក់ថា ក្រោយពីបានទៅទួលស្លែងនេះ គាត់អាចនឹងស្គាល់រូបថតក្មួយប្រុសរបស់គាត់ ដែលមានលេខ 566 ប៉ុន្តែមិនមានឯកសារអ្វីនៅក្នុងសំណុំរឿង ដែលអាចបញ្ជាក់ថា រូបថតនោះ គឺថាតាមពិតជាក្មួយរបស់ដើមបណ្តឹងរដ្ឋប្បវេណីទេ។ តាមពិតខ្ញុំអាចបញ្ជាក់ផងដែរថា មិនមានឈ្មោះដែលថាដាក់នូវរូបថតនោះដែរ ។ អ៊ីចឹង

ដែលអាចបញ្ជាក់ថា ជាឈ្មោះរបស់ជនរងគ្រោះ ដូចដែលដើមបណ្ដឹងរដ្ឋប្បវេណីបញ្ជាក់នោះទេ ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញ មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីក្រុមពីរ ។

**លោក គង់ ពិសី៖**

សូមអរគុណ លោកប្រធាន ។

ទាក់ទងទៅនឹងពាក្យបណ្ដឹង ដែលមានលេខ E2/35 ហ្នឹង អ្នកដាក់នៅក្នុង-- អ្នកដែលជាដើមបណ្ដឹងរដ្ឋប្បវេណីហ្នឹង គឺថាគាត់អះអាងថា ជាក្មួយបង្កើតពិតប្រាកដមែន ។ ពីព្រោះគាត់នៅពេលដែលគាត់ទៅពិនិត្យមើលនៅមន្ទីរទួលស្លែងទៅ គាត់មានឃើញរូបថតរបស់ក្មួយគាត់ គាត់ស្គាល់ ។ ហើយគាត់ស្គាល់ហ្នឹង គាត់សំអាងថាគាត់បានរស់នៅ-- ក្មួយរបស់គាត់ហ្នឹងបានរស់នៅជាមួយគាត់ហ្នឹងយូរហើយ ។ ហើយនៅពេលមុន នៅក្នុងអំឡុងឆ្នាំ រយៈពេលដែលកម្ពុជាប្រជាធិបតេយ្យហ្នឹង គឺថាក្មួយរបស់គាត់ហ្នឹង ធ្វើជាយោធា ។ ធ្វើជាយោធាទៅ ហើយទៅជួរមុខទៅ ហើយក្រោយមកត្រូវបានគេចាប់ខ្លួន ។ ដល់ពេលត្រូវបានគេចាប់ខ្លួនអ៊ីចឹង គាត់ក៏មិនដឹងជានាំទៅណាទេ ស្រាប់តែបាត់ខ្លួន ហើយគាត់មានក្មួយរបស់គាត់ហ្នឹង បានផ្ដាំផ្ញើគាត់ថា បើសិនណាគេបញ្ជូនគាត់ បញ្ជូនដើមបណ្ដឹងរដ្ឋប្បវេណីហ្នឹង ទៅមុខ សូមឲ្យទៅមុខរហូតតែម្ដង កុំឲ្យថយក្រោយ បានន័យថា បើសិនណាជាថយក្រោយ គេនឹងត្រូវចាប់ខ្លួនទៀតហើយ ។

ទាក់ទងបញ្ហានេះ គឺថា គាត់គឺជាម្ដាយមីងជីដូនមួយរបស់ជនរងគ្រោះហ្នឹង ហើយដោយសារតែយើងមិនបានឃើញឈ្មោះហ្នឹងដូចៗជាថា ឲ្យដូចស្រដៀងៗគ្នាដោយសារតែម្ដាយមីងជីដូនមួយហ្នឹង គឺថាម្ដាយរបស់ជនរងគ្រោះហ្នឹង គឺត្រូវជាបងប្អូនជីដូនមួយរបស់គាត់ទៀត ។

[១០:២៥:៤៦]

ដល់ពេលត្រូវបងប្អូនជីដូនមួយរបស់គាត់ ហើយអ៊ីចឹងទៅ នៅពេលដែលដាក់ឈ្មោះយើងមើលឈ្មោះទៅ ឃើញថាដាច់គ្នា វាថាមិនស៊ីគ្នាត្រង់ថា ម្ដាយមីង ម្ដាយរបស់ជនរងគ្រោះត្រូវជាបងប្អូនជីដូនមួយរបស់អ្នកដាក់ពាក្យបណ្ដឹងនោះ ។ ហើយម៉្យាងទៀត គាត់ខំស្វែងរកបញ្ជីឯកសារ ឬក៏ប្រវត្តិជនរងគ្រោះនោះដែរ ប៉ុន្តែគាត់រកមិនបាន រកមិនឃើញ គាត់ស្គាល់តែរូបថត ។ ហើយមានរូបថតហ្នឹង បញ្ជូនមកទៀត គ្រាន់តែអត់មានសរសេរឈ្មោះពីក្រោមហ្នឹងទេ ហើយបើសិនណាជាយករូបថតមក គាត់សរសេរឈ្មោះបន្ថែមទៅ អាហ្នឹងវាជារឿងយើងត្រូវសរសេរបំពេញបន្ថែមទេ បើសិនណាជាវាមានតាំង

ពីជំនាន់ស-២១ មក អាហ្នឹងយើងទុកជារូប-- ជាឈ្មោះនឹងនៅទីនោះ យើងមិនអាចសរសេរបន្ថែមបានទេទៅក្នុងរូបថតនោះបាទ ។ ហើយសូមអរគុណ លោកប្រធាន សូមមេត្តាទទួលយក ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញ មេធាវីការពារក្តីបន្ត ។

**លោកស្រី ម៉ារីប៉ូល កានីហ្សារេស៖**

E2/38 ដើមបណ្តឹងរដ្ឋប្បវេណីបានបញ្ជាក់ថា ឪពុកមារបស់ខ្លួនត្រូវបានចាប់ខ្លួន ហើយឃុំខ្លួននៅទួលស្លែង ។ សេចក្តីសង្កេតដូចខាងដើមដែរ មកដល់ពេលនេះ យើងមិនមានភស្តុតាងណាមួយដែលបញ្ជាក់ថា ទំនាក់ទំនងសាច់ញាតិរវាងអ្នកដាក់ពាក្យសុំ និងជនរងគ្រោះទេ ហើយក៏មិនមានឯកសារណាមួយ ដែលបង្ហាញភស្តុតាងថា ជនរងគ្រោះត្រូវបានគេឃុំខ្លួននៅស-២១ នោះដែរ ។ ជាពិសេស មេធាវីការពារមិនឃើញឈ្មោះនេះ នៅក្នុងបញ្ជីអ្នកទោសនៅស-២១ ជាឈ្មោះរបស់ជនរងគ្រោះមួយនេះទេ ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញ មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្រុមបី ។

**លោកស្រី ហ្សាប៊ីយ៉ែន ទ្រូស្សូណាព្រូស៖**

នៅក្នុងករណីនេះ ថាឪពុកមារបស់នាង គឺថាជនរងគ្រោះនោះ គឺជាឪពុកមារបស់កូនក្តីខ្ញុំ ។ ឪពុកមាកូនក្តីរបស់ខ្ញុំ ឈ្មោះថា សុះ ឯល គឺជាបងឪពុករបស់លោកស្រី អ៊ុច ចិន ។ អ៊ីចឹង គឺថាភស្តុតាងបញ្ជាក់ពីសាច់ញាតិនេះ គឺថាខ្ញុំបានបញ្ជាក់ហើយ គឺជាសំខាន់ ចំពោះករណីនីមួយៗ ហើយយើងបានទាក់ទងបណ្តាញសមាគមន៍ដើម្បីប្រមូលនូវព័ត៌មានបន្ថែម ។ ជាពិសេស ភស្តុតាងទាក់ទងនៅនឹងទំនាក់ទំនងសាច់ញាតិលោហិត ។ ហើយយើងត្រូវតែចាត់ទុកថាករណីនេះ នឹងបានព័ត៌មានបន្ថែមនៅសប្តាហ៍នេះ ហើយភស្តុតាងផ្សេងៗទៀត ដែលអាចនឹងបង្ហាញថា មានទំនាក់ទំនងបែបនេះ ។

អ៊ីចឹងនិយាយពីទំនាក់ទំនងទៅនឹងស-២១ វិញ បុគ្គលនេះត្រូវបានចាប់ខ្លួននៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដែលគាត់រស់នៅជាមួយប្រពន្ធគាត់នៅក្នុងភ្នំពេញ ។ គាត់ជាបញ្ញវន្ត គេចាត់ទុកថាគាត់ គឺជាអ្នកសមាជិករបស់របប លន់ នល់ ហើយយើងដឹងហើយថា នៅថ្ងៃនោះគឺបញ្ញវន្តជាច្រើនមន្ត្រីរាជការទាំងឡាយត្រូវបានគេចាប់ខ្លួន ហើយឃុំខ្លួននៅស-២១ ។ ហើយតាមពិតមិនមានឯកសារទេ ដែលត្រូវបានរកឃើញទាក់ទងទៅនឹងជនរងគ្រោះមួយនេះ ។ ហើយទំនាក់ទំនងរវាងជននេះទៅនឹងស-២១ នោះមិនមាន ប៉ុន្តែនៅក្នុងសេចក្តីថ្លែងការណ៍របស់ ហៀត តីចូវ នោះ គឺថាបញ្ជាក់ឲ្យជឿជាក់បានថា គឺថាវា

អាចនឹងលទ្ធភាពដោយច្បាស់ថាជនរងគ្រោះនោះ ពិតជាបានត្រូវបានឃុំខ្លួនហើយគេកម្ទេចនៅស-២១។

ដូច្នេះ ខ្ញុំជឿជាក់ថា សេចក្តីថ្លែងការណ៍គាត់នេះ គឺវាមានលក្ខណៈស្របទៅតាមហេតុការណ៍អង្គហេតុនោះ ។

ដូច្នេះ សូមអង្គជំនុំជម្រះសម្រេចទៅតាមអ្វីជាភស្តុតាងដែលយើងមាន ។ ហើយខ្ញុំជឿថា លោកប្រធានសូមអភ័យទោស ខ្ញុំដែលបានបញ្ជាក់ពីបញ្ហានេះ ។ ប៉ុន្តែ តាមពិតនៅក្នុងករណីនេះ ខ្ញុំមានឯកសារពីរបន្ថែម ដែលអាចបញ្ជាក់អំពីទំនាក់ទំនងសាច់ញាតិនោះ គឺលេខ ERN00274587 ហើយនិង ERN 00274589 ដែលជាឯកសារសេចក្តីអះអាងបញ្ជាក់ពីររបស់មនុស្សមួយចំនួនដែលស្គាល់កូនក្តីរបស់ខ្ញុំច្បាស់ ហើយនិងផ្តល់ព័ត៌មាន ហើយភស្តុតាងអ្វីចាំបាច់ ដើម្បីបញ្ជាក់ពីទំនាក់ទំនងគាត់ទៅនឹងឪពុកមារបស់គាត់នេះ ដែរថាបន្ថែមទៅនឹងអ្វីដែលខ្ញុំដាក់បញ្ជូនពីមុននោះ ។ សូមអង្គជំនុំជម្រះមេត្តាទទួលយកភស្តុតាងថ្មីបន្ថែមនេះ ហើយសម្រេចទទួលស្គាល់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីមួយនេះ ។

**ប្រធានអង្គជំនុំ៖**

ឥឡូវដល់ម៉ោងត្រូវសម្រាក ហើយអង្គជំនុំជម្រះប្រកាសសម្រាកម្ភៃនាទីរហូតដល់ម៉ោងដប់មួយខ្វះដប់នាទី អញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការរបស់យើង ។

**លោកស្រី សែ កុលវុឌ្ឍី៖**

សូមអញ្ជើញក្រោកឈរ!

*[សវនាការសម្រាកពីម៉ោង១០:៣២ នាទីដល់ម៉ោង ១០:៥៥នាទី]*

**ប្រធានអង្គជំនុំ៖**

អញ្ជើញអង្គុយចុះ ។ អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ ។ សូមអញ្ជើញមេធាវីការពារក្តីបន្តឡើងធ្វើអត្ថាធិប្បាយ ។

**លោកស្រី ម៉ារីប៉ូល កានីហ្សារេស៖**

សូមអរគុណលោកប្រធាន ។ មេធាវីការពារក្តីបានឆ្លៀតយកពេលសម្រាកនេះ សិក្សាទៅលើឯកសារដែលបានដាក់កាលពីព្រឹកមិញដោយក្រុមដើមបណ្តឹងរដ្ឋប្បវេណីមួយក្រុមនោះ ។ ហើយខ្ញុំសង្ឃឹមថា លោកប្រធាននឹងអនុញ្ញាតឲ្យខ្ញុំនិយាយឡើងវិញតាមលំដាប់លំដោយ ដែលខ្ញុំលើកឡើងកាលពីព្រឹក

មិញ ហើយឲ្យខ្ញុំលើកឡើងអំពី E2/30 ខ្ញុំបានទុក មិនទាន់បានលើកឡើងនោះទេ ។ ហើយដោយសារតែខ្ញុំចង់យកពេលវេលាដើម្បីពិភាក្សាទៅលើឯកសារផ្សេងៗ ។

ទោះបីជាឯកសារមួយចំនួន យើងឈរទៅលើជំហររបស់យើង ហើយយើងរក្សាការជំទាស់ និងតវ៉ារបស់យើងក៏ដោយ ។ ជាការពិត ដើមបណ្ដឹងរដ្ឋប្បវេណីមួយនោះ គឺបងប្អូនប្រុសពីរនាក់ ហើយនិងបងប្អូនថ្លៃត្រូវបានជាប់ឃុំនៅស-២១ ។

ប្រសិនអ៊ីចឹងមែន ដើមបណ្ដឹងហើយនិងជនរងគ្រោះមានឈ្មោះស្រដៀងគ្នា ។ ដូច្នេះហើយយើងហាក់ដូចជាមិនសួរយល់អំពីចំណងញាតិលោហិតរបស់គាត់ ទាក់ទងទៅនឹងការបង្ហាញនៅក្នុងឯកសារដែលបានបង្ហាញ ។ ហើយដើមបណ្ដឹងបានដាក់នូវរូបថតមួយចំនួនដែលបានដាក់ចូលទៅក្នុងសំណុំរឿង។ ហើយយើងខ្ញុំយល់ថា រូបថតទាំងអស់នោះមិនមានលក្ខណៈគ្រប់គ្រាន់ ដើម្បីបង្ហាញថា ជនរងគ្រោះទាំងអស់នោះ ពិតជាបានជាប់ឃុំនៅស-២១ មែន ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញមេធាវីតំណាងឲ្យដើមបណ្ដឹងរដ្ឋប្បវេណីក្រុមបី ។

**លោកស្រី ហ្សាប៊ីយ៉ែន ទ្រូស្សណាព្រូស៖**

លោកប្រធាន! នៅក្នុងសំណុំរឿងនោះគឺទាក់ទងទៅនឹងលោកស្រី ញឹម គឹមហឿន ដែលបាត់បងប្អូនប្រុសពីររូប ហើយនិងបាត់បង់នូវប្រពន្ធរបស់ ឈួន រឿង ផងដែរ ។ ខ្ញុំជឿថា ទំនាក់ទំនងជាមួយនឹងស-២១ គឺអ្វីដែលយើងមិនអាចតវ៉ាបានទេ គឺពិតជាមានមែន ។ យើងមានរូបថតដែលបានដាក់នៅក្នុងសំណុំ-- នៅក្នុងសវនាការរបស់យើង ហើយរូបថតនោះ គឺយកចេញពីស-២១ ។ រូបថតនោះ ដោយសារតែចោទសួរទៅលើបញ្ហារូបថតនោះ គឺរូបថតនោះ គឺឲ្យខ្ញុំធ្វើការទាក់ទង ខ្ញុំទៅទាក់ទងជាមួយនឹងស-២១ សារមន្ទីរនៅទួលស្លែង ហើយធ្វើការសាកសួរអំពីប្រភពនៃរូបថតទាំងអស់នោះ ។

[១០:៥៨:៥៩]

ហើយជាការពិតទៅ គឺយើងបានទទួលនូវលិខិតអះអាងបញ្ជាក់ពីនាយករងនៃសារមន្ទីរទួលស្លែងដែលគ្រប់គ្រងទៅលើឯកសារ ហើយនៅក្នុងនោះឯកសារមានលេខ 009845 ហើយប្រសិនអនុញ្ញាតនោះ ខ្ញុំនឹងពិនិត្យទៅលើរូបថតនោះ ។ ហើយយើងឃើញថា លិខិតធានាអះអាងនៅក្នុងលិខិតនោះក៏បានលើកឡើងទាក់ទងទៅនឹងរឿងក្ដីមួយទៀតផងដែរ ។

ដូច្នេះហើយ គឺខ្ញុំសូមឲ្យលោក លោកស្រីចៅក្រម និងភាគី កុំឲ្យយល់ច្រឡំទៅលើករណីនេះ ។

ចំពោះករណីនេះលេខ ហើយនិង០២ គឺយើងឃើញមានលេខ 0245 និង0247 ហើយរូបថតនោះ គឺបានផ្ដល់ជូនទៅដល់មេធាវីការពារក្ដី ហើយឯកសារផ្សេងៗនឹងធ្វើការបញ្ជូនទៅដល់មេធាវីការពារក្ដី តាមរយៈសំណើសុំដែលបានដាក់ជូនដោយអង្គជំនុំជម្រះសាលាដំបូងផងដែរ ។

ខ្ញុំសូមបន្ថែមថា នៅក្នុងករណីនេះ យើងក៏មានប្រវត្តិរូបស-២១ ទាក់ទងទៅនឹង ផាំង ។ យើងឃើញមានរូបថត-- ប្រវត្តិរូបស-២១ ដែលយើងមានឃើញនៅក្នុងលេខយោងឯកសារ ERN លេខ 0001-- (សូមអភ័យទោស បាទ, សូមខ្ញុំកែតម្រូវ) ។ ខ្ញុំឲ្យលេខ ERN ខ្មែរវិញ គឺ 00273314 ខ្ញុំជឿថា គឺយើងមិនឃើញមានបញ្ហាកើតឡើងណាមួយទាក់ទងទៅនឹងការបង្ហាញអំពីទំនាក់ទំនងជាមួយនឹង ស-២១ នោះទេ យើងមានរូបថត ប្រវត្តិរូប ។

ហើយចំពោះបញ្ហាចំណងសាច់ញាតិវិញ នៅក្នុងករណីមួយនេះ គឺយើងមានលិខិតធានាអះអាងដែល យើងបានដាក់បញ្ចូលទៅក្នុងសំណុំរឿងរួចហើយ ហើយលេខ ERN ជាភាសាខ្មែរ គឺ 00273301 ហើយនិង 00273307 ។ គឺលិខិតធានាអះអាចំនួនពីរនេះ ដែលចេញពីបុគ្គល-- ដែលចេញដោយបុគ្គល ចេង អ៊ឹម និង ចេង ថុល ហើយបានបង្ហាញបញ្ជាក់អំពីចំណងសាច់ញាតិរវាងកូនក្ដីរបស់ខ្ញុំ និងបងប្អូនប្រុសរបស់គាត់ ។

ទាក់ទងទៅនឹងព្យសនកម្មដែលទទួលរងដោយកូនក្ដីរបស់ខ្ញុំ គឺមិនអាចចោទសួរបានទេ គឺពិតជាមាន ។ ហើយសាច់ញាតិរវាងភាគីនិងជនរងគ្រោះ គឺពិតជាមានលក្ខណៈជិតស្និទ្ធ ។ ដូច្នេះហើយ គឺមានការបង្កប់នូវការឈឺចាប់នៅក្នុងខ្លួនរបស់កូនក្ដីរបស់ខ្ញុំទាក់ទងទៅនឹងការបាត់បង់ប្អូនប្រុស និងប្អូនស្រីថ្លៃ ។ ហើយទាក់ទៅនឹងប្អូនថ្លៃស្រីនោះ យើងក៏មានរូបថតផងដែរ ហើយរូបថតនោះ គឺរូបថតចេញមកពីព្រៃស ស-២៤ ។

[១១:០៣:០២]

ទាំងអស់នេះហើយ គឺជាសេចក្ដីសង្កេតរបស់ខ្ញុំទាក់ទងទៅនឹងរឿងក្ដីមួយនេះ ដែលបានលើកឡើង ។

ហើយចំពោះដើមបណ្ដឹងរដ្ឋប្បវេណី E2/41 វិញ ។ ដើមបណ្ដឹងរដ្ឋប្បវេណីគាត់បានលើកឡើងថា ជីតារបស់គាត់ត្រូវបានស្លាប់ ត្រូវបានគេសម្លាប់នៅទួលស្លែង ដោយសារតែដើមបណ្ដឹងរដ្ឋប្បវេណីបានលើកឡើងថា គាត់បានឃើញរូបថតនៅសល់នៅទួលស្លែង ។

មេធាវីការពារក្ដីសូមកត់សម្គាល់ថា ដើមបណ្ដឹងរដ្ឋប្បវេណីមិនបានដាក់រូបថតនៅក្នុងសំណុំរឿង

ហើយដើមបណ្តឹងរដ្ឋប្បវេណីក៏ពុំបានផ្តល់ភស្តុតាង ដែលថាជនរងគ្រោះពិតជាជីតារបស់គាត់ ។ យើងមិនឃើញមានឯកសារដែលបង្កើតចេញពីស-២១ ផ្តល់ជូនយើងខ្ញុំនោះទេ ។

ចំណុចចុងក្រោយ យើងសូមធ្វើការកត់សម្គាល់ថា ជីតានោះ គឺយើងមិនអាចរកឈ្មោះគាត់ឃើញនៅក្នុងបញ្ជីអ្នកទោសនៅស-២១ នោះទេ ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្រុមមួយ ។

**កញ្ញា ទី ស្រ៊ីនណា៖**

នាងខ្ញុំ សូមជម្រាបជូនទាក់ទងទៅនឹងដើមបណ្តឹងរដ្ឋប្បវេណី ដែលមានលេខ E2/41 ដែលមានឈ្មោះ ស៊ិន ស៊ីណែត ។ ទាក់ទងទៅនឹងជំហានដំបូងនាងខ្ញុំសូមជម្រាបពាក់ព័ន្ធទៅនឹងឯកសារដែលពាក់ព័ន្ធទៅនឹងអ្នកទោសនៅមន្ទីរស-២១ គឺយើងមានឯកសារ គឺមានប្រវត្តិរូបអ្នកទោសជាប់ឃុំឃាំងនៅមន្ទីរស-២១ ដែលមានឈ្មោះ ភិ គុណ ហៅ ស៊ិន ហើយនិងយើងមានរូបថត ដែលបញ្ជាក់អំពីអត្តសញ្ញាណរបស់គាត់ដែលមានពាក់ស្លាកលេខប្រាំពីរ ។ នៅក្នុងហ្នឹង យើងក៏មានអត្តសញ្ញាណនៃការចង្អុលបង្ហាញរបស់ដើមបណ្តឹងរដ្ឋប្បវេណី ដែលគាត់ចង្អុលបង្ហាញថា រូបថតដែលមាននៅក្នុងមន្ទីរស-២១ហ្នឹង គាត់បានទៅស-២១ ហើយក៏គាត់បានស្វែងរករូបថត គាត់ក៏បានឃើញអត្តសញ្ញាណនៃជីតារបស់គាត់ដែលពាក់ស្លាកលេខប្រាំពីរនេះ ។

ពាក់ព័ន្ធទៅនឹងឯកសារទាំងនេះហ្នឹង ទាក់ទងនឹង គឺពួកខ្ញុំបានស្រាវជ្រាវចេញមកពី វេបសាយរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ហើយឯកសារទាំងហ្នឹង យើងខ្ញុំនឹងធ្វើការបញ្ជាក់បន្ថែមនៅមន្ទីរស-២១ និងសូមធ្វើការដាក់ជូននៅពេលក្រោយ ។

[១១:០៥:៤៦]

ឯចំណែក ទាក់ទងទៅនឹងទំនាក់ទំនងរវាងដើមបណ្តឹងរដ្ឋប្បវេណី ជាមួយនឹងជីតារបស់គាត់ដែលមានអត្តសញ្ញាណនៅក្នុងមន្ទីរស-២១នេះ យើងឃើញថា ឯកសាររបស់គាត់ គឺយើងបានបញ្ចូលទាក់ទងទៅនឹងអត្តសញ្ញាណ ដែលគាត់បាន ដែលមាននាពេលបច្ចុប្បន្ន គឺអត្តសញ្ញាណប័ណ្ណដែលធ្វើនៅពេលបច្ចុប្បន្ន ហើយនិងមានសៀវភៅសំបុត្រកំណើតក៏ដូចជាមានសៀវភៅគ្រួសារ ។

ហើយពាក់ព័ន្ធជាមួយនឹងប្រវត្តិរូបរបស់ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះដែរ ទាក់ទងនឹងប្រវត្តិរបស់គាត់ ។ កាលពីមុនឆ្នាំ១៩៧៥ ហ្នឹង គឺមុនរបបខ្មែរក្រហមហ្នឹង ឪពុកម្តាយរបស់គាត់បានបញ្ជូនគាត់ឲ្យ

ទៅរស់នៅជាមួយនឹងជីដូនជីតារបស់គាត់នៅកំពង់សោម ។ ពេលដែលគាត់ទៅហ្នឹង គឺគាត់នៅមានអាយុទើបតែប្រាំពីរឆ្នាំទេ ។ ពេលនុ៎ង គឺគាត់បានរស់នៅជាមួយជីតារបស់គាត់ហ្នឹង គឺគាត់មានភាពជីដូនជីតារបស់គាត់បានធ្វើការបីបាច់ថែរក្សាគាត់ហ្នឹង ដូចជាកូនបង្កើតអ៊ីចឹង ដែលធ្វើឲ្យគាត់ហ្នឹងមានមនោសញ្ចេតនា និងមានការចងចាំជីតារបស់គាត់ជាខ្លាំង ហាក់បីដូចជាឪពុកម្តាយរបស់គាត់បង្កើតតែម្តង ។

ហើយនៅក្នុងនុ៎ងដែរ តាមការរៀបរាប់របស់ដើមបណ្តឹងរដ្ឋប្បវេណី គាត់បានរៀបរាប់នៅក្នុងពាក្យបណ្តឹងរបស់គាត់ហ្នឹង គឺគាត់បានបង្ហាញថា គាត់បានរស់នៅជាមួយជីតារបស់គាត់ហ្នឹង នៅវាលរេញ ខេត្តកំពង់សោម ។ នៅក្នុងនោះ នៅក្នុងប្រវត្តិរូបនោះ បើយើងធ្វើការផ្ទៀងផ្ទាត់ទៅនៅក្នុងប្រវត្តិរូប ដែលយើងទទួលបាននេះ គឺចំណុចទីប្រាំ ដែលគេនិយាយក្រសួង និងនាទីមុនថ្ងៃរំដោះភ្នំពេញ គឺគាត់ធ្វើជាងនៅកំពង់សោម ។ នេះគឺជាចំណុចមួយដែលស្របជាមួយនឹងៗ សម្តីរបស់ដើមបណ្តឹងរដ្ឋប្បវេណី ដែលគាត់បានអះអាងថា គាត់បានរស់នៅជីតារបស់គាត់នៅកំពង់សោម មុនសម័យខ្មែរក្រហម ។ នេះគឺជាចំណុចមួយ ដែលខ្ញុំស្នើសុំឲ្យលោកប្រធានមេត្តាពិចារណាត្រង់ចំណុចនេះ ដើម្បីបញ្ជាក់ពីទំនាក់ទំនងរបស់គាត់ជាមួយនឹងជីតារបស់គាត់ ។

ហើយចំណុចមួយទៀត ដែលជាចំណុចសំខាន់មួយទៀតដែលនាងខ្ញុំទើបតែបានទទួលដំណឹងពីខាងគាត់ដែរនោះ ដោយសារតែគាត់បានរកឃើញប្រវត្តិរូបក៏ដូចជា រូបថត និងភិនភាគដែលគាត់បានរកឃើញនៅក្នុងមន្ទីរស-២១ ពាក់ព័ន្ធជាមួយនឹងជីតារបស់គាត់នឹងហើយ ដែលនាំឲ្យគាត់ហ្នឹងធ្វើការស្វែងរកឪពុកម្តាយរបស់គាត់ ដោយចុះនៅក្នុងទស្សនាវដ្តីមជ្ឈមណ្ឌលឯកសារកម្ពុជា ដែលស្វែងរកការពិត ។ ស្វែងរកការពិត ដែលមានលេខ១១៤ ខែមិថុនា ឆ្នាំ២០០៩ ដោយសារតែឯកសារ ដែលគាត់បានរកឃើញនៅមន្ទីរស-២១ ហ្នឹងហើយ ជាប្រភព ជាមួយមូលដ្ឋានមួយ ដែលធ្វើឲ្យគាត់ហ្នឹងអាចស្វែងរកអត្តសញ្ញាណរបស់គាត់ ដែលគាត់បានបែកពីក្រុមគ្រួសារ ក្រោយពីរបបកម្ពុជាប្រជាធិបតេយ្យដែលគាត់មានតែម្នាក់ឯង គាត់អត់មានបងប្អូនណាទេ ។

[១១:០៨:៥៣]

ដូច្នេះហើយ យើងមានលក្ខណៈពិបាកនៅក្នុងការបង្ហាញពីភិនភាគរបស់គាត់ ។ ហើយចំណុចមួយទៀត គឺគាត់បែកពីក្រុមគ្រួសារហ្នឹងតាំពីអាយុប្រាំពីរឆ្នាំ ។ ហើយដូច្នេះហើយប្រសិន-- នេះគឺជាចំណុចមួយដែលសំខាន់ ដែលបង្ហាញ ជីតារបស់គាត់ហ្នឹង គឺជាពិតជាជីតា ហើយជាសាច់ញាតិតែមួយ

គាត់ ដែលគាត់អាចរកឃើញប្រភព ហើយនិងនាំឲ្យគាត់ហ្នឹងឈានទៅរកការដែលគាត់អាចស្វែងរកឪពុកម្តាយ ក៏ដូចប្អូនប្រុសរបស់គាត់ទៀត ដែលគាត់ធ្វើការផ្សព្វផ្សាយរកដំណឹងតាមរយៈទស្សនាវដ្តីស្វែងការពិតនេះ ។

សូមអរគុណ សូមអរគុណលោកប្រធាន ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញមេធាវីការពារក្តីបន្ត ។

**លោកស្រី ម៉ារីប៉ូល កានីហ្សារេស៖**

ហើយដើមបណ្តឹងរដ្ឋប្បវេណី E2/62 វិញ បានលើកឡើងថា បងប្អូនប្រុសរបស់គាត់ពីរនាក់ត្រូវបានគេចាប់ខ្លួន និងសម្លាប់ចោលនៅទួលស្លែង ។ ហើយដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ បានដាក់ជូននូវរូបថត ហើយគាត់បញ្ជាក់ថា រូបថតនោះ គឺជាប្អូនប្រុស បងប្រុសរបស់គាត់ ហើយយ៉ាងណាក៏ដោយមិនមានធាតុផ្សំទាំងឡាយដាក់នៅក្នុងសំណុំរឿង ផ្តល់ជាភស្តុតាងបញ្ជាក់អំពីចំណងសាច់ញាតិនោះទេ ។ បន្ថែមទៅលើចំណុចនេះ មេធាវីការពារក្តីសូមកត់សម្គាល់ផងដែរថា តាំងពីឆ្នាំ១៩៧៦ គឺក្នុងខែមីនា តាម៉ុក គឺគាត់ទទួលខុសត្រូវផ្នែកនិរតី ហើយអ្វីដែលដើមបណ្តឹងរដ្ឋប្បវេណី គាត់នៅតំបន់នោះផងដែរ នៅក្នុងភូមិភាគនោះផងដែរ ហើយមិនមានការបញ្ជាក់អំពីការបញ្ជូនបុគ្គលណាមួយចូលមកក្នុងមន្ទីរនេះទេ មន្ទីរសន្តិសុខស-២១ ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្រុមមួយ ។

**កញ្ញា ទី ស្រ៊ីនណា៖**

សូមអរគុណលោកប្រធាន ។ ទាក់ទងទៅនឹងដើមបណ្តឹងរដ្ឋប្បវេណី E2/62 ហ៊ឹម មុំ ។ ជាដំបូង នាងខ្ញុំសូមបង្ហាញពីចំណុចដែលពាក់ព័ន្ធទៅក្នុងមន្ទីរស-២១ ។

ទាក់ទងទៅនឹងចំណុច ដែលពាក់ព័ន្ធនឹងឯកសារ យើងពុំមានឯកសារដែលពាក់ព័ន្ធនៅក្នុងប្រវត្តិរូបទេ ក៏ប៉ុន្តែយើងមានឯកសារដែលពាក់ព័ន្ធទៅនឹងរូបថត ។ មានន័យថាគាត់មានរូបថត ដែលមានពាក់ស្លាកលេខ២១៧ ហើយនិងទាក់ទងនឹងរូបថតនេះ គឺយើងបានប្រភពមកពីប្រព័ន្ធអ៊ីនធឺណែតដែរ ហើយនៅក្នុងប្រព័ន្ធហ្នឹង គឺយើងបានស្វែងរកប្រភពនៃឯកសារដែលគេដាក់ថា រូបថត *ដេតាបេស* របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ។ នៅក្នុងនុ៎ង គឺបានបង្ហាញយ៉ាងច្បាស់ហើយថាបុគ្គលហ្នឹង គឺដកចេញ

មកពីមន្ទីរទួលស្លែង ហើយនៅក្នុងឯកសារហ្នឹង គឺយើងមានប្រភពហ្នឹងដែលបញ្ជាក់ថា បុគ្គលដែលមានរូបភាពនៅក្នុងនេះហ្នឹង គឺគាត់ជាបុគ្គលដែលជាប់នៅក្នុងមន្ទីរទួលស្លែង ។

ហើយចំណុចមួយទៀត ដែលយើងបង្ហាញកាន់តែច្បាស់មួយទៀត គឺសាច់ញាតិរបស់គាត់ ដែលជាដើមបណ្តឹងរដ្ឋប្បវេណី ដែលគាត់បានអះអាងថា គាត់ជាសាច់ញាតិរបស់រូបថតនេះ ដែលមាននៅក្នុងមន្ទីរស-២១នោះ គឺគាត់បានទៅចង្អុលបង្ហាញយ៉ាងច្បាស់ពីភិនភាគបងត្រូវជាបងប្រុសរបស់គាត់ ដែលមានជាប់នៅក្នុងមន្ទីរទួលស្លែងនោះ ។ នេះ គឺជាចំណុចដែលពាក់ព័ន្ធទៅនឹងមន្ទីរស-២១ ។

ទាក់ទងទៅនឹងចំណុចដែលពាក់ព័ន្ធទៅនឹងសាច់ញាតិ ។ ទាក់ទងនឹងបុគ្គលនេះដែរ គាត់ក៏បានរៀបរាប់ដែរ គាត់ថាតាមការសម្ភាសន៍ជាមួយគាត់ គឺគាត់បានប្រាប់ថា បងប្អូនគាត់ពីរនាក់ដែលបានបាត់ខ្លួនដូចអ្វីដែលមេធាវីការពារគាត់បានលើកឡើងអ៊ីចឹង ។ ក៏ប៉ុន្តែ ជាក់ស្តែងដែលពួកខ្ញុំបានសម្ភាសជាមួយគាត់ គាត់ថា អ្នកដែលគាត់រកឃើញនោះ គឺគាត់រកឃើញអ្នកដែលស្លាប់នោះតែម្នាក់គត់ គឺបងគាត់ឈ្មោះ សាង គឹមលាង ហើយទាក់ទងនឹង សាង គឹមលាង នេះ-- ។

ទាក់ទងអត្តសញ្ញាណរបស់គាត់ បើវិភាគទៅ យើងឃើញថា វាមានភាពប្លែកគ្នានៅក្នុងឯកសារដែលខ្ញុំបានប្រគល់ជូនទៅមេធាវីការពារក្តី ។ វាមានភាពខុសគ្នាត្រង់ថា អត្តសញ្ញាណប័ណ្ណរបស់គាត់ហ្នឹងប្រើពាក្យ ហ៊ឹម មុំ ឯចំណែកនៅក្នុងសំបុត្រកំណើត គឺឈ្មោះ ហ៊ឹម ម៉ុម ដែលសរសេរអក្សរខុសគ្នាមួយ ហ៊ឹម "ម" ដាក់ស្រះ "ុំ" មួយទៀត ហ+ "ម"+"៉"+"ុ"+"ម", ហ៊ឹម ម៉ុម ។ នេះជាភាពខុសគ្នាដែលកើតមានឡើង ហើយទាក់ទងទៅនឹងភាពខុសគ្នានេះ គឺពុំមែនជាកំហុសរបស់គាត់នៅក្នុងការដាក់ឯកសារទេ គឺជាកំហុសមួយដែលទាក់ទងទៅស្ថានភាពនៅក្នុងប្រទេសកម្ពុជា ក្រោយសម័យរបបកម្ពុជាប្រជាធិបតេយ្យ ។

[១១:១៣:៤២]

យើងដឹងហើយថាបុគ្គលចេះដឹងមួយចំនួន មន្ត្រីអត្រានុកូលដ្ឋាន ដែលចេះដឹងជាន់ខ្ពស់មួយចំនួន គឺត្រូវបានបាត់បង់ជីវិតអស់ហើយ គឺនៅសេសសល់តែបុគ្គល ដែលពុំសូវចេះដឹងទេ ។ ដូច្នេះហើយទាក់ទងទៅនឹងការចុះឈ្មោះ ការដាក់ឯកសារអី ដែលគាត់ធ្វើហ្នឹង គឺតែងតែមានការភាន់ច្រឡំ ។ ហើយពាក់ព័ន្ធជាមួយនឹងកូនក្តីនាងខ្ញុំទៀតសោតហ្នឹង គាត់គឺជាបុគ្គលដែលមិនសូវចេះអក្សរទេ ។ ដូច្នេះហើយគាត់មិនបានពិនិត្យមើលថា ភាពខុសគ្នារវាងឯកសារទាំងពីរហ្នឹង កើតឡើងដោយយ៉ាងម៉េចទេ ។

អ៊ីចឹងនេះ គឺជាចំណុចមួយដែលប្រជាពលរដ្ឋយើងដែលនៅសេសសល់គឺជាបុគ្គលដែលអក្ខរកម្ម។ អ៊ីចឹងនេះ គឺជាចំណុចមួយដែលសូមលោកប្រធានមេត្តាពិចារណា ។ ហើយពាក់ព័ន្ធនឹងភាពខុសគ្នានេះ គាត់បានបញ្ជាក់ហើយ បងប្រុសរបស់គាត់ហ្នឹង សាង គឹមលាង១ ហ្នឹង គាត់បានបាត់បង់ប្អូនពីរនាក់ គឺ សាង គឹមលាង និង សាង គឹមឡេង ។ អ្នកដែលគាត់រកឃើញនៅក្នុងមន្ទីរស-២១ ហ្នឹង គឺ សាង គឹមលាង ។

ភាពខុសគ្នានេះ គឺបានបង្ហាញចំណុច ដែលនាងខ្ញុំចង់បង្ហាញហ្នឹង គឺដោយសារតែភាពខុសគ្នានៃតួអក្សរ ។ ហ៊ឹម មុំ នៅក្នុងអត្តសញ្ញាណប័ណ្ណ គឺសរសេរត្រឹមត្រូវស្របជាមួយនឹងពាក្យបណ្តឹង ។ ឯចំណែកសំបុត្របញ្ជាក់កំណើតនេះ គឺបង្ហាញពីភាពខុសគ្នារវាង គាត់ប្រើត្រកូលរបស់គាត់ ត្រកូលឪពុករបស់គាត់ ហ៊ឹម ដល់គាត់ប្រើ ហ៊ឹម មុំ ។ ឯចំណែក បងប្រុសរបស់គាត់ហ្នឹងបានធ្វើការផ្លាស់ប្តូរឈ្មោះដោយដាក់ត្រកូលថា សាង គឹមលាង ។ សាង គឹមលាង នេះ គឺ សាង ដោយយកឈ្មោះឪពុករបស់គាត់មកធ្វើជាត្រកូល ។ នេះ គឺជាចំណុច ភាពប្លែកគ្នារវាងកូនក្តីនាងខ្ញុំ មិនថាកូនក្តីនាងខ្ញុំ ហ៊ឹម មុំ ក៏ដូចជាកូនក្តីផ្សេងៗទៀតដែរ ដែលមានឈ្មោះខុសគ្នានេះ ដោយសារតែភាពប្រែប្រួលនៃរបបកម្ពុជាប្រជាធិបតេយ្យហ្នឹង ក៏ដូចជាមកដល់ពេលបច្ចុប្បន្នហ្នឹង គឺមានភាពប្រែប្រួល ។ ហើយដូច្នេះហើយមានការផ្លាស់ប្តូរឈ្មោះ ហើយការផ្លាស់ប្តូរឈ្មោះហ្នឹង គឺយើងធ្វើការផ្លាស់ប្តូរដោយ យើងអត់មានបានផ្លាស់ប្តូរដោយស្នើសុំទៅអាជ្ញាធរ ដូចកាលពីសម័យមុន ឬក៏សម័យក្រោយបច្ចុប្បន្ននេះទេ ។ ព្រោះនេះ គឺជាភាពខុសគ្នាដែលប្រជាពលរដ្ឋ តែងតែធ្វើការដាក់ ផ្លាស់ប្តូរតាមតែចិត្ត ពេលខ្លះទៅមានការខុសគ្នា ដោយអាជ្ញាធរហ្នឹង គាត់អត់បានសិក្សាទៅលើឈ្មោះច្បាស់លាស់ ក៏គាត់សរសេរឈ្មោះហ្នឹង គឺអាចមានការភាន់ច្រឡំ ។

ដូច្នេះ ជាចំណុចមួយដែលនាងខ្ញុំសូមជម្រាបជូនលោកប្រធានទាក់ទងទៅនឹងចំណុចនេះ ។ ឯចំណែកទាក់ទងនឹង ហ៊ឹម មុំ ហ្នឹងទៀត នាងខ្ញុំនឹងធ្វើការស្វែងរកឯកសារបន្ថែមទៀត ដើម្បីមកបញ្ជាក់ឲ្យកាន់តែច្បាស់ថា បុគ្គលហ្នឹងពិតជាមានទំនាក់ទំនងជាមួយគ្នា ។ ពីព្រោះថា បើសិនជាមិនមានការទំនាក់ទំនងគ្នាទេ ក៏កូនក្តីនាងខ្ញុំ ហ៊ឹម មុំ មិនអាចចងចាំភិនភាគ ឬក៏មុខមាត់នៅក្នុងរូបថតហ្នឹង គឺជាបងប្រុសរបស់គាត់ដែរ ។ ដោយសារចំណុចនេះហើយ គឺជាចំណុចដែលសំខាន់ ព្រោះអីគាត់មិនអាចទៅចង្អុលបុគ្គលផ្សេង បុគ្គល “ក” ឬក៏ “ខ” ណាមួយ ថាជាបងប្រុសរបស់គាត់ទេ ។ គឺគាត់ចង្អុល លុះត្រាតែជាបងប្រុសរបស់គាត់ ទើបគាត់បានចង្អុលបង្ហាញ ។ នេះគឺជាចំណុចមួយដែលសំខាន់បញ្ជាក់ពី

ទំនាក់ទំនងរបស់គាត់ ដែលនាំឱ្យគាត់មានភាពរំជួលចិត្ត ធ្វើឱ្យគាត់ហ្នឹងរំជួលចិត្ត មានការលំបាកចិត្ត ដោយសារឃើញបង គាត់កើតទុក្ខ ដោយសារឃើញបងប្រុសរបស់គាត់ហ្នឹងស្លាប់នៅក្នុងមន្ទីរ ស-២១ ដែលទទួលរងទារុណកម្មធ្ងន់ធ្ងរបំផុត ។

នាងខ្ញុំក៏សុំស្នើសុំដល់លោកប្រធានដែរ សុំស្នើសុំឱ្យលោកប្រធាន ក៏ដូចជា លោក លោកស្រីចៅក្រមជាតិ និងអន្តរជាតិនៅក្នុងសាលសវនាការនេះផងដែរ ដើម្បីទទួលយកនូវដើមបណ្តឹងរដ្ឋប្បវេណីជាច្រើនដែលគាត់ ភាគច្រើន គឺគាត់អត់មានឯកសារគ្រប់គ្រាន់ គឺគាត់មានឯកសារមួយភាគតូចបំផុត ដែលគាត់អាចនឹងបង្ហាញថា គាត់មានទំនាក់ទំនង ក៏ដូចជាឯកសារដែលពាក់ព័ន្ធទៅនឹងមន្ទីរស-២១ ពីព្រោះថា ដូចជាមេធាវីដើមបណ្តឹងរដ្ឋប្បវេណីក្រុមបី គាត់បានលើកឡើងពីដំបូងហើយថា ឯកសារភាគច្រើន គឺត្រូវបានបាត់បង់ ឯកសារភាពច្រើន គឺត្រូវបានយកទៅវេចខ្ចប់ ។ ឯកសាររបស់មន្ទីរស-២១ ត្រូវបានវេចខ្ចប់នៅ-- វេចខ្ចប់នំ វេចខ្ចប់អីផ្សេងៗនៅក្នុងសម័យក្រោយរបបកម្ពុជាប្រជាធិបតេយ្យ ។

[១១:១៧:៣៩]

ឯចំណែកឯកសារមួយចំនួនទៀត ដែលពាក់ព័ន្ធទៅនឹងទំនាក់ទំនងរបស់ដើមបណ្តឹងរដ្ឋប្បវេណី ដូចយើងឃើញហើយថា សង្គមខ្មែរយើងមុនសម័យកម្ពុជាប្រជាធិបតេយ្យ យើងក៏មានឯកសារមួយចំនួនដែរ ក៏ប៉ុន្តែដោយសារភាពខ្លាច រអារបស់ប្រជាពលរដ្ឋយើង នៅក្នុងការដែលថ្នាក់ដឹកនាំ ឬក៏អង្គការរបស់កម្ពុជាប្រជាធិបតេយ្យហ្នឹង គាត់បានធ្វើការតាមដាន ស្រាវជ្រាវប្រវត្តិរូប ដើម្បីយកទៅកម្ទេចចោល ។ ដោយសារភាពភ័យខ្លាចរបស់គាត់ហ្នឹងហើយ ធ្វើឱ្យគាត់ហ្នឹងសម្រេចចិត្តនៅក្នុងការបំផ្លាញឯកសារ ដែលគាត់មានកន្លងមកចោលអស់ ។

ដូច្នេះហើយ ដល់ពេលបច្ចុប្បន្ននេះ យើងមិនអាចយកឯកសារ ឬក៏រកឯកសារណាមួយ ដើម្បីមកបញ្ជាក់ថា គឺគាត់មានទំនាក់ទំនងជាមួយបុគ្គល “ក” ឬក៏ “ខ” ឬក៏ជាបុគ្គលដែលមាននៅក្នុងមន្ទីរ ស-២១ ទេ ។ នេះគឺជាចំណុចមួយដែលនាងខ្ញុំចង់ជម្រាបជូនដល់អង្គសវនាការ ដើម្បីក្នុងការពិចារណាទៅលើកត្តានេះ ។ នេះ គឺជាស្ថានភាពជាក់ស្តែងដែលកើតមាន ។

សូមអរគុណលោកប្រធាន ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញមេធាវីការពារក្តីបន្ត ។

**លោកស្រី ម៉ារីប៉ូល កានីហ្សារេស៖**

ហើយដើមបណ្ដឹងរដ្ឋប្បវេណី E2/63 បានបង្ហាញថា បងថ្លៃប្រុសរបស់គាត់ត្រូវបានចោទប្រកាន់ថា ជាប់ឃុំ និងសម្លាប់ចោលនៅស-២១ ។ ទោះបីជាឯកសារយើងទទួលបានព្រឹកមិញក៏ដោយ មេធាវីការពារក្ដីមានការយល់ឃើញថា ធាតុផ្សំភស្តុតាងទាំងអស់នោះពុំមានលក្ខណៈគ្រប់គ្រាន់ ដើម្បីបង្ហាញអំពីចំណងសាច់ញាតិរវាងដើមបណ្ដឹងនិងជនរងគ្រោះ ។ ហើយបន្ថែមទៅលើចំណុចនេះទៀត ធាតុផ្សំភស្តុតាងទាំងអស់នោះ មិនបានបង្ហាញថា ជនរងគ្រោះពិតជាជាប់ឃុំនៅស-២១ នោះទេ ។

ដូច្នេះហើយមេធាវីការពារក្ដី សូមបញ្ជាក់ថា ឈ្មោះរបស់ជនរងគ្រោះ ក៏មិនមានរកឃើញនៅក្នុងបញ្ជីអ្នកទោសស-២១ ផងដែរ ។ សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីក្រុមបី ។

[១១:២០:០៦]

**លោកស្រី ហ្សាប៊ីយ៉ែន ទ្រូស្សូណាព្រួស៖**

លោកប្រធានជាទីគោរព! ព្រឹកមិញ យើងបានផ្ដល់ជូនទៅមេធាវីការពារក្ដីនូវឯកសារថ្មីមួយដែលជាលិខិតធានាអះអាងពីអភិបាលក្រុង ដែលបញ្ជាក់អំពីចំណងសាច់ញាតិរបស់កូនក្ដីរបស់ខ្ញុំទៅនឹងបងថ្លៃប្រុសរបស់គាត់ ។ ជាការពិតយើងមានអារម្មណ៍យល់ឃើញថា ភស្តុតាងនោះ គឺមានតម្លៃជាភស្តុតាង ទាក់ទងទៅនឹងការបង្ហាញអំពីចំណងសាច់ញាតិ ហើយចំពោះការទំនាក់ទំនងជាប់ពាក់ព័ន្ធទៅនឹងស-២១ វិញនោះ ។ យើងពិតជាមិនឃើញមានឈ្មោះនៅក្នុងបញ្ជីអ្នកទោសពិតមែន ទោះបីជាយើងធ្វើការស្រាវជ្រាវក៏ដោយ យើងព័ត៌មានដែលយើងទទួលបានចំពោះជនរូបនេះ គឺយើងផ្អែកទៅលើការបញ្ជាក់ពីកូនក្ដីរបស់ខ្ញុំផ្ទាល់តែប៉ុណ្ណោះ ដែលគាត់បានលើកឡើងនៅក្នុងសេចក្ដីថ្លែងរបស់គាត់ថា នៅក្នុងឆ្នាំ១៩៧៨ បុគ្គលម្នាក់បានបញ្ជូនរូបថត ឪពុក និងបងប្រុសរបស់គាត់ ដែលត្រូវបានដាក់ខ្នោះច្រវាក់ ហើយមានការវះពោះ ហើយអ្នកទាំងពីរនោះស្លាប់ដូចសត្វធាតុ ។

ដូច្នេះ ចម្លើយនិងសេចក្ដីថ្លែងនោះ គឺជាសេចក្ដីថ្លែងរបស់ដើមបណ្ដឹងរដ្ឋប្បវេណី កូនក្ដីរបស់ខ្ញុំ ហើយខ្ញុំសូមអនុញ្ញាតឲ្យអង្គជំនុំជម្រះធ្វើការសម្រេចទៅលើករណី ដើមបណ្ដឹងរូបនេះ ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញមេធាវីការពារក្ដីបន្ត ។

**លោកស្រី ម៉ារីប៉ូល កានីហ្សារេស៖**

ដើមបណ្តឹងរដ្ឋប្បវេណី E2/64 បានចោទប្រកាន់ថា ពូរបស់គាត់ ហើយនិងមីងរបស់គាត់ ហើយនិងបងប្អូនជីដូនមួយប្រាំរូប ត្រូវបានឃុំខ្លួន និងសម្លាប់ចោលនៅទួលស្លែង ប៉ុន្តែពុំមានភស្តុតាងទាំងឡាយណាដែលមាននៅក្នុងសំណុំរឿងបង្ហាញអំពីចំណងសាច់ញាតិរវាងដើមបណ្តឹង និងជនរងគ្រោះ ។ ហើយនៅក្នុងករណីផងដែរ មេធាវីការពារក្តីជឿថា ឯកសារដែលបានបញ្ចូលនៅក្នុងសំណុំរឿង គឺមិនមានលក្ខណៈគ្រប់គ្រាន់បង្ហាញថា ជនរងគ្រោះពិតជាបានសម្លាប់នៅទួលស្លែងនោះទេ ។ ដើមបណ្តឹងរដ្ឋប្បវេណីបានលើកឡើងអំពីរូបថត រូបថតនោះមិនដែលបង្ហាញ និងផ្តល់ជូននោះទេ ហើយក៏មានការលើកឡើងអំពីប្រវត្តិរូបផងដែរ ប៉ុន្តែប្រវត្តិរូបនោះ គឺជាប្រវត្តិរូបដែលថតចម្លងដោយដៃសរសេរដោយដៃ ហើយវាមិនមែនចេញមកពីស-២១ នោះទេ ។

ជាថ្មីម្តងទៀត មេធាវីការពារក្តីគ្រាន់តែកត់សម្គាល់ថា ជនរងគ្រោះមួយរូបនៅក្នុងនេះគឺមិនមានឈ្មោះ នៅក្នុងបញ្ជីអ្នកទោសនៅស-២១ នោះទេ ។

[១១:២៣:៣៩]

**ប្រធានអង្គជំនុំ៖**

អញ្ជើញមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្រុមមួយ-- ក្រុមមួយ-- ក្រុមពីរៗ ។

**លោក គង់ ពិសី៖**

សូមអរគុណលោកប្រធាន ។ ខ្ញុំបាទសូមធ្វើការបំភ្លឺចំពោះដើមបណ្តឹងរដ្ឋប្បវេណីដែលមានពាក្យបណ្តឹងលេខ E2/64 នេះដូចតទៅ៖

ហើយខ្ញុំសូមជម្រាបជូនអង្គជំនុំជម្រះមេត្តាជ្រាបថា ឈ្មោះជនរងគ្រោះនេះ គឺមានឈ្មោះតែ ឃុត ផន ទេ ហើយ ឃុត ផន ហ្នឹង គឺមានប្តីឈ្មោះ ជៀប បារ៉ូ ហើយ ជៀប បារ៉ូ ហ្នឹងត្រូវជាបងប្អូនបង្កើត ជៀប ញ៉ែប ។ ហើយ ជៀប ញ៉ែប ហ្នឹង ត្រូវជាឪពុកបង្កើតរបស់ ញ៉ែប គឹមស្រ៊ា ។ អ៊ីចឹង ញ៉ែប គឹមស្រ៊ា នេះ គឺជាដើមបណ្តឹងរដ្ឋប្បវេណី ។ ហើយ ញ៉ែប គឹមស្រ៊ា នេះ ត្រូវជាក្មួយរបស់ ជៀប បារ៉ូ ហើយ ជៀប បារ៉ូ នេះ មានប្រពន្ធឈ្មោះ ឃុត ផន ។ អ៊ីចឹងនៅពេលដែលក្នុងសម័យនោះ គាត់ដឹងថា ឃុត ផន ដែលជាប្រពន្ធ ជៀប បារ៉ូ ហ្នឹង មានកូនប្រាំនាក់រស់នៅជាមួយគ្នានៅក្នុងនោះ ។

អ៊ីចឹងកាលដែលយកទៅសម្លាប់ចោល យកទៅឃុំឃាំងនៅមន្ទីរទួលស្លែងនេះ គឺថាអត់មិនមានឃើញឯកសារទាក់ទងទៅនឹង ជៀប បារ៉ូ ទេ ក៏ប៉ុន្តែមានឯកសារ មិនមានជាឯកសារទេ មានបញ្ជីអ្នក

ទោសនៅក្នុងទួលស្លែងមានតែឈ្មោះ ឃុត ផន តែប៉ុណ្ណោះទេ ។ ឃុន ផន ដែលត្រូវជាប្រពន្ធរបស់ ជៀប បារ៉ូ ។

ហេតុដូច្នេះ ខ្ញុំនឹងសូមជូនឯកសារជាក្រោយទៀតនូវបញ្ជីឈ្មោះអ្នកទោសដែលត្រូវបានគេសម្លាប់នៅទួលស្លែងដែលមានឈ្មោះអ្នកស្រី ឃុត ផន ដែលត្រូវជាប្រពន្ធរបស់ ជៀប បារ៉ូ ហើយខ្ញុំនឹងសូមជូនឯកសារបន្ថែមទាក់ទងទៅនឹង ជៀប បារ៉ូ ដែលត្រូវជាប្ដីរបស់ ឃុត ផន នេះដើម្បីឲ្យច្បាស់ថា ជៀប បារ៉ូ មានប្រពន្ធឈ្មោះ ឃុត ផន ហើយ មានឃើញ ឃុត ផន មានបញ្ជីនៅក្នុងបញ្ជីឈ្មោះសម្លាប់អ្នកទោសនៅមន្ទីរទួលស្លែងហើយ ជៀប បារ៉ូ នេះត្រូវជាបងបង្កើតរបស់ ជៀប ញិប ហើយ ជៀប ញិប ត្រូវជាឪពុកបង្កើតរបស់ ញិប គឹមស្រ៊ា ។ ហេតុដូច្នេះ សូមអង្គជំនុំជម្រះ មេត្តាទទួលយកដោយអនុគ្រោះ ។ សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញមេធាវីការពារក្ដីបន្ត ។

**លោកស្រី ម៉ារីប៉ូល កានីហ្សារេស៖**

ដើមបណ្ដឹងរដ្ឋប្បវេណី E2/65 បានចោទប្រកាន់ថា ពូរបស់គាត់ស្លាប់នៅឆ្នាំ១៩៧៧ នៅស-២១ ។ ហើយយើងមិនមានឈ្មោះពូរបស់គាត់នៅក្នុងមន្ទីរស-២១ នោះទេ ។ ដូច្នេះ មេធាវីការពារក្ដីជឿថាការបង្ហាញអំពីចំណងសាច់ញាតិរវាងពូ ហើយនិងការដែលថាជាប់នៅស-២១នោះ គឺមិនបានបង្ហាញនិងបញ្ជាក់ភស្ដុតាងឲ្យបានជឿជាក់ និងត្រឹមត្រូវនោះទេ ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីក្រុមបី ។

**លោកស្រី ហ្សាប៊ីយ៉ែន ទ្រូស្សូណាព្រូស៖**

លោកប្រធានជាទីគោរព! យើងហាក់ដូចជាចូលមកដល់ករណីមួយជាក់លាក់ ហើយវាហាក់ដូចជាបញ្ជាក់ថាចំណុចនេះវាបង្ហាញ និងលាតត្រដាងថាវាអាចកើតឡើងនៅក្នុងគ្រួសារមួយចំនួនជាក់លាក់។ ដោយសារតែយើងពុំមានឯកសារ ហើយយើងបានទៅជួបកូនក្ដីរបស់យើងទើបតែថ្មីៗនេះ ហើយយើងបានជួបគាត់ ដើម្បីធ្វើឲ្យគាត់បង្ហាញទៅលើការពិត ។ ហើយទាក់ទងទៅនឹងបុគ្គលដើមបណ្ដឹងរូបនេះ យើងឃើញថា មានការជំទាស់តវ៉ាទៅលើដើមបណ្ដឹងរដ្ឋប្បវេណី ហើយដើមបណ្ដឹងរដ្ឋប្បវេណីគឺគាត់មិនចង់ឲ្យមានការប៉ះពាល់ទៅដល់គ្រួសារគាត់ ហើយគាត់មិនដឹងថាតើមានលទ្ធភាពថាតើគួរតែធ្វើការ

បោះបង់សិទ្ធិជាដើមបណ្តឹងរដ្ឋប្បវេណី ឬក៏ទទួលនិងរក្សាជំហរ ។ ដូច្នេះហើយគឺគាត់កំពុងតែពិចារណាទៅលើជំហរទាំងអស់នេះ ។ ហើយនៅក្នុងអាទិត្យនេះ គឺគាត់នឹងបញ្ជាក់ជំហររបស់គាត់ទៅលើករណីនេះ ។ ហើយខ្ញុំនឹងជូនលោកប្រធានអង្គសវនាការឲ្យបានជ្រាបអំពីសេចក្តីសម្រេចរបស់កូនក្តីរបស់ខ្ញុំថាតើគាត់គិតយ៉ាងណាចំពោះពាក្យសុំរបស់គាត់ ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញមេធាវីការពារក្តីបន្ត ។

**លោកស្រី ម៉ារីប៉ូល កានីហ្សារេស៖**

E2/70 បានលើកឡើងថា ពូរបស់គាត់ សុខ ប៊ុន ត្រូវបានគេសម្លាប់ចោលនៅស-២១ ប៉ុន្តែយើងពុំមានធាតុផ្សំភស្តុតាង ទាក់ទងទៅនឹងដើមបណ្តឹងរូបនេះ ដែលអាចបញ្ជាក់ចំណងសាច់ញាតិ ឬក៏អាចបង្ហាញថា ជនរងគ្រោះពិតជាបានជាប់ឃុំនៅស-២១ គឺ ពូ សុខ ប៊ុន ។

**កញ្ញា ម៉ុច សុវណ្ណារី៖**

សូមគោរពលោកប្រធាន និងអង្គជំនុំជម្រះសាលាដំបូងទាំងមូលជាទីគោរព! ទាក់ទងទៅនឹងសំណុំរឿងរបស់ដើមបណ្តឹងរដ្ឋប្បវេណី E2/70 ដែលក្នុងនោះគាត់ដាក់ពាក្យបណ្តឹងដោយសារគាត់គិតថាដោយសារឪពុកមារបស់គាត់ត្រូវបានចាប់ ហើយនិងឃុំខ្លួន ព្រមទាំងសម្លាប់នៅគុកទួលស្លែង ។ ក្រុមមេធាវីរបស់យើងខ្ញុំបានព្យាយាមនៅក្នុងការស្រាវជាវរកឯកសារ ទាក់ទងជាមួយនឹងការឃុំខ្លួនរបស់គាត់នៅមន្ទីរស-២១ ហើយក៏ដូចជាឯកសារផ្សេងៗដែលអាចផ្តល់ព័ត៌មានបញ្ជាក់ពីបញ្ហានេះ ។ ហើយយើងខ្ញុំបានព្យាយាមស្រាវជ្រាវមើលនៅក្នុងបញ្ជីរបស់សហព្រះរាជអាជ្ញា បញ្ជីអ្នកទោសរួមរបស់សហព្រះរាជអាជ្ញា យើងខ្ញុំបានរកឃើញឈ្មោះអ្នកទោសមួយ ដែលមានឈ្មោះដូចគ្នាគឺឈ្មោះ សុខ ប៊ុន ដូចគ្នានៅក្នុងលេខរៀងទី9556 ។ ក៏ប៉ុន្តែ នៅពេលដែលក្រុមយើងខ្ញុំបានធ្វើការពិនិត្យទៅលើព័ត៌មានលម្អិតទាក់ទងជាមួយនឹងឈ្មោះអ្នកទោសរូបនេះ ហើយមកប្រៀបធៀបជាមួយនឹងឈ្មោះអ្នកទោសដែលមាននៅក្នុង ឈ្មោះជនរងគ្រោះដែលមាននៅក្នុងពាក្យបណ្តឹងរបស់ដើមបណ្តឹងរដ្ឋប្បវេណីយើងឃើញថា ព័ត៌មានគឺមិនដូចគ្នាទេ ។ យើងខ្ញុំមិនដឹងថា តើវាមានការភាន់ច្រឡំនៅក្នុងការទទួលបានព័ត៌មាន ឬក៏យ៉ាងណាទេ ក៏ប៉ុន្តែយើងខ្ញុំសូមទុកការទាំងអស់នេះ ជូនដល់អង្គជំនុំជម្រះជាអ្នកពិចារណា ។

ក៏ប៉ុន្តែ ប្រសិនបើយើងវិភាគទៅលើព័ត៌មានដែលកូនក្តីនាងខ្ញុំបានផ្តល់ជូនអង្គជំនុំជម្រះនៅក្នុងពាក្យបណ្តឹងរបស់គាត់ យើងនឹងឃើញនៅក្នុងពាក្យបណ្តឹងរបស់គាត់ គាត់បានបញ្ជាក់ថា នៅក្រោយ

មកនៅដើមឆ្នាំ១៩៧៨ ឈ្មោះ រឿន ជាប្រធានតំបន់១០៣ បានកោះហៅប្រជាជននិងប្រធានភូមិ មេឃុំនៅក្នុងឃុំរហ័ស ទាំងអស់មកប្រជុំ ដោយទាហានមានសុទ្ធតែកាំភ្លើងយាម មិនឲ្យអ្នកណាម្នាក់ចេញចូលទេ សូម្បីតែបត់ជើងតូចធំក៏មិនបានដែរ ។ ពេលប្រជុំចប់ពួកវាបានហៅឈ្មោះ ព្រំ ហំ, គង់,ជៀប, ជួន, ព្រំ ហ៊ឹម, រី និងឪពុកមារបស់ដើមបណ្តឹងរដ្ឋប្បវេណីរបស់ខ្ញុំ មានឈ្មោះ សុខ ប៊ុន ដែលអ្នកទាំងអស់គ្នានេះសុទ្ធតែជាប្រធានភូមិ មេឃុំ នៅសម័យប៉ុលពត ។

ប្រសិនបើយើងអានចំណុចនេះហើយ ហើយយើងធ្វើការវិភាគនូវអ្វី ដែលអង្គសវនាការទទួលព័ត៌មានពីមុនមក យើងសង្កេតឃើញថា ឃុំរហ័ស ស្រុករវៀង ខេត្តព្រះវិហារគឺស្ថិតនៅ ក្នុងតំបន់មួយនៅក្នុងភូមិភាគឧត្តរដែលតំបន់នេះវាគឺជាកម្មវត្ថុនៃការសម្រិតសម្រាំងផ្ទៃក្នុង ។ ហើយជនជាប់ចោទ ក៏គាត់បានទទួលស្គាល់ដែរហើយថា នៅពេលដែលមានការសម្រិតសម្រាំងផ្ទៃក្នុងនេះ អ្នកដែលជាកម្មវត្ថុមុខសញ្ញា ដែលជាជន ដែលជាមនុស្សដែលគេត្រូវចាប់យកមកមន្ទីរស-២១ គឺមានអ្នក ដែលនៅធ្វើការនៅក្នុងគណៈឃុំ គណៈស្រុកជាដើម ។ ហេតុដូច្នេះហើយនាងខ្ញុំយល់ឃើញថា ព័ត៌មានដែលគាត់បានផ្តល់ឲ្យនេះគឺមានការទាក់ទងនឹងអ្វីដែលបានកើតឡើងនៅសម័យនោះ ហើយវាមានការពាក់ព័ន្ធជាមួយនឹងអ្វី-- ព័ត៌មានដែលអង្គសវនាការបានទទួលមកនៅពេលមុននោះ ។

មួយវិញទៀត ទាក់ទងជាមួយនឹងទំនាក់ទំនងសាច់ញាតិ រវាងកូនក្តីនាងខ្ញុំជាមួយឪពុកមារបស់គាត់ សុខ ប៊ុន ។ ក្រោយពីបានទទួលព័ត៌មាននៃការជំទាស់អំពីមេធាវីការពារក្តីយើងខ្ញុំបានធ្វើការទំនាក់ទំនងភ្លាមជាមួយនឹងកូនក្តីយើងខ្ញុំ ហើយយើងខ្ញុំបានស្នើទៅគាត់ ដើម្បីឲ្យគាត់ធ្វើការបញ្ជាក់នូវទំនាក់ទំនងរបស់គាត់ ហើយយើងខ្ញុំកំពុងតែរង់ចាំនូវការផ្តល់មកវិញនូវឯកសាររបស់ពួកគាត់ ដោយយើងខ្ញុំរំពឹងថា គាត់នឹងផ្តល់ឯកសារទាំងអស់នោះមកយើងខ្ញុំវិញនៅក្នុងសប្តាហ៍នេះ ហើយនៅពេលដែលយើងខ្ញុំបានទទួលឯកសារនោះភ្លាម យើងខ្ញុំនឹងដាក់ជូនទៅអង្គជំនុំជម្រះដើម្បីពិចារណា ។

ការឆ្លើយតបរបស់នាងខ្ញុំសូមចប់នូវត្រឹមនេះ ហើយសូមជូននូវការពិចារណានេះ ទៅដល់អង្គជំនុំជម្រះដើម្បីពិនិត្យទៅលើភាពត្រឹមត្រូវនៃការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់គាត់ ។ នាងខ្ញុំសូមអរគុណ ។

[១១:៣៣:៣៥]

**ប្រធានអង្គជំនុំ៖**

អញ្ជើញបន្តមេធាវីការពារក្តី ។

**លោកស្រី ម៉ារីប៉ូល កានីហ្សារេស៖**

ចំពោះដើមបណ្តឹងរដ្ឋប្បវេណី E2/70 ដែលអះអាងថា បងថ្លៃរបស់គាត់បានស្លាប់នៅស-២១ ក្នុងឆ្នាំ១៩៧៦នោះ គឺនៅក្នុងករណីដើមដែរ គឺមិនមានភស្តុតាងណាមួយ នៅក្នុងពាក្យបណ្តឹងហ្នឹងដើម្បីបញ្ជាក់ថា ទំនាក់ទំនងសាច់ញាតិរវាងដើមបណ្តឹងរដ្ឋប្បវេណី ហើយនិងជនរងគ្រោះនោះទេ ។ ហើយក៏មិនមានឯកសារភស្តុតាងណាបញ្ជាក់ថា ជនរងគ្រោះត្រូវបានឃុំខ្លួននៅស-២១ នោះដែរ ជាពិសេសទៅទៀតគឺឈ្មោះជនរងគ្រោះមិនមាននៅក្នុងបញ្ជីអ្នកទោសស-២១ ទេ E2/71 នេះ ។

**លោកស្រី ហ្សាប៊ីយ៉ែន ទ្រូស្សូណាព្រូស ៖**

លោកប្រធាន ចំពោះដើមបណ្តឹងរដ្ឋប្បវេណីនេះផងដែរ យើងស្នើឲ្យមេឃុំធ្វើការបញ្ជាក់ពីទំនាក់ទំនងសាច់ញាតិរបស់គាត់ ហើយយើងកំពុងតែរង់ចាំឯកសារនោះ ហើយយើងរំពឹងថានឹងបានទទួលឯកសារនេះមុនចុងសប្តាហ៍នេះ ។ ខ្ញុំសង្ឃឹមថានឹងបានទទួលហើយដាក់ជូនឯកសារនេះជូនអង្គជំនុំជម្រះ ចំពោះទំនាក់ទំនងស-២១នោះ ដូចដែលមេធាវីការពារបញ្ជាក់នោះថាយើងមិនអាចរកឃើញឈ្មោះជនរងគ្រោះនៅលើបញ្ជីអ្នកទោសស-២១នោះមែន ។ ប៉ុន្តែ មានព័ត៌មាននិងខ្លឹមសារដែលបញ្ជាក់ពីភាពស្របគ្នាអំពីការចាប់ខ្លួនជនរងគ្រោះ បរិបទនៃការងាររបស់គាត់ ហើយយើងអាចយល់បានថាគាត់បានចាកចេញពីកន្លែងមួយដោយមិនមានការអនុញ្ញាតពីមេរបស់គាត់ ហើយបន្ទាប់មកគេបានឃាត់ខ្លួនចាប់ខ្លួនហើយបញ្ជូនទៅស-២១ ។ នៅក្នុងករណីមួយនេះយើងយល់ឃើញថា សេចក្តីប្រកាសរបស់កូនក្តីយើងអនុញ្ញាតឲ្យយើងពិចារណានិងចាត់ទុកថា ជននេះពិតជាត្រូវបានឃុំខ្លួនហើយកម្ទេចនៅស-២១ ប្រាកដមែន ។ ជាថ្មីម្តងទៀត យើងសូមអនុញ្ញាតតុលាការអង្គជំនុំជម្រះ ធ្វើសេចក្តីសម្រេចលើករណីនេះ ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញបន្តមេធាវីការពារក្តី ។

**លោកស្រី ម៉ារីប៉ូល កានីហ្សារេស៖**

ចំពោះដើមបណ្តឹងរដ្ឋប្បវេណី E2/76 ដែលបានដាក់ពាក្យសុំ ដោយសារបងប្រុសរបស់គាត់ឈ្មោះ អ៊ុំង គាំ បានរកឃើញអត្តសញ្ញាណភស្តុតាងនៅក្នុងស-២១ ចំពោះថាដើមបណ្តឹងរដ្ឋប្បវេណីហើយនិងជនរងគ្រោះនោះមានឈ្មោះនាមត្រកូលដូចគ្នា ។ ហើយក្រៅពីហ្នឹងមិនមានភស្តុតាងអ្វីដើម្បីបញ្ជាក់អំពីទំនាក់ទំនងសាច់ញាតិរវាងបុគ្គលទាំងពីរនេះទេ ។

[១១:៣៧:៣៦]

ចំពោះបញ្ហាទីពីរ ដែលថាជនរងគ្រោះត្រូវបានអះអាងថា រងគ្រោះនៅស-២១ នោះគឺថាភស្តុតាងតែមួយគត់ ដែលយើងមានក្នុងសំណុំរឿងនោះគឺថា ប្រវត្តិរូបរបស់លោក អ៊ុង គាំ តែប៉ុណ្ណោះ ។ យើងមានការលំបាក ដើម្បីបញ្ជាក់ថាចេញមកពីស-២១ នោះ ។ ជាថ្មីម្តងទៀតគឺថាអាចជាករណីដែលថាលោក អ៊ុង គាំ នេះគឺថាមិនមានឈ្មោះនៅក្នុងបញ្ជីអ្នកទោសនៅស-២១ នោះផងដែរ ។

**កញ្ញា ម៉ុច សុវណ្ណារី៖**

សូមអរគុណចំពោះការបញ្ជាក់របស់មេធាវីការពារក្តី ។ ដើម្បីឆ្លើយតបនឹងបញ្ហានេះ ទីមួយទាក់ទងជាមួយភាពពិតប្រាកដនៃព្រឹត្តិការណ៍ដែលថា តើលោក អ៊ុង គាំ ជាបងប្រុសបង្កើតរបស់លោកស្រី អ៊ុង វឿន ឬក៏ ហ៊ុល វឿន ដែលជាដើមបណ្តឹងរដ្ឋប្បវេណីនោះ គាត់បានជាប់នៅគុកទួលស្លែងមែនឬក៏អត់? យើងមានប្រវត្តិរូបសង្ខេបមួយរបស់លោក អ៊ុង គាំ ចេញពីមន្ទីរស-២១ គឺប្រវត្តិរូបសង្ខេបដែលមាននៅក្នុងឯកសារលេខ E2/76.4 ។ ប្រសិនបើយើងក្រឡេកមើលទៅលើរឿងហេតុតាំងពីដើមដែលដើមបណ្តឹងរដ្ឋប្បវេណីគាត់បានរៀបរាប់នៅក្នុងពាក្យបណ្តឹងរបស់គាត់ ។

នៅក្នុងឆ្នាំ១៩៧៤ នៅក្នុងភូមិ នៅក្នុងភូមិឈ្យូកក្រួស ឃុំឈ្យូក ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ នៅពេលនោះដើមបណ្តឹងរដ្ឋប្បវេណី គាត់បានផ្តល់ព័ត៌មានថា បងប្រុសរបស់គាត់ត្រូវបានទាហាន លន់ នល់ ចាប់ឲ្យធ្វើ ហើយបង្ខំឲ្យគាត់ ធ្វើជាទាហាន ហើយបញ្ជូនគាត់ទៅសមរភូមិ ។ ហើយយើងសង្កេតឃើញថាវាមានភាពស៊ីសង្វាក់គ្នា ជាមួយនឹងប្រវត្តិសាស្ត្រនេះដែលថានៅសម័យនុ៎ង គឺមានការប្រទាញប្រទង់គ្នារវាងកងទ័ពខ្មែរក្រហម និងកងទ័ពរបស់ លន់ នល់ ។ ហើយចំណុចមួយទៀតយើងសង្កេតឃើញថា នៅឆ្នាំ១៩៧៦ ដើមបណ្តឹងរដ្ឋប្បវេណីបានផ្តល់ព័ត៌មានថា បងប្រុសរបស់គាត់បានទៅជួបគាត់ ទៅលេងគាត់ ទៅសួរសុខទុក្ខគាត់ នៅពេលនោះយើងមិនដឹងថា តើស្ថានភាពនៃការដែលគាត់ទៅហ្នឹង គឺទៅក្នុងលក្ខណៈបែបណាទេ តើគាត់លួចទៅឬក៏យ៉ាងម៉េច? នេះគឺជារឿងហេតុដែលយើងអត់ដឹងទាំងអស់គ្នា ដោយសារគាត់បាត់ខ្លួនទៅសង្គ្រាមបាត់ ហើយគាត់បានលេចមុខមកភ្លាម ។

នៅពេលនោះគាត់បាន លោក អ៊ុង គាំ ជនរងគ្រោះហ្នឹងគាត់បានទៅជួបជាមួយនឹងម្តាយគាត់ គាត់ប្រាប់ម្តាយរបស់គាត់ថា "រូបគាត់ដែលមានប្រវត្តិធ្វើជាទាហាន លន់ នល់ គេប្រហែលជានឹងបញ្ជូនគាត់ទៅភ្នំពេញ ហើយនឹងត្រូវដាក់គុកនៅទីនោះហើយ ។ ក្រោយមកទៀត ក្រុមគ្រួសារក៏បាត់ព័ត៌មានរបស់គាត់រហូតទៅ ។ ហើយក្រោយមកទៀត ក្រុមគ្រួសាររបស់គាត់ក្រោយពីរំដោះក៏បានរកឃើញប្រវត្តិរូបនេះ ។ ដូច្នេះ នាងខ្ញុំសូមដាក់ប្រវត្តិរូបនេះឲ្យអង្គជំនុំជម្រះធ្វើការពិចារណា ។

ចំណុចទីពីរ ទាក់ទងជាមួយនឹងទំនាក់ទំនងញាតិលោហិតរវាងដើមបណ្ដឹងរដ្ឋប្បវេណី ហើយនិងជនរងគ្រោះឈ្មោះ អ៊ុង គាំ ។ ប្រសិនបើយើងក្រឡេកមើលឯកសារភស្តុតាងទាំងឡាយ ដែលដើមបណ្ដឹងរដ្ឋប្បវេណីគាត់បានដាក់ ទាក់ទងជាមួយនឹងអត្តសញ្ញាណប័ណ្ណរបស់គាត់ ទាក់ទងជាមួយនឹងទម្រង់ព័ត៌មានជនរងគ្រោះ ដែលជាពាក្យបណ្ដឹងរបស់គាត់ ទាក់ទងជាមួយនឹងប្រវត្តិរូបដែលគាត់បានដាក់ ទាក់ទងជាមួយនឹងរូបរបស់លោក អ៊ុង គាំ នៅស-២១ ហ្នឹង ហើយនិងកិច្ចសម្ភាសន៍មួយដែលធ្វើឡើងដោយបុគ្គលិករបស់អង្គការ *ឌីស៊ីខេម* ហើយនិងម្ដាយរបស់គាត់ យើងសង្កេតព័ត៌មាននៅក្នុងហ្នឹង ទាក់ទងជាមួយនឹងអាសយដ្ឋានគឺតែមួយៗ ។ អាសយដ្ឋានដែលផ្ដល់ឲ្យនៅក្នុងរូបរបស់លោក អ៊ុង គាំ គឺដូចគ្នានឹងអាសយដ្ឋានដែលផ្ដល់ឲ្យនៅក្នុងកិច្ចសម្ភាសន៍ជាមួយនឹងម្ដាយគាត់ ហើយក៏ដូចគ្នាជាមួយនឹងអាសយដ្ឋានដែលមាននៅក្នុងអត្តសញ្ញាណប័ណ្ណរបស់ដើមបណ្ដឹងរដ្ឋប្បវេណី។ នេះក៏ជាចំណុចមួយដែលអាចធ្វើឲ្យយើងពិចារណានូវទំនាក់ទំនងសាច់ញាតិរវាងដើមបណ្ដឹងរដ្ឋប្បវេណី ហើយនិងជនរងគ្រោះឈ្មោះ អ៊ុង គាំ ។

មួយវិញទៀត នៅក្នុងប្រវត្តិរូបរបស់លោក អ៊ុង គាំ យើងសង្កេតឃើញគាត់បានប្រាប់ថា ម្ដាយរបស់គាត់មានឈ្មោះថា ហ៊ុល សឿន ហើយប្រសិនបើយើងក្រឡេកមើលនៅក្នុងកិច្ចសម្ភាសន៍ រវាងម្ដាយរបស់គាត់ជាមួយនឹងបុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជា យើងនឹងឃើញមានឈ្មោះដូចគ្នា ហើយម្ដាយរបស់គាត់បានប្រាប់ថា សព្វថ្ងៃនេះគាត់រស់នៅជាមួយនឹងកូនស្រីរបស់គាត់ម្នាក់ ។ នេះក៏ជាកត្តាមួយដែលអាចធ្វើឲ្យយើងពិចារណាអំពីអាទិភាពនៃទំនាក់ទំនងសាច់ញាតិលោហិត រវាងដើមបណ្ដឹងរដ្ឋប្បវេណីជាមួយនឹងជនរងគ្រោះឈ្មោះ អ៊ុង គាំ ។

ហើយម៉្យាងទៀត ដើម្បីបញ្ជាក់ឲ្យកាន់តែច្បាស់ថាពួកគាត់ពិតជាមានទំនាក់ទំនងញាតិលោហិតមែន ក្រុមមេធាវីរបស់យើងខ្ញុំបានស្នើសុំទៅកូនក្ដីម្នាក់នេះ ដើម្បីឲ្យគាត់ធ្វើលិខិតបញ្ជាក់បន្ថែមដើម្បីបំបាត់នូវការសង្ស័យទាក់ទងជាមួយនឹងទំនាក់ទំនងញាតិលោហិតនេះ ។ នាងខ្ញុំសូមអរគុណ ។

[១១:៤២:០០]

**ប្រធានអង្គជំនុំ៖**

អញ្ជើញបន្តមេធាវីការពារក្ដី ។

**លោកស្រី មារីប៉ូល កានីហ្សារេស៖**

ចំណុចតទៅនេះ គឺពាក្យបណ្ដឹងរបស់ E2/77 ហើយយើងមិនពិនិត្យឃើញថា មានភស្តុតាងអ្វី

ទាល់តែសោះ ដែលបញ្ជាក់អំពីទំនាក់ទំនងសាច់ញាតិ ហើយនិងមានជនរងគ្រោះនៅស-២១ នេះ ។ ដូច្នេះ ខ្ញុំសូមអនុញ្ញាតបញ្ជាក់ថា ឈ្មោះជនរងគ្រោះ ក៏មិនមាននៅក្នុងបញ្ជីអ្នកទោសរបស់ស-២១ នោះដែរ ។

**លោក អាឡាំង វ៉ែនណឺ៖**

លើកលែងតែខ្ញុំច្រឡំ គឺថា E2/77 នោះមិនបានលើកឡើងដោយមេធាវីការពារនោះទេពីខាងដើម ។ តើជាចំណុចមួយដែលយើងមានការភ្ញាក់ផ្អើល ថាតើមេធាវីការពារអាចបញ្ជាក់បំភ្លឺអ្វីបន្ថែមបានដែរឬទេពីចំណុចនេះ?

**ប្រធានអង្គជំនុំ៖**

អញ្ជើញមេធាវីការពារ ។

**លោកស្រី មារីប៉ូល កានីហ្សារេស៖**

លើកលែងតែខ្ញុំមានការភាន់ច្រឡំ ខ្ញុំជឿជាក់ថា ដើមបណ្តឹងរដ្ឋប្បវេណី E2/77 នេះគឺត្រូវបានធ្វើសវនាការលើគាត់រួចហើយ ។ ហើយឃើញថាមានការបដិសេធ ប៉ុន្តែយើងមិនបានធ្វើសវនាការគាត់ទេ អ៊ីចឹងហើយមេធាវីការពារមិនបានធ្វើសេចក្តីសង្កេតទៅលើគាត់ទេនៅពេលនោះ ។ អ៊ីចឹងហើយ ខ្ញុំសូមអនុញ្ញាតដើម្បីដាក់បញ្ចូលទៅក្នុងដើមបណ្តឹងរដ្ឋប្បវេណី ដែលមិនទាន់បានធ្វើសវនាការនៅក្នុងការជំទាស់តវ៉ារបស់យើង ។

**ប្រធានអង្គជំនុំ៖**

ម៉េចទៅបញ្ហាអ៊ីចេះ E2/77 គឺក្នុងចំណោមដើមបណ្តឹងរដ្ឋប្បវេណីដែលត្រូវមកធ្វើសេចក្តីថ្លែងការណ៍នៅចំពោះមុខអង្គជំនុំជម្រះ ប៉ុន្តែមិនបានមកទេលះបង់ក្នុងការអញ្ជើញមកធ្វើសេចក្តីថ្លែងការណ៍នៅចំពោះមុខអង្គជំនុំជម្រះ ។ អ៊ីចឹងហើយកិច្ចការទាំងអស់នេះ គឺយើងមិនបានធ្វើការតទល់ទេ។ មូលហេតុដើមគឺ ការបង្ហាញដំបូង គឺដូច្នេះមែន ។ ប៉ុន្តែការបង្ហាញពីម្សិលមិញ គឺបានបង្ហាញច្បាស់លាស់អំពីការបំពេញបន្ថែមនូវ E2/77 ដែលជាបន្ថែមនូវដើមបណ្តឹងរដ្ឋប្បវេណី ដែលមានការលះបង់សិទ្ធិក្នុងការធ្វើសេចក្តីថ្លែងការណ៍នៅចំពោះមុខអង្គជំនុំជម្រះ ។

បញ្ហានេះថាតើមេធាវីតំណាងឲ្យដើមបណ្តឹងរដ្ឋប្បវេណីអាចធ្វើការបង្ហាញនូវហេតុផលនៃការបណ្តឹងករណីនេះបានទេ ឬក៏មានសំណូមពរយ៉ាងម៉េចចំពោះករណីនេះ ។

[១១:៤៥:៤៦]

**លោក អាឡាំង វែនណឺ៖**

សូមគោរពលោកប្រធាន ។ តាមដែលខ្ញុំយល់នោះ ដើមបណ្តឹងរដ្ឋប្បវេណីនេះ គឺនៅក្នុងក្រុមទីពីរ នេះជាករណីមួយដែលខ្ញុំមិនអាចផ្តល់ព័ត៌មានអ្វីបន្ថែមជូនអង្គជំនុំជម្រះបានទេ ។

**ប្រធានអង្គជំនុំ៖**

មេធាវីក្រុមពីរ ។

**លោក គង់ ពិសី៖**

សូមអភ័យទោសលោកប្រធាន ខ្ញុំបាទសូមជាអធ្យាស្រ័យ ដោយសារតែព័ត៌មាននេះខ្ញុំមិនបានទទួលមុន ដូច្នេះ ខ្ញុំមិនអាចឆ្លើយបានទេ ។ សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

លោកអាចឆ្លើយពេលណាបាន?

**លោក គង់ ពិសី៖**

ហើយខ្ញុំនឹងឆ្លើយទៅថ្ងៃក្រោយទៀត នៅពេលដែលអង្គជំនុំជម្រះត្រូវការបាទ ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះដំណើរការថ្ងៃនេះ បើមិនចប់ទេនឹងលើកបន្តទៅព្រឹកថ្ងៃស្អែក អ៊ីចឹងពេលវេលាមានតែព្រឹកថ្ងៃស្អែកប៉ុណ្ណោះ ។

ហើយបញ្ហានេះ គឺបានបង្ហាញច្បាស់លាស់ហើយនៅពេលការបង្ហាញអំពីមតិក្នុងការប៉ុនប៉ងតវ៉ាទៅលើដើមបណ្តឹងរដ្ឋប្បវេណីនេះ គឺគេបានថ្លែងបញ្ជាក់បន្ថែមយ៉ាងច្បាស់លាស់ ដោយសារមានការប្រែប្រួលនៃកិច្ចដំណើរការនីតិវិធីសវនាការកន្លងមក រវាងដំណើរការនៃការលះបង់សិទ្ធិនៅក្នុងការមកចូលរួម ដើម្បីធ្វើសេចក្តីថ្លែងការណ៍នៅចំពោះអង្គជំនុំជម្រះ ដោយការកត់សម្គាល់ហ្នឹង គឺភាគីមេធាវីការពារក្តីគិតថា ប្រសិនបើគាត់មានការមកធ្វើសេចក្តីថ្លែងការណ៍នោះ គឺមានការតទល់គ្នា មានការពិភាក្សាដេញដោលនៅចំពោះមុខបាន ។

អ៊ីចឹងទេ គឺជម្រាបលោកថា ពេលវេលាដែលសមស្របគឺមានតែមួយព្រឹកគឺព្រឹកថ្ងៃស្អែក ប្រហែលជាអាចមិនដល់មួយព្រឹកផងទេ បើសិនបើល្បឿននៃដំណើរការដេញដោលនេះមានល្បឿនដូចពេលនេះ។ អ៊ីចឹងសូមលោកត្រៀមខ្លួន អង្គជំនុំជម្រះយល់ស្របថា ថ្ងៃស្អែកសមស្របសម្រាប់ការងាររបស់លោកនេះ ។

**លោក គង់ ពិសី៖**

សូមអរគុណលោកប្រធាន បាទ ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញមេធាវីការពារក្តីបន្ត ។

**លោកស្រី មារីប៉ូល កានីហ្សារេស៖**

E2/81 មានការអន្តរាគមន៍ ដែលថាឪពុករបស់គាត់ ជីតារបស់គាត់ អ៊ំ សុបិន ឪពុកឈ្មោះ អ៊ំ ចត គឺថាឯកសារមួយចំនួន ដែលបានផ្តល់មកយើងនៅព្រឹកនេះ គឺថាមេធាវីបានទទួល រូបថត យើងមិនដឹងថាជារូបថតរបស់អ្នកណាទេ ថាឯកសារទាំងអស់នេះ មិនមានលក្ខណៈគ្រប់គ្រាន់ដើម្បីបញ្ជាក់ពីទំនាក់ទំនងសាច់ញាតិរវាងដើមបណ្តឹងរដ្ឋប្បវេណី និងជនរងគ្រោះទេ ។ ជាពិសេសទៅទៀត មិនមានឯកសារភស្តុតាងណាមួយក្នុងសំណុំរឿង ដែលបញ្ជាក់ពីហេតុការណ៍ដែលថា ជនរងគ្រោះពិតជាបានត្រូវគេឃុំខ្លួននៅស-២១ នោះទេ ។ ប៉ុន្តែដើម្បីបំភ្លឺពីបញ្ហានេះ មេធាវីការពារសូមបញ្ជាក់ថា នៅថ្ងៃទី១២ ខែសីហា ឆ្នាំ២០០៩ ឯកសារហ្នឹងត្រូវបានលើកឡើងមកនិយាយ ប៉ុន្តែឯកសារទាំងអស់នេះ គឺមានតែជាភាសាខ្មែរទេ មិនមានការពាក់ព័ន្ធទៅនឹងជនរងគ្រោះដែលលើកឡើងនោះទេ ។ ប៉ុន្តែទំនងជានិយាយអំពីឪពុកមាមួយឈ្មោះ សុបិន នោះគឺថាមិនមែនជា ជីតា ឬក៏ជាឪពុក ឬក៏ឪពុកធំ ហើយឈ្មោះទាំងបីនេះ មិនមានស្ថិតនៅក្នុងបញ្ជីអ្នកទោសរបស់ស-២១ នោះទេ ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញមេធាវី ។

[១១:៥០:២៥]

**កញ្ញា ម៉ុច សុវណ្ណារី៖**

សូមអរគុណលោកប្រធាន ។

មុននឹងឆ្លើយតបជាមួយនឹងបញ្ហាដែលមេធាវីការពារគាត់បានលើកឡើង ទីមួយទាក់ទងជាមួយនឹងទំនាក់ទំនងរវាងជនរងគ្រោះទាំងបី ជាមួយនឹងមន្ទីរស-២១ ។ ទីពីរ ទាក់ទងជាមួយនឹងទំនាក់ទំនងញាតិលោហិតរវាងដើមបណ្តឹងរដ្ឋប្បវេណី ហើយនិងជនរងគ្រោះទាំងអស់នោះ ។ នាងខ្ញុំសូមធ្វើការពន្យល់ជូនដល់អង្គសវនាការទាំងមូលនូវមូលហេតុដែលដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ គាត់បានសម្រេចចិត្តនៅក្នុងការបោះបង់ការស្តាប់ចម្លើយរបស់គាត់ចោល កាលពីសវនាការនៅពេលកន្លងមកនេះ ។

កាលពីពេលនោះ ដោយសារតែនៅក្នុងសំណុំរឿងរបស់គាត់ ទោះបីជាមានការខំស្រាវជ្រាវរកឯកសារយ៉ាងក៏ដោយ គឺពួកយើងមិនអាចរកឃើញនូវឯកសារ ដែលគាំទ្រពាក្យបណ្ដឹងរបស់គាត់នេះបាន ។ ហេតុដូច្នេះហើយ យើងបានសម្រេចចិត្តដើម្បីនឹងដកចេញនូវការស្ដាប់ចម្លើយរបស់ពួកគាត់ ។ ក៏ប៉ុន្តែនៅពេលថ្មីៗនេះ តាមរយៈការស្រាវជ្រាវរបស់ដើមបណ្ដឹងរដ្ឋប្បវេណី នៅក្នុងឯកសារនៃសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង គាត់បានរកឃើញឯកសារមួយ ដោយឯកសារនោះ គឺជាប្រវត្តិរូបអ្នកទោសជាប់ឃុំឃាំង។ ហើយឯកសារនេះក្រុមមេធាវីរបស់យើងខ្ញុំបានដាក់ជូនទៅដល់អង្គសវនាការ គឺនៅក្នុងឯកសារដែលមានលេខ E2/81.3 ERN 00362274 វាគឺជាប្រវត្តិរូបអ្នកទោសជាប់ឃុំឃាំងនៅទួលស្លែង ។ ហើយដើមបណ្ដឹងរដ្ឋប្បវេណីគាត់បានបញ្ជាក់ អំពីទំនាក់ទំនងសាច់ញាតិរបស់គាត់នៅក្នុងឯកសារលេខ E2/81.2 គាត់បានបញ្ជាក់ថា ជនរងគ្រោះឈ្មោះ ពត ម៉ុយ ដែលមាននៅក្នុងប្រវត្តិរូបអ្នកទោសជាប់ឃុំឃាំង គឺជាជីតារបស់គាត់ ។

អ្វីដែលនៅខ្វះនៅពេលនេះៗ គឺទាក់ទងជាមួយនឹងការបញ្ជាក់ថា គាត់គឺពិតជាសាច់ញាតិជាមួយនឹងជនរងគ្រោះឈ្មោះ ពត ម៉ុយ មែន ។ ហើយយើងខ្ញុំបានស្នើសុំឲ្យគាត់ ដើម្បីឲ្យធ្វើលិខិតនេះ ហើយយើងខ្ញុំរំពឹងថាវានឹងមកដល់នៅក្នុងអាទិត្រក្រោយនេះ ហើយយើងខ្ញុំនឹងដាក់ជូនទៅដល់អង្គសវនាការទៅដល់អង្គជំនុំជម្រះនៅពេលដែលយើងខ្ញុំទទួលបានភ្លាម ។

ទាក់ទងជាមួយនឹង-- ក្រោយមកទៀតនៅពេលដែលយើងរកបានប្រវត្តិរូបរបស់គាត់ហើយ គាត់បានធ្វើការ-- ក្រុមមេធាវីរបស់យើងខ្ញុំបានធ្វើការស្រាវជ្រាវរកទៀត ។ យើងមិនបោះបង់ចោលការស្រាវជ្រាវរបស់យើងទេ ។ នៅពេលនោះយើងបានចូលទៅក្នុងឯកសាររូបថតរបស់សហព្រះរាជអាជ្ញា នៅពេលមួយយើងបានឃើ រូបថតមួយដែលវាស្រដៀង ដែលវាដូចគ្នាជាមួយនឹងរូបថតរបស់ឪពុកជនរងគ្រោះដែលមានឈ្មោះ អាំ ផាត់ ។

[១១:៥២:៥៨]

ប្រសិនបើលោកប្រធានអនុញ្ញាត នាងខ្ញុំសូមបង្ហាញដើម្បីធ្វើការប្រៀបធៀបភាពដូចគ្នានៃរូបថតអ្នកទោសដែលគាត់រកបាននៅក្នុងឯកសាររូបថតរបស់សហព្រះរាជអាជ្ញា ហើយនិងរូបថតដែលគាត់បានដោយដើមបណ្ដឹងរដ្ឋប្បវេណីគាត់បានផ្ដល់ជូនយើងខ្ញុំថាគឺជាមនុស្សតែមួយ បើសិនជាលោកប្រធានអនុញ្ញាត នាងខ្ញុំសូមបង្ហាញជូននៅពេលនេះ ។

**ប្រធានអង្គជំនុំ៖**

អនុញ្ញាតមន្ត្រីតុលាការយករូបថតពីមេធាវីក្រុមបី យកមកដាក់បញ្ចាំងនៅម៉ាស៊ីនស្គាយ ដើម្បីបង្ហាញរូបនៅលើកញ្ចក់អេក្រង់ទូរទស្សន៍ ។

**កញ្ញា ម៉ុច សុវណ្ណារី៖**

នាងខ្ញុំសូមជម្រាបជូនលោកប្រធានដែរ ដោយសាររូបថតដែលនាងខ្ញុំព្រីនចេញពីឯកសារនៅក្នុងកុំព្យូទ័រពីឯកសាររបស់ព្រះរាជអាជ្ញាហ្នឹងមានទំហំតូច ប្រសិនបើវាមានការលំបាកនៅក្នុងការមើលនាងខ្ញុំនឹងសូមឲ្យ-- សុំជំនួយពីខាងសោតទស្សន៍វិញ នាងខ្ញុំនឹងផ្តល់លេខកូដ ដើម្បីឲ្យគាត់បញ្ចាំងមកវិញ បើសិនជាមានការអនុញ្ញាតពីលោកប្រធាន បើសិនជាគិតថា រូបថតនេះវាមិនច្បាស់លាស់គ្រប់គ្រាន់ ។

រូបថតនេះ គឺជារូបថតឪពុករបស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ អាំ ផាត់ ដែលយើងខ្ញុំទទួលបានពីដើមបណ្តឹងរដ្ឋប្បវេណី ។ ហើយដើមបណ្តឹងរដ្ឋប្បវេណី គាត់នឹងធ្វើការផ្តល់នូវលិខិតបញ្ជាក់អំពីទំនាក់ទំនងញាតិលោហិតរបស់គាត់នៅពេល ប្រហែលជាសប្តាហ៍ក្រោយនេះ នៅពេលដែលគាត់អាចធ្វើបាន ។

នេះគឺជារូបថតរបស់ឪពុកដើមបណ្តឹងរដ្ឋប្បវេណី ដែលក្រុមយើងខ្ញុំបានរកឃើញនៅក្នុងឯកសាររូបភាពរបស់សហព្រះរាជអាជ្ញា ។

[១១:៥៥:០០]

**ប្រធានអង្គជំនុំ៖**

តទៀតមន្ត្រីតុលាការដករូបភាពចេញ បង្វិលរូបនេះធម្មតាឡើងវិញ ។

**កញ្ញា ម៉ុច សុវណ្ណារី៖**

នាងខ្ញុំសូមអរគុណលោកប្រធាន ។ រូបថតទាំងអស់នេះ ក្រុមនាងខ្ញុំបានផ្តល់ជូនទៅឲ្យមេធាវីការពារ ដើម្បីគោរពទៅតាមគោលការណ៍ចំពោះមុខ ។ ហើយក្រុមនាងខ្ញុំនឹងដាក់ជូនដល់អង្គជំនុំជម្រះនូវឯកសារទាំងអស់នេះ នៅក្នុងអំឡុងពេលថ្ងៃនេះ ឬក៏ថ្ងៃស្អែក ដែលខាងក្រុមយើងខ្ញុំកំពុងតែរៀបចំដាក់ទៅហើយ ។

នេះមួយទៀត ហើយមួយទៀត ប្រសិនបើយើងក្រឡេកមើលទៅក្នុងព័ត៌មាននៅក្នុងពាក្យបណ្តឹងដែលដើមបណ្តឹងរដ្ឋប្បវេណីគាត់បានផ្តល់ឲ្យ ។ យើងនឹងឃើញភាពស៊ីសង្វាក់គ្នាពិតប្រាកដនៃព័ត៌មានដែលគាត់ផ្តល់ឲ្យជាមួយនឹងហេតុការណ៍ទាំងឡាយ ដូចថាអាចថាលក្ខណៈប្រវត្តិសាស្ត្រ ដែលអង្គ

សវនាការទទួលបានតាមរយៈសវនាការកន្លងមក ។ នៅក្នុងនោះ គាត់បាននិយាយថា ពួកគាត់គឺរស់នៅក្នុងស្រុករមាសហែក នៅក្នុងខេត្តស្វាយរៀង ។

ប្រសិនបើយើងមើលទីតាំងនេះ យើងនឹងឃើញថានៅពេលនោះ ស្រុករមាសហែក ខេត្តស្វាយរៀង គឺនៅក្រោមការដឹកនាំរបស់ សោ ភឹម ។ ហើយយើងនឹងពិចារណាតទៅទៀត យើងនឹងឃើញថាកន្លែងនោះទៀតហើយ ជាមុខសញ្ញានៃការសម្រិតសម្រាំងផ្ទៃក្នុង ពីព្រោះថាបុគ្គលម្នាក់ត្រូវបក្សកុម្មុយនីស្តកម្ពុជាចាប់ខ្លួន ហើយអ្វីបានជាបក្សកុម្មុយនីស្តនោះមិនចាប់បន្តទៀតនៅខ្សែក្រោមរបស់គាត់? យើងឃើញថាជីតារបស់ជនជាប់-- របស់ដើមបណ្ដឹងរដ្ឋប្បវេណីដែលគាត់បានផ្ដល់នៅក្នុងពាក្យបណ្ដឹងរបស់គាត់ ឈ្មោះ អាំ សាប៊ីន ត្រូវបានគេបង្ខំឲ្យចូលបម្រើទ័ពខ្មែរក្រហម ហើយក្រោមការដឹកនាំរបស់បុគ្គលឈ្មោះ សោ ភឹម ។ ឪពុករបស់គាត់ អាំ ធាត់ រូបថតអម្បាញ់មិញហ្នឹង ក៏ត្រូវបានគេឲ្យចូលធ្វើជាមេសន្តិសុខនៅសម័យខ្មែរក្រហមនោះដែរ ។ ហើយនៅពេលដែល នៅពេលក្រោយមកទៀត គាត់ផ្ដល់ព័ត៌មានថានៅក្នុងឆ្នាំ១៩៧៧ ពេលហ្នឹងមានពួកនិរតីចូលទៅក្នុងតំបន់នោះ ។ ហើយពួកនិរតីនៅពេលដែលគេចូលទៅដល់ភ្លាម គេចាប់ផ្ដើមដើរចាប់ប្រជាជន គេចាប់ផ្ដើមដើរចាប់អ្នកដែលមនុស្សជាច្រើនទៀត ហើយនៅពេលមួយគេបានហៅជីតារបស់ដើមបណ្ដឹងរដ្ឋប្បវេណីនិងឪពុកដើមបណ្ដឹងរដ្ឋប្បវេណីហ្នឹង ទៅជុំនៅគណៈស្រុក នៅស្រុករមាសហែកហ្នឹងហើយ គេក៏ចាប់ខ្លួនគាត់ ។ ហើយយើងសង្កេតឃើញថា នៅពេលនោះគេមិនត្រឹមតែចាប់ប៉ុណ្ណឹង ហើយប្រសិនយើងមើលតួនាទីរបស់ឪពុក ហើយនិងជីតារបស់ដើមបណ្ដឹងរដ្ឋប្បវេណី យើងនឹងឃើញថាគាត់មានមុខតំណែងនៅក្នុងគណៈឃុំ នៅក្នុងគណៈស្រុករមាសហែក ។

ហើយបើសិនយើងមើលតាមដានព័ត៌មានដែលគាត់បានផ្ដល់ឲ្យទៀត នៅពេលដែលក្រោយពេលមានដែលចាប់ខ្លួនឪពុក ហើយនិងជីតារបស់ដើមបណ្ដឹងរដ្ឋប្បវេណីហើយ យើងសង្កេតឃើញថាពួកនិរតីដែលចូលនោះ គេចាប់ផ្ដើមជម្លៀសប្រជាជនហ្នឹង តាំងពីដើមហ្នឹងចេញរហូត ។ នៅក្នុងនោះ ក៏បានផ្ដល់ព័ត៌មានមានការជម្លៀសពីរបីដំណាក់ ជម្លៀសគ្រួសាររបស់ដើមបណ្ដឹងរដ្ឋប្បវេណី គឺចេញ ។

ដូច្នេះ យើងសង្កេតឃើញថាព័ត៌មានដែលគាត់បានផ្ដល់ឲ្យនៅក្នុងពាក្យបណ្ដឹងហ្នឹង គឺវាមានតម្លៃគ្រប់គ្រាន់ ដែលអាចឲ្យយើងជឿបានថាអ្វីដែលគាត់និយាយគឺជាការពិត ។

ដូច្នេះ នាងខ្ញុំសូមអស់ប៉ុណ្ណោះ ហើយនាងខ្ញុំសូមដាក់ការវិភាគ ហើយនិងឯកសារភស្តុតាងទាំងអស់នេះជូនដល់អង្គជំនុំជម្រះ ដើម្បីធ្វើសម្រេចពិចារណាទៅលើភាពត្រឹមត្រូវនៃពាក្យសុំតាំងខ្លួនរបស់

គាត់ ។ នាងខ្ញុំសូមអរគុណ ។

[១១:៥៨:២៨]

**ប្រធានអង្គជំនុំ៖**

អញ្ជើញបន្ត មេធាវីការពារ ។

**លោកស្រី មារីប៉ូល កាណាហ្សារេស៖**

ចំពោះដើមបណ្តឹងរដ្ឋប្បវេណី E2/82 មិនមានព័ត៌មានអ្វីសំខាន់ច្រើននោះទេ ហើយមិនមានអ្វីបញ្ជាក់ពីទំនាក់ទំនងសាច់ញាតិរវាងដើមបណ្តឹងរដ្ឋប្បវេណីនិងជនរងគ្រោះ ហើយមិនមានអ្វីបញ្ជាក់ថាជនរងគ្រោះនោះ ពិតជាបានរងគ្រោះនៅស-២១ ហើយជនរងគ្រោះ ក៏មិនមានឈ្មោះនៅលើបញ្ជីអ្នកទោសរបស់ស-២១ ដែរ ។

**កញ្ញា ម៉ុច សុវណ្ណារី៖**

នាងខ្ញុំអរគុណ ។ ដូចដែលខាងសហភាតារបស់នាងខ្ញុំ មេធាវីអន្តរជាតិ គាត់បានលើកឡើងពីដំបូងនូវការកត់សម្គាល់ជាដំបូងរបស់គាត់ ទាក់ទងហើយខាងព្រះរាជអាជ្ញា ក៏គាត់បានគាំទ្រ ដោយថាបញ្ជីរួមអ្នកទោសដែលព្រះរាជអាជ្ញាបានរៀបចំឡើង មិនមែនជាបញ្ជីដែលគ្រប់គ្រាន់នោះទេ គឺវាមានការខ្វះខាតមិនមែនមានន័យថា អ្នកទោសដែលមិនមានឈ្មោះនៅក្នុងបញ្ជីនោះ គេមិនមែនជាអ្នកទោសនៅក្នុងមន្ទីរស-២១នោះទេ នេះគឺជាចំណុចមួយ ។ ហើយចំណុចមួយទៀត បើសិនជាយោងតាមវិធាន ៨៧ យើងសង្កេតឃើញថាភស្តុតាងគឺអាចផ្តល់ឲ្យនៅក្នុងព្រហ្មទណ្ឌ គឺដោយតាមគ្រប់មធ្យោបាយទាំងអស់ ភស្តុតាងគឺដោយសេរី ។

ដូច្នេះ វាមិនមានការសង្ស័យទេ នៅពេលដែលអង្គជំនុំជម្រះធ្វើពិចារណាទៅលើព័ត៌មានទាំងឡាយដែលបានផ្តល់ឲ្យដោយដើមបណ្តឹងរដ្ឋប្បវេណី នៅក្នុងពាក្យបណ្តឹងរបស់គាត់ ។ ដើមបណ្តឹងរដ្ឋប្បវេណីម្នាក់នេះ គាត់មានឈ្មោះថា លោក ម៉ន សុធា ។ គាត់បានបាត់បង់ម្តាយរបស់គាត់ ឈ្មោះ សែន សុខលីម នៅក្នុងសម័យខ្មែរក្រហម ។ នៅពេលដែលគេជម្លៀស កំពុងតែជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ ។

ប្រសិនបើ យើងមើលអំពីតួនាទីម្តាយរបស់គាត់ លោកស្រី សែន សុខលីម យើងនឹងឃើញថាម្តាយរបស់គាត់គឺជាអតីតបុគ្គលិកស្ថានទូតហ្វីលីពីនប្រចាំនៅប្រទេសខ្មែរ ។ គាត់មានគម្រោងដើម្បីនឹងនាំគ្រួសាររបស់គាត់ទាំងមូលទៅរស់នៅប្រទេសហ្វីលីពីន ។ ក៏ប៉ុន្តែ ដំណើររបស់គាត់ត្រូវបានអាក់ខាន

ដោយសារមានការទម្លាក់គ្រាប់បែក ហើយនៅថ្ងៃទី១៧ មេសា ដោយជ័យជម្នះរបស់កងទ័ពខ្មែរក្រហម គាត់មិនអាចទៅទាន់ជើងយន្តហោះ ហើយប្តីរបស់គាត់ក៏មិនអាចមិនទាន់ពេលវេលាដែរ ។

យើងមើលនៅក្នុងពាក្យបណ្តឹងរបស់គាត់ គេបាននិយាយថា នៅតាមផ្លូវពេលដែលខ្មែរក្រហមជម្លៀសគាត់ ។ លោកស្រី សែន សុខលីម ក៏បានតវ៉ាជាមួយនឹងកងទ័ពខ្មែរក្រហម គាត់ថាតើធ្វើបដិវត្តន៍យ៉ាងម៉េចបានជាជម្លៀសប្រជាជនដូចជាសត្វធាតុអ៊ីចឹង? ឋានៈប៉ុនខ្ញុំនេ៎ វាសមតែលោកយកឡានមកដឹកខ្ញុំទេ មិនសមឲ្យដើរបៀបនេះទេ ។ ហើយគាត់បានប្រាប់កងទ័ពខ្មែរក្រហមទៀតថា គាត់ចង់ទៅធ្វើការនៅភ្នំពេញ ដើម្បីកែប្រែរបបព្រៃផ្សៃបែបនេះ ។ ហើយកងទ័ពខ្មែរក្រហម ពិតជាបានបញ្ជូនគាត់ទៅក្រុងភ្នំពេញវិញ ។

[១២:០១:៣៣]

ឥឡូវ យើងពិចារណាទាំងអស់គ្នា ថាតើគេបញ្ជូនគាត់ទៅទីក្រុងភ្នំពេញ គេយកគាត់ទៅដាក់កន្លែងណា? អ្នកចេះដឹងដូចជាគាត់ អ្នកដែលប្រឆាំងយ៉ាងចេញមុខទៅនឹងរបបខ្មែរក្រហម ដូចជាគាត់តើគេយកគាត់ទៅដាក់នៅកន្លែងណា? ប្រសិនបើ យើងពិនិត្យទៅលើព័ត៌មានដែលជនជាប់ចោទ គាត់បានផ្តល់ជូនអង្គសវនាការវិញ ។ គាត់បានប្រាប់យើងជាច្រើន ជាហូរហែយ៉ាងលម្អិតជាមួយនឹងគោលនយោបាយកម្ទេចខ្មាំងរបស់បក្សកុម្មុយនីស្តកម្ពុជា ។ ហើយគាត់ក៏បានប្រាប់ថា មន្ទីរស-២១ គឺជាយន្តការឧក្រិដ្ឋកម្មមួយរបស់បក្សកុម្មុយនីស្តកម្ពុជាដើម្បីកម្ទេចខ្មាំង ហើយនៅក្នុងមន្ទីរស-២១ នោះហើយតួនាទីសំខាន់របស់គាត់ផ្សេងពីការកម្ទេចខ្មាំងហើយ គឺការស្វែងរកខ្សែក្បត់របស់ខ្មាំងតាមរយៈការធ្វើទារុណកម្មដើម្បីទារយកចម្លើយ ។

ដូច្នេះហើយ តាមព័ត៌មានដែលបានផ្តល់ឲ្យនេះ យើងសង្កេតឃើញថា ហើយដើមបណ្តឹងរដ្ឋប្បវេណីក៏គាត់ដឹងដែរថា គេបញ្ជូនម្តាយរបស់គាត់ទៅភ្នំពេញ គេមិនសម្លាប់ភ្លាមដោយសារគេចង់ស៊ើបរកខ្សែធំរបស់គាត់ ។ ហេតុដូច្នេះ ហើយព័ត៌មានទាំងអស់ នាងខ្ញុំជឿថាជាព័ត៌មានពិត ហើយដែលអាចមានតម្លៃជឿបាន ។

ដូច្នេះ នាងខ្ញុំសូមដាក់ព័ត៌មានទាំងអស់នេះ ជូនទៅដល់អង្គសវនាការដើម្បីធ្វើការពិចារណា ហើយនាងខ្ញុំក៏មិនបោះបង់នៅក្នុងការស្រាវជ្រាវរកឯកសារបន្ថែមទៀត ដើម្បីនឹងគាំទ្រពាក្យសុំរបស់គាត់ ហើយនាងខ្ញុំសុំរក្សាសិទ្ធិនៅពេលណាដែលនាងខ្ញុំបានទទួលឯកសារទាំងអស់នោះបន្ថែម នាងខ្ញុំនឹងដាក់ជូនទៅអង្គសវនាការភ្លាម ។

ហើយមួយទៀត ឆ្លើយតបទៅនឹងសំណួររបស់មេធាវីការពារក្តី ទាក់ទងនៅនឹងជាមួយទំនាក់ទំនងញាតិលោហិត ដូចគ្នាជាមួយនឹងកូនក្តីដទៃទៀតដែរ នាងខ្ញុំបានស្នើទៅកូនក្តីនេះហើយ ហើយនាងខ្ញុំកំពុងតែរង់ចាំចម្លើយរបស់គាត់វិញ ដោយរំពឹងថានឹងបាននៅសប្តាហ៍នេះ ហើយនិងដាក់ជូនទៅដល់អង្គជំនុំជម្រះ ។ នាងខ្ញុំសូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

បាទឥឡូវនេះ ដល់ម៉ោងត្រូវសម្រាក ដើម្បីពិសារអាហារថ្ងៃត្រង់ហើយ ហើយម្យ៉ាងទៀតដោយសារកាលវិភាគនៃដំណើរការសវនាការមានការប្រែប្រួល ដោយហេតុផលចាំបាច់ ដូចអ្វីដែលយើងខ្ញុំបានប្រកាសជូនដំណឹងដល់ភាគីនិងសាធារណជន កាលពីព្រឹកមិញថា នៅរសៀលនេះ អង្គជំនុំជម្រះមិនអាចដំណើរការសវនាការបានទេ ដោយមិនធ្វើសវនាការទេនៅរសៀលនេះ ត្រូវដោយចាំបាច់ត្រូវប្រជុំដោះស្រាយបន្ទាន់មួយចំនួន ។

ដោយហេតុដូច្នេះ អង្គជំនុំជម្រះប្រកាសផ្អាកដំណើរការសវនាការសម្រាប់ថ្ងៃនេះ ត្រឹមនេះហើយសវនាការលើកទៅបន្តនៅព្រឹកថ្ងៃស្អែកចាប់ពីម៉ោងប្រាំបួន ។

អនុរក្សមន្ទីរឃុំឃាំងឲ្យនាំជនជាប់ចោទទៅកាន់មន្ទីរឃុំឃាំងវិញ ហើយឲ្យនាំគាត់មកកាន់សាលសវនាការនៅព្រឹកថ្ងៃស្អែកឲ្យបានមុនម៉ោងប្រាំបួន ៕

**លោកស្រី សែ កុលវុឌ្ឍី៖**

សូមអញ្ជើញក្រោកឈរ!

*[សវនាការផ្អាកនៅម៉ោង១២:០៥នាទី]*